ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Aug-2012, 13:57
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១០៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ណាតាចា វីស៊ែល រីស៊ឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារារស្មី

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រីជេត វណ្ណលី

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms. Philipine SUTZ)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក អែម អឿន (TCCP-28) | ខ្មែរ |
| លោក នង សុផង់(TCW-480) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក អែម អឿន ហៅ អៀប ឡុន** (TCCP-28)
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖ ................................ ទំព័រ ៣
សួរដោយលោក គង់ សំអុន ផ្តើមពី៖ ................................ ទំព័រ ១៤

**ការសួរសំណួរទៅសាក្សី៖ លោក នន សុផន់** (TCW-480)
សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ................................ ទំព័រ ២៦
សួរដោយលោក វ៉េង ហ៊ាត់ ផ្តើមពី៖ ................................ ទំព័រ ២៩
សួរដោយលោក ថារីក អាប់ឌុលឡាក់ ផ្តើមពី៖ ................................ ទំព័រ ៤៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅម៉ោងដំបូងនៃព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ដែលនឹងតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេញ១ថ្ងៃ នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ចំពោះសាក្សី ដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ គឺសាក្សីដែលមានរហស្សនាម TCW-480។ សាក្សីរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៣:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាន ក្នុងបន្ទប់សវនាការដោយផ្ទាល់ ដោយសុំនៅតាមដានកិច្ចដំណើរ

ការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

[០៩:០៤:00]

លោកវេជ្ជបណ្ឌិត ឈាង ឃោ គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ បានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈវិលមុខ និងហត់ នៅពេលអង្គុយ ឬពេលធ្វើចលនាបន្តិចបន្តួច និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។ នៅពេលនេះ លោក អៀង សារី បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយគាត់មានបញ្ហាសុខភាព ដូចគ្រូពេទ្យបានកត់សម្គាល់តែរូបកាយ និងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

[០៩:០៥:១៩]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាម -- ក្នុងរយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ ដែលមានវត្តមាននៅទីនេះ ជម្រាបសួរលោក អែម អឿន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ខ្ញុំចង់បន្តសួរសំណួរលោកតទៅទៀត ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោកនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ កាលពីថ្ងៃទី២៣ ខែសីហា កន្លងទៅនេះ ក្រោយពីម៉ោង ១៤:១៦:៥៦ លោកបានឆ្លើយថា "លោកគ្រូ -- នៅពេលដែលលោកទៅដល់ភ្នំពេញទៅដល់មន្ទីរពេទ្យខ្មែរ-សូវៀត លោកត្រូវបានគេចាត់តាំងជាប្រធាននិស្សិត នៅក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលផ្នែកពេទ្យ"។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ ខ្ញុំចង់ដឹងថាតើលោកមានមុខងារអ្វីខ្លះក្នុងឋានៈជាប្រធាននិស្សិតនេះ?

**លោក អែម អឿន៖**

**ឆ៖** ត្រង់ណេះ ខ្ញុំសូមជម្រាបជូនថា ការចាំឲ្យអស់មិនបានចាំអស់ទេ គ្រាន់តែខ្ញុំដឹងថា នាទីប្រធានសិស្សក្នុងថ្នាក់រៀននេះគឺ កាលណោះគឺសាលាគេឲ្យខ្ញុំទទួលខុសត្រូវពីសុខ និងទុក្ខ ឈឺថ្កាត់អីសូមឲ្យមេ លោកគ្រូ -- លោកប្រធានសិស្សហ្នឹងដឹងឮជាមុន ហ្នឹងមួយ។ មួយទៀត គេឲ្យទទួលខុសត្រូវពីការសិក្សា តើពាក់ព័ន្ធអី ខ្វះអីៗយ៉ាងណានោះ ឲ្យគេរាយការណ៍តាមរយៈខ្ញុំឲ្យលោកគ្រូអ្នកគ្រូដែលបង្រៀនគឺត្រូវការសួរខ្ញុំ។ គឺមានតែប៉ុណ្ណោះទេបាទ។

[០៩:០៧:៥៨]

**ស៖** តើលោក អែម អឿន អ្នកណាជាអ្នកប្រគល់តួនាទីនេះឲ្យលោក? ហើយអ្នកណាជាថ្នាក់លើរបស់លោក ដែលលោកត្រូវរាយការណ៍ទៅនោះ?

**ឆ៖** ស្ថិតក្នុងការសិក្សា បើតាមការចាំបានរបស់ខ្ញុំ គឺប្រធានសាលានោះ គឺលោក ជួន ជឿន ព្រមទាំងសហការីរបស់គាត់។ ខ្ញុំមិនដឹងថា អ្នកណាមួយជាសហការីទេ ព្រោះខ្ញុំមិនបានស្គាល់គេអស់។ អ៊ីចឹង ខ្ញុំមិនបាននិយាយ គ្រាន់តែអ្នកទទួលខុសត្រូវសាលាគឺ លោកគ្រូ ជួន ជឿន នេះឯង។

**ស៖** តើខ្ញុំត្រូវយល់ថា គឺលោក ជួន ជឿន ជាអ្នកប្រគល់តំណែងជាប្រធានសិស្សពេទ្យនេះឲ្យលោកមែនទេ? គឺគាត់មែនទេ?

**ឆ៖** បាទ។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកបានបញ្ជាក់ថា "មានសិស្សពេទ្យប្រហែល១.០០០នាក់ នៅក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលនេះ"។ ខ្ញុំចង់ដឹងថា

ហេតុអ្វីបានជាគេរើសលោកក្នុងចំណោមអ្នក១.០០០នាក់ហ្នឹង ដើម្បីឲ្យកាន់មុខងារនេះ?

[០៩:០៩:៥៤]

**ឆ៖** តាមចាំបាន ឱកាសដែលគេតែងតាំងខ្ញុំ ដោយសារការឧទ្ទេសនាមពីមូលដ្ឋានទៅពីតំបន់ ឬភូមិភាគទៅ គឺគេមើលទៅតាមតួនាទីទៅពីខាងដើម។ អ៊ីចឹងនៅឱកាសនោះ គឺឋានៈជាអ្នកទៅរៀននៅក្នុងឱកាសនោះតិចណាស់ ឈ្មោះឋានៈទទួល -- ទទួលថាជាសមាជិកច្បាស់លាស់របស់ៗអង្គការ បានន័យថា អ្នកដែលទទួលច្បាស់នោះ គឺគេទទួលសិទ្ធិ អ្នកណាសម្ព័ន្ធ អ្នកណាបក្ស។ ឯខ្ញុំពេលនោះ គឺខ្ញុំស្ថិតនៅក្នុងតំណែងមួយគឺជាសមាជិកបក្ស។ នោះទើបបានគេឲ្យ ខ្ញុំធ្វើជាតំណាងប្រធានសិស្សបាទ។

**ស៖** សូមអរគុណចំពោះការពន្យល់នេះ។ លោកទើបតែឆ្លើយថាមានការណែនាំពីមូលដ្ឋាន តើលោកដឹងទេថាអ្នកណានៅមូលដ្ឋានដែលជាអ្នកណែនាំ ដើម្បីឲ្យលោកក្លាយទៅជាប្រធានសិស្សពេទ្យហ្នឹង?

**ឆ៖** ត្រង់ហ្នឹងសូមបញ្ជាក់បន្ថែម បើខាងម្ចាស់សំណួរមិនយល់ខ្ញុំបញ្ជាក់ថា ការបំពេញអប់រំមិនមែនអប់រំថ្ងៃនុ៎ងទេ ទៅទីនុ៎ងទេ គឺបក្សអប់រំនៅមូលដ្ឋានពីខាងដើមមកបានជាខ្ញុំក្លាយទៅជាសមាជិកបក្សនៅក្នុងទីនោះ។ អ៊ីចឹង ខ្ញុំមានអំណាចមួយនៅក្នុងតួនាទីពេទ្យនោះ គឺខ្ញុំមានតួនាទីសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ស្ថិតនៅក្នុងមន្ទីរពេទ្យតំបន់។ ហ្នឹងសូមជ្រាបបាទ។

[០៩:១១:៥២]

**ស៖** លោក អែម អឿន ខ្ញុំយល់ហើយ ក៏ប៉ុន្តែសំណួរខ្ញុំ ខ្ញុំចង់បានឈ្មោះតែម្តង គឺឈ្មោះបុគ្គលដែលផ្តាំផ្ញើថាឲ្យលោកធ្វើជាប្រធានសិស្សពេទ្យនេះ?

**ឆ៖** នៅក្នុងមន្ទីរពេទ្យរុស្ស៊ី ការតែងតាំងក្នុងសាលាគឺលោក ជួន ជឿន ឯការតែងតាំងពីតំបន់មកឲ្យខ្ញុំឡើងមករៀនគឺ តាអ៊ុត ប្រធានមន្ទីរពេទ្យតំបន់ និង បងខឹម នោះជាលេខាតំបន់បានឧទ្ទេសនាមឲ្យខ្ញុំឡើងមករៀន។ សូមជ្រាបបាទ។

**ស៖** សូមអរគុណលោក អែម អឿន។ ឥឡូវនេះ ខ្ញុំចូលទៅពិភាក្សាចំណុចមួយផ្សេងទៀត។ ខ្ញុំសូមយោងទៅលើសំណុំបែបបទព័ត៌មានជនរងគ្រោះរបស់លោកទាំងពីរ ជាពិសេសពាក់ព័ន្ធនឹងចំណុចដែលលោកនិយាយអំពីការចាប់ខ្លួនលោកស្រី ឡេង សី។ ខ្ញុំសូមយោងទៅលើឯកសារ D230/2/4.2.277a។ ERN ជាភាសាបារាំង 00822270, ERN ជាភាសាខ្មែរ 00508424 ហើយបន្តទៅទំព័រខាងមុខបន្ទាប់មកទៀត, ERN ជាភាសាអង់គ្លេស 00777625។ ខ្ញុំសូមអាននូវសម្រង់នៃឯកសារនេះ ជា

ភាសាបារាំងគឺទំព័រ១៤ គឺកថាខណ្ឌចុងក្រោយ លោកឆ្លើយថា "នៅចុងឆ្នាំ៧៧ នៅពេលដែលលោកសិក្សានោះ ខ្ញុំឃើញគេដឹកពីមន្ទីរពេទ្យ គឺគេដឹកតាមឡាន គឺថាគេគិតថាគាត់ជាខ្មាំង -- ជាជនក្បត់ គឺគាត់ឈ្មោះលោកស្រី ឡេង សី ជាប្រធានមន្ទីរពេទ្យរុស្ស៊ី"។ នេះគឺជាសម្រង់ដំបូងដែលខ្ញុំចង់ដកស្រង់។

[០៩:១៤:៣០]

ឥឡូវនេះ ខ្ញុំសូមដកស្រង់នូវឃ្លាមួយទៀត គឺនៅឯកសារមួយផ្សេងទៀត គឺឯកសារលេខ D22/3963, ERN ជាភាសាបារាំង 00786287, ERN ជាភាសា 00751868, ERN ជាភាសាខ្មែរ 00573980។ នៅក្នុងឯកសារនេះ លោកបានរៀបរាប់ពីព្រឹត្តិការណ៍ដូចគ្នានេះ គឺការចាប់ខ្លួនលោកស្រី ឡេង សី។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអាននេះ គឺជាអានការបកប្រែជាភាសាបារាំង "ខ្ញុំបានឃើញផ្ទាល់ភ្នែកចំពោះការចាប់អ្នកគ្រូម្នាក់ឈ្មោះ ឡេង សី ជាប្រពន្ធលោក ទីវ អុល ដោយប្ដីរបស់គាត់គេចោទជាភ្នាក់ងារ សេ.អ៊ី.អា។ ហើយលោកស្រី ឡេង សី គេចោទថាជាភ្នាក់ងារ កា.ហ្សេ.បេ។ ឈុតឆាកនេះ វាគួរឲ្យរន្ធត់ណាស់ មុនពេលគេបោះទៅក្នុងឡាន គេត្រូវបោះខោអាវរបស់ពួកគេ។ អ្នកណាឡើងឡានយឺតអ្នកនោះត្រូវគេវាយរហូតទាល់សន្លប់។ ហេតុការណ៍នេះកើតឡើងនៅក្នុងមន្ទីររុស្ស៊ី ក្រុងភ្នំពេញនៅចុងឆ្នាំ១៩៧៦"។ បន្ទាប់ពីអានឃ្លាទាំងពីរនេះទៅ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកបានឃើញនូវការចាប់ខ្លួនអ្នកគ្រូ ឡេង សី។ តើនៅពេលនោះ គេចាប់ខ្លួនទាំងប្ដីរបស់គាត់ដែរឬទេ?

[០៩:១៦:៤៩]

**ប្រធានអង្គជំនុំ៖**

សាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ តាមពិតមិនមែនជាការជំទាស់អ្វីទេ។ ខ្ញុំគិតថាប្រហែលជាមានការបកប្រែ បញ្ហាបកប្រែ នៅក្នុងជាភាសាបារាំងនោះ មានន័យថាគឺប្ដីប្រពន្ធត្រូវបានគេដោះខោអាវ ប៉ុន្តែជាភាសាអង់គ្លេសដូចមិនមែនថាជាប្ដីប្រពន្ធទេ គឺមានន័យថា គ្រាន់តែជាមនុស្សពីរនាក់ ដែលត្រូវបានគេចាប់ខ្លួន ហើយគេសម្រាតខោអាវ។ ដូច្នេះ ខ្ញុំគិតថាមិនគួរផ្អែកទៅលើឯកសារជាភាសាបារាំងនោះទេ។ គួរតែផ្អែកទៅលើឯកសារច្បាប់ដើមជាភាសាខ្មែរ ដើម្បីឲ្យយល់ថាតើឃ្លានេះមានន័យយ៉ាងម៉េច?

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំគិតថា ការកត់សម្គាល់របស់សហព្រះរាជអាជ្ញានោះមិនត្រឹមត្រូវទេ គឺខ្ញុំអាន អានជាការបកប្រែភាសាបារាំង ដូច្នេះ ខ្ញុំមិនមែនយកបញ្ហាមកខុសទេ។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននៅនេះ គឺថាគាត់អាចពន្យល់បញ្ជាក់បំភ្លឺបាន មិនមែនជាសហព្រះរាជអាជ្ញា គាត់មិនមែនជាសាក្សីមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ គាត់អាចបញ្ជាក់បាន។ ខ្ញុំខ្ញុំច្បាស់ណាស់ ខ្ញុំសួរសំណួរច្បាស់លាស់ ខ្ញុំចង់បានការបំភ្លឺពីលោក អែម អឿន។ ដូច្នេះ ខ្ញុំគិតថា គឺអាចផ្តល់ឱកាសឲ្យគាត់ក្នុងការផ្តល់ការបំភ្លឺ មិនមែនឲ្យទៅសហព្រះរាជអាជ្ញាជាអ្នកបំភ្លឺទេ។ ដូច្នេះ សូមលោកប្រធានសម្រេច ថាតើខ្ញុំអាចបន្តការសុំបំភ្លឺពីគាត់បានដែរឬទេ?

[០៩:១៨:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៩:០៣]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន។ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រមខ្ញុំចង់អន្តរាគមន៍ពីព្រោះខ្ញុំគិតថា របៀបដែលមេធាវីការពារក្តីពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីហើយនិងឆ្លើយទៅនឹងសហព្រះរាជអាជ្ញានេះមិនត្រឹមត្រូវទេ។ គឺថាយើងសួរត្រូវសួរពីឯកសារច្បាប់ដើម យើងមិនត្រូវយកឯកសារបកប្រែទេ ព្រោះថាវាអាចមានភាពផ្ទុយគ្នារវាងការបកប្រែខ្មែរ និងភាសាបារាំង។ ដូច្នេះ នៅពេលដែលយើងយកឯកសារបកប្រែ ហើយយកមកគិតថាជាឯកសារត្រឹមត្រូវយកមកសួរនោះ ខ្ញុំគិតថា វាមិនមែនជាលក្ខណៈ១ សមស្របនោះទេ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំគិតថាយើងធ្វើបែបនេះ គឺមិនត្រឹមត្រូវទេ។

[០៩:២០:០០]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន បើតាមយើងចងចាំ គឺលោកស្រីតែងតែមានការស្នើសុំថា ឲ្យការនិយាយហ្នឹងមានការឃ្លាតគ្នា ពីព្រោះការបកប្រែមិនទាន់ទេ។ ប៉ុន្តែអំមិញនេះគឺពីរដង ដោយសារការប្រឈមនឹងការដេញដោលគ្នា រវាងប្រើភាសាបារាំងដូចគ្នា គឺការនិយាយរបស់

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិនិយាយស្ទើរតែមិនទាន់ចប់ផង លោកស្រីចាប់ផ្តើមនិយាយភ្លាម ហើយការបកប្រែ គឺបកប្រែមិនអស់សេចក្តីទេ។ ហើយដូចគ្នាដែរ គឺលោកស្រីខាងប្រើភាសាបារាំង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំមិញ គឺលោកស្រីនិយាយភ្លាម។ នោះលោកស្រីភ្លេចនូវសំណើសុំរបស់លោកស្រី ដែលបែបមិនតិចជាង១០ដងទេ ដែលលោកស្រីបានស្នើសុំម្តងហើយម្តងទៀតបញ្ហានេះ។

ឥឡូវនេះធ្លាក់មកលើខ្លួនលោកស្រីដែលជាអ្នកស្នើសុំ ហើយកត់សម្គាល់បញ្ហានេះច្រើនជាងគេបាទបញ្ហាទី១។ បញ្ហាទី២ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីបន្តការតាំងសំណួរដេញដោលផ្អែកលើឯកសារដែលលោកស្រីមាននៅក្នុងដៃ ពីព្រោះភាសានេះ គឺភាសាប្រើប្រាស់ផ្លូវការនៅ អ.វ.ត.ក ហើយ។ ហើយពេលនេះមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់បានដឹងអំពីអង្គហេតុនោះ គាត់នឹងអាចបញ្ជាក់ច្បាស់អំពីបញ្ហានេះហើយ។ មិនមានមូលដ្ឋានអី ដែលតម្រូវឲ្យមេធាវីបារាំងទៅមើលឯកសារជាភាសាខ្មែរ ជាភាសាដើមនោះទេ។

[០៩:២១:៤៨]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជាដំបូងសូមអភ័យទោសសិន ខ្ញុំគួរតែឈប់ចាំឲ្យគេនិយាយចប់សិន។ ដូច្នេះសូមអធ្យាស្រ័យ។ ពាក់ព័ន្ធទៅនឹងបញ្ហាបកប្រែ ច្បាស់ណាស់ថាយើងធ្វើការជាមួយជនជាតិខ្មែរ និងជនជាតិបារាំង។ ហើយចំពោះខ្ញុំ ខ្ញុំបានកំណត់ឃើញមានបញ្ហាពាក់ព័ន្ធទៅនឹងភាសាខ្មែរ និងភាសាបារាំង ហេតុនេះហើយបានខ្ញុំសួរបំភ្លឺពីដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះខ្ញុំគិតថា បុគ្គលដែលអាចឆ្លើយទៅនឹងសំណួររបស់ខ្ញុំបាន គឺលោក អែម អឿន នេះហើយ។ ដូច្នេះហើយ មូលហេតុនេះហើយបានជាខ្ញុំសួរគាត់ ដើម្បីឲ្យគាត់បញ្ជាក់ឲ្យច្បាស់។

ដូចគ្នានេះដែរ ខ្ញុំគិតថា វាមិនត្រឹមត្រូវទេ ពេលដែលខ្ញុំអាននូវឃ្លាទី២ នៃឃ្លានៃឯកសារទី២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺឯកសារលេខ D22/3963 នេះ ខ្ញុំបញ្ជាក់ច្បាស់ណាស់ ខ្ញុំបញ្ជាក់ថា ខ្ញុំអានចេញពីឯកសារជាភាសាបារាំង។ ដូច្នេះ ខ្ញុំមានលក្ខណៈច្បាស់លាស់ណាស់ចំពោះលោក អែម អឿន។

[០៩:២២:៥៦]

ហើយនៅពេលដែលយើងមានបញ្ហាពាក់ព័ន្ធនឹងការបកប្រែនោះ ក្នុងសវនាការយើងត្រូវតែលើក

ពីបញ្ហានេះ ដើម្បីឲ្យមានការកែតម្រូវ ប្រសិនបើមានការត្រូវការកែតម្រូវនោះ។ ប្រសិនបើយើងត្រូវការឯកសារត្រឹមត្រូវ យោងត្រឹមត្រូវ ហើយបារាំងនិយាយផ្សេង ខ្មែរនិយាយផ្សេងនោះ យើងត្រូវតែមានការកែតម្រូវ។ ដូច្នេះ--

**ប្រធានអង្គជំនុំ៖**

អំមិញនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីអនុវត្តដូច្នេះហើយ។ យើងបដិសេធនូវការជំទាស់របស់ភាគីតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូចជាលោកស្រីមានសិទ្ធិហើយនៅក្នុងការប្រើប្រាស់សំណួរ ដែលលោកស្រីមានការបំណងក្នុងការតាំងសំណួរនេះ។ មានអីបកស្រាយទៀត!

[០៩:២៣:៥៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះខ្ញុំអត់យល់ ហេតុនេះហើយបានជាខ្ញុំបន្តផ្តល់ទទ្បីករណ៍។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក អែម អឿន ខ្ញុំត្រឡប់មកលោកវិញ ដោយសារតែលោកបានស្តាប់ការពិភាក្សានេះហើយ ដូច្នេះខ្ញុំសួរលោកបញ្ជាក់ឲ្យបានច្បាស់ថា តើនៅពេលដែលគេចាប់ខ្លួនអ្នកស្រី ឡេង សី ដែលលោកបានឃើញផ្ទាល់ភ្នែកនោះ តើលោកឃើញគេចាប់ទាំងប្តីគាត់ទេនៅពេលនុ៎ង?

**លោក អែម អឿន៖**

**ឆ៖** សូមបញ្ជាក់ចម្លើយនេះ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ដើម្បីកុំឲ្យមានការដេញដោលសង្ស័យ មិនមែនការបកស្រាយខុសទេ ការពិតប្រហែលជាគេ គេសរសេរ -- អ្នកសរសេរ គឺខុសក្នុងឯកសារដើមរបស់ខ្ញុំ គ្រាន់តែដាក់ថា "ឡេង សី ត្រូវជាប្រពន្ធរបស់លោក ទីវ អុល។ ឡេង សី ត្រូវគេចាប់នៅក្នុងមន្ទីរពេទ្យ។ ពេលនោះខ្ញុំបានឃើញ អ្នកស្រីគេត្រូវដោះខោអាវចេញអស់ពីខ្លួន។ ក្នុងនោះដែរខ្ញុំបានឃើញថា បុគ្គលណាដែលគេត្រូវឲ្យឡើងឡាន បើសិនជាឡើងមិនទាន់ទេ យឺតយ៉ាវ គេនឹងវាយដំច្រំធាក់នោះគឺជាការពិត។ សូមអ្នកម្ចាស់សំណួរឲ្យច្បាស់បាទ។ ខ្ញុំមិនបានប្រាប់ថា គាត់ទាំងពីរនាក់ប្តីប្រពន្ធគេចាប់ពេលតែមួយជាមួយគ្នា មិនមែនអ៊ីចឹងទេ គឺខ្ញុំគ្រាន់តែថា ឡេង សី ជាប្រពន្ធរបស់លោក ទីវ អុល។ សូមច្បាស់បាទ។

[០៩:២៥:៣៣]

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះលោក អែម អឿន។ ខ្ញុំគិតថាឥឡូវនេះយើងទទួលបាននូវចម្លើយច្បាស់លាស់ហើយ ទោះបីជាភាសាអ្វីក៏ដោយ។ ឥឡូវនេះ ខ្ញុំចូលទៅចំណុចមួយផ្សេងទៀត។ នៅពេលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកបញ្ជាក់កាលពីថ្ងៃទី២៣ ខែសីហា នៅចន្លោះម៉ោង ១៤:២២ ទៅដល់ ២៤ ពាក់ព័ន្ធទៅនឹងការរៀនសូត្រនយោបាយនៅបុរីកីឡា លោកអះអាងថា “ការបណ្តុះបណ្តាលនោះមានរយៈពេលខ្លីទេ គឺប្រហែលជា១អាទិត្យ ឬក៏ទៅដល់១០ថ្ងៃជាទូទៅនោះ។ ហើយប្រហែលជាម្តងទៅពីរដងក្នុង១ខែ”។ បន្ទាប់មកទៀតនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលសុំឲ្យលោកឆ្លើយបញ្ជាក់ លោកបានបញ្ជាក់ថា “លោកបានចូលរួមក្នុងវគ្គតែម្តងទេ”។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកបានដឹងអំពីវគ្គរៀនសូត្រផ្សេងទៀតយ៉ាងដូចម្តេច បើលោកមិនបានចូលរួមផងនោះ?

[០៩:២៧:០៤]

**ឆ៖** ខ្ញុំសូមបញ្ជាក់ត្រង់ចម្លើយនេះ ខ្ញុំសូមបញ្ជាក់ត្រង់ថា មូលហេតុដែលខ្ញុំដឹងអាស្រ័យដោយមានអ្នកមកពីមូលដ្ឋានស្គាល់គ្នាទៅ ចូលរៀនហើយ គេទៅជួបគ្នានៅមន្ទីរពេទ្យខ្ញុំដែរ។ គេដឹងថា ខ្ញុំរៀននៅមន្ទីរពេទ្យ កាលណាជួបតែងតែសំណេះសំណាល សួរពីនេះពីនោះ សួរពីនោះ។ អ៊ីចឹងសូមម្ចាស់សំណួរទទួលស្គាល់បាទ។

**ស៖** ជាថ្មីម្តងទៀត ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ថាអ្នកនៅមូលដ្ឋានណាខ្លះដែលលោកបានជួបនៅពេលនោះ? សូមឲ្យលោកផ្តល់ឈ្មោះអ្នកនៅមូលដ្ឋានដែលលោកបានជួបនៅទីនោះ។

**ឆ៖** ដោយយូរអង្វែងពេក ខ្ញុំបានមិនបានចាំអស់ទេបាទ។

**ស៖** ខ្ញុំគ្រាន់តែចង់បានឈ្មោះអ្នកដែលលោកនឹកឃើញ គ្រប់គ្រាន់ហើយ។ តើលោកមាននឹកឃើញឈ្មោះអ្នកណាខ្លះទេ?

[០៩:២៨:២៨]

**ឆ៖** នឹករកអត់ឃើញទេបាទ ព្រោះថាការពាក់ព័ន្ធហ្នឹងច្រើនៗរឿង ហើយក៏ច្រើនលើក។ អ៊ីចឹង ខ្ញុំមិនអាចចាំបានអស់ទេបាទ។

**ស៖** សូមអរគុណ មិនអីទេ។ នៅក្នុងសវនាការកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ គឺមុនម៉ោង ១០:១៨:៥៣ នៅពេលលោកឆ្លើយទៅនឹងសំណួររបស់លោកសហព្រះរាជអាជ្ញា។ សហព្រះរាជ

អាជ្ញាសួរលោកដូចតទៅនេះ៖ “ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ ដើម្បីឲ្យខ្ញុំដឹងថាតើខ្ញុំយល់ច្បាស់ឬមិនច្បាស់។ អម្បាញ់មិញនេះ គឺថាលោក នៅពេលដែលលោកនៅបុរីកីឡា តើគឺជាលើកដំបូងបង្អស់មែនទេ ដែលលោកឃើញ ប៉ុល ពត, នួន ជា, និង ខៀវ សំផន ក៏ដូចជាមេដឹកនាំផ្សេងទៀតនោះ? តើអ៊ីចឹងមែនទេ?” ពេលនោះលោកឆ្លើយថា៖ “បាទ នោះជាការពិត ខ្ញុំទើបឃើញដំបូងបង្អស់បាទ ក្នុងជីវិត”។ នេះគឺជាចម្លើយរបស់លោកកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២។ តើលោកនៅរក្សាចម្លើយនេះទេ?

[០៩:៣០:០២]

**ឆ៖** បាទ នោះជារឿងពិតរបស់ខ្ញុំបាននិយាយ។

**ស៖** នៅក្នុងសវនាការកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ គឺពាក់ព័ន្ធទៅនឹងប្រធានបទមេដឹកនាំ ហើយនិងបុរីកីឡាដដែល គឺមុនម៉ោង ១៤:៣០:៥៣ លោកបានឆ្លើយថា “ពីដំបូងមានមេដឹកនាំជាច្រើន ហើយខ្ញុំចាំតែអ្នកណាដែលខ្ញុំស្គាល់ទេ ក្នុងចំណោមនោះមានដូចជា នួន ជា, ខៀវ សំផន លោកស្រី ឡេង សី មកពីខាងសង្គមកិច្ច”។ ខ្ញុំចង់សួរលោកថា ប្រសិនបើពេលនោះជាលើកដំបូងដែលលោកបានឃើញមេដឹកនាំ តើលោកម៉េចស្គាល់ពួកគាត់បាន បើទើបនឹងឃើញជាលើកដំបូងនោះ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំបានបញ្ជាក់ហើយថា ស្គាល់ក្រោមការណែនាំឈ្មោះ ពេលចូលបើកសាលានោះ ខ្ញុំចាប់ផ្ដើមស្គាល់។

[០៩:៣១:៣៣]

**ស៖** សូមអរគុណ។ នៅពេលរៀននោះ តើលោក សោ ភឹម ដែលនៅភូមិភាគរបស់លោកនោះមានវត្តមាននៅក្នុងវគ្គរៀនសូត្រនោះទេ?

**ឆ៖** អត់មានទេបាទ។

**ស៖** លោកបានឆ្លើយថា នៅក្នុងវគ្គរៀនសូត្រនោះ លោកមានវត្តមានក្នុងនាមជាប្រធានសិស្សពេទ្យ ហើយក្នុងនោះមានប្រធានស្រុក ចូលរួមផងដែរ។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថាតើការបណ្ដុះបណ្ដាលនេះសម្រាប់អ្នកណាខ្លះ? វគ្គបណ្ដុះបណ្ដាលដែលលោកចូលរួមនោះ ថាតើវាសម្រាប់បណ្ដុះបណ្ដាលអ្នកណា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ បញ្ហាទាំងនេះខ្ញុំនិយាយ -- បាននិយាយមែនក្នុងសាលា ហើយក្នុងឱកាសនេះក៏ខ្ញុំនិយាយ។ ឈ្មោះថាមានស្រុកមានអី គឺខ្ញុំនិយាយពីលក្ខណៈដែលចូលរៀនៗនយោបាយ។ អ៊ីចឹង

ការចូលរៀនគឺមានទាបបំផុតគឺថ្នាក់ស្រុក។ អ៊ីចឹងសូមលោកម្ចាស់សំណួរស្គាល់ ទទួលដឹងឮ។

**ស៖** សូមអរគុណ។ ចុះអ្នកដែលមានឋានៈខ្ពស់ជាងគេនោះអ្នក -- ជាអ្នកណាដែរ?

**ឆ៖** សូមបញ្ជាក់ខ្ពស់បំផុតនោះសួរក្នុងនាមសិស្ស ឬក៏សួរក្នុងនាមអី?

[០៩:៣៣:៣៧]

**ស៖** ខ្ញុំចង់និយាយពីសិស្ស។ សិស្សដែលរៀនទុំង តើអ្នកដែលមានឋានៈខ្ពស់ជាងគេហ្នឹង គឺមានអ្នកណាខ្លះ?

**ឆ៖** សូមលោកម្ចាស់សំណួរឲ្យបានយល់ថា ខ្ពស់ជាងគេបំផុតក្នុងឋានៈដែលទៅរៀន បានន័យថា គេយកក្នុងស្រុកមួយ ស្រុកនោះគេត្រូវតែយកបុគ្គលណាដែលមានឋានៈខ្ពស់ក្នុងស្រុក។ អ៊ីចឹងស្រុកណាក៏ដូចជាស្រុកណាគ្រប់។ ប៉ុន្តែការដឹងឮក្នុងឋានៈថាខ្ពស់ជាងគេក្នុងស្រុកនោះ វាគ្រប់ស្រុក វាមិនដឹងស្រុកណាអ្នកខ្ពស់មករៀននោះទេ គ្រាន់តែបានដឹងថា ឋានៈនោះគេចាប់ផ្ដើមយកទៅរៀនពីថ្នាក់ស្រុក គឺថ្នាក់ខ្ពស់បំផុតគឺថ្នាក់ស្រុក ដែលគេត្រូវយកពីស្រុកហ្នឹងយកអ្នកខ្ពស់ជាងគេក្នុងស្រុក។ មិនមែនខ្ពស់ជាងគេ -- គេយកពី -- យកអ្នកខ្ពស់ជាងគេក្នុងស្រុកមួយៗ។ អ៊ីចឹងបានន័យថា គេទៅរៀនតែត្រឹមថ្នាក់ស្រុកទេ។ ឯអ្នកដែលខ្ពស់ជាងថ្នាក់ស្រុក គេអាចយកដល់តំបន់ មានភូមិភាគ ហើយបើតំបន់គេយកក្រសួងរបស់តំបន់ និងគេយកគណៈតំបន់ ឲ្យតែមាននាទីក្នុងឋានៈ ឋានៈក្នុងគណៈតំបន់។ ឯក្រសួងគេយកប្រធានក្រសួង និងអនុប្រធានក្រសួង។ នោះជាការពិតដែលខ្ញុំបានឃើញច្បាស់បាទ។

[០៩:៣៥:១៥]

**ស៖** យោងទៅតាមអ្វីដែលលោកឆ្លើយអម្បាញ់មិញនេះ តើចំពោះលោកផ្ទាល់ លោកមានតួនាទីអ្វីទេ នៅក្នុងគណៈស្រុក គណៈតំបន់ ឬក៏គណៈភូមិភាគនោះ?

**ឆ៖** សូមបញ្ជាក់ក្នុងឋានៈ បើសិនជា -- មិនមែនទេ នៅពេលដែលខ្ញុំនៅគណៈ នៅតំបន់ នៅមន្ទីរតំបន់ ខ្ញុំមិនមានសិទ្ធិ ប្រហែលជាខ្ញុំអត់មានសិទ្ធិមករៀនទេ។ ប៉ុន្តែដល់ខ្ញុំមកដល់ពេទ្យរុស្ស៊ី គឺជាភ្នាក់ងារចល័តក្នុងមន្ទីរផង ចល័តទៅកន្លែងមូលដ្ឋានរបស់ខ្ញុំ ជាសិស្សផង។ ដូច្នេះ ក្នុងនាទីនេះ ខ្ញុំមាននាទីជាប្រធានសិស្ស។ ទើបខ្ញុំមានសិទ្ធិចូលរៀនសាលានេះបាទ។

[០៩:៣៦:១៨]

**ស៖** ចុះក្នុងឋានៈជាប្រធានសិស្សពេទ្យ តើលោកមាននាំសិស្សពេទ្យផ្សេងៗទៀត ទៅរៀនវគ្គនយោបាយនៅបុរីកីឡាហ្នឹងទេ?

**ឆ៖** ត្រង់ណេះ សូមម្ចាស់សំណួរយល់បានថា ក្នុងដែលខ្ញុំថាក្នុងតួអ្នកសិស្សរៀននេះ គេយកតែប្រធានសិស្សទេ គេមិនបានយកសិស្សទាំងអស់ទៅបានទេ។ ព្រោះការទៅនេះ ក៏មិនចង់ទៅ ទៅបានដែរ ព្រោះកាលទៅកាលណោះ គឺសម័យ គឺគោរពវិន័យណាស់ បើបុគ្គលណាប៉ាន់តែខុស គឺរក្សាជីវិតមិនបាន។ ហ្នឹង សូមម្ចាស់សំណួរដឹងឮជ្រាប បាទ។

**ស៖** លោកបានឆ្លើយនៅក្នុងសវនាការ ថាអ្នកស្រី ឡេង សី ខាងសង្គមកិច្ច មានវត្តមាននៅក្នុងវគ្គនយោបាយនោះដែរ។ តើគាត់មានធ្វើបទឧទ្ទេសនាមអ្វីទេ នៅក្នុងវគ្គនុ៎ង?

**ឆ៖** ក្នុងពេលនោះ ឡេង សី គ្មានឧទ្ទេសនាមអីទេ បាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំចំពោះចម្លើយរបស់លោកកាលពីថ្ងៃទី២៣ សីហា ទេ គឺថាគាត់នៅលើវេទិកា។ តើអ៊ីចឹងមែនទេ?

**ឆ៖** គាត់នៅក្នុងវេទិកា បានន័យថា គាត់ជាតំណាងឲ្យមន្ទីរពេទ្យមិត្តខ្មែរ-សូវៀត នេះទេ។ មិនមែនថា ចូលក្នុងបទឧទ្ទេសនាមអីទេ។ បានន័យថា ពេលនោះ គាត់ចូលទៅសង្កេតការណ៍ក្នុងកិច្ចការដែលមានសិស្សរបស់គាត់បានទៅរៀនដែរ។

**ស៖** លោកទើបបាននិយាយបញ្ជាក់ថា សិស្សពេទ្យនៅពេទ្យនោះ ក៏មានវត្តមានដែរ។ អ៊ីចឹងមានន័យថា មិនមែនលោកតែម្នាក់ឯងទេ ដែលមានវត្តមាននៅក្នុងនោះ ដែលមកពីមន្ទីរ។ អ៊ីចឹងមែនទេ?

[០៩:៣៨:៥៤]

**ឆ៖** ខ្ញុំដូចមិនយល់ពីអ្នកសំណួរ។ ខ្ញុំជាសិស្ស គ្រាន់តែទៅតាមមើល។ អ៊ីចឹង ខ្ញុំអត់ចាំថាសិស្សណាៗ ខ្ញុំថាមានសិស្សរបស់គាត់តើ។ សូមអស់។

**ស៖** សូមអរគុណ។ នៅពេលដែលខ្ញុំសួរលោកចង់ដឹងថា លោកមកជាមួយសិស្សពេទ្យផ្សេងទៀត ឬក៏អត់។ លោក ប្រហែលជាលោកច្រឡំ ឬមួយក៏ខ្ញុំស្តាប់មិនយល់ទេ ចំពោះចំណុចនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ អ៎! ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរនេះដូចជាអត់ប្រយោជន៍ទេ។ ប្រហែលជាគាត់ស្តាប់មិនច្បាស់អម្បាញ់មិញនេះ ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយច្បាស់ហើយ ថាមានតែគាត់ទេ

ដែលជាប្រធានសិស្សពេទ្យហ្នឹង ដែលមិនបានមកចូលរួម។ គាត់និយាយថា គឺថានៅក្នុងពេលនោះ គឺអាចមានន័យថាជា មានប្រធានសិស្សពេទ្យច្រើន។ ដូច្នេះ សូមអាចឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់ពន្យល់បញ្ជាក់។

[០៩:៤០:១៧]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំចង់បានន័យថា គឺសូមឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់ហើយថាតើខ្ញុំយល់ច្រឡំ ឬក៏គាត់ឆ្លើយខុស ហើយមិនមែនលោកសហព្រះរាជអាជ្ញាជាអ្នកបំភ្លឺទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់ជាអ្នកឆ្លើយបញ្ជាក់។

[០៩:៤០:៤០]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរ!

**លោក អែម អឿន៖**

**ឆ៖** សូមបញ្ជាក់បន្ថែមសំណួរម្តងទៀត។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោក អែម អឿន លោកបានឆ្លើយថា "អ្នកស្រី ឡេង សី មានវត្តមាន ពីព្រោះនៅក្នុងវគ្គសិក្សានោះ មានសិស្សនៅ -- សិស្សពេទ្យ" ដូចដែលបានខ្ញុំសួរពីមុនមកនោះ សួរថាតើមានសិស្សផ្សេងទៀតនៃមន្ទីរពេទ្យហ្នឹងក្រៅពីលោកនោះ ថាមានវត្តមានដែរឬទេ? ហើយកាលនោះ ខ្ញុំយល់ថា មានតែលោកទេដែលមានវត្តមាន។ អ៊ីចឹងហើយ បានខ្ញុំសួរលោកជាថ្មីថាតើមានសិស្សពេទ្យផ្សេងទៀត នៅទីហ្នឹងដែរឬទេ ឬក៏មានតែលោកទេដែលមានវត្តមាននៅទីនោះ?

**ឆ៖** អរគុណ។ សំណួរនេះបានន័យថា ខ្ញុំសូមឆ្លើយឆាប់អស់ ត្រង់ថា ពេលដែលទៅរៀនពីមន្ទីរពេទ្យនោះ គឺមានតែខ្ញុំម្នាក់ទេ ព្រោះមាននាទីជាប្រធានគេ។ ឯ ឡេង សី ទៅក្នុងឋានៈរបស់គាត់ជាអ្នកត្រួតពិនិត្យ។ សិស្សរបស់គាត់ ដូចជាអ្នកអី ក៏ខ្ញុំមិនដឹងដែរ ព្រោះថា ខ្ញុំគ្រាន់តែដឹងថា គាត់បានចូលទៅមែន។ ហ្នឹងសូមបញ្ជាក់បាទ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំចោទសួរចប់ហើយ ហើយខ្ញុំគិតថា សហភាតារបស់ខ្ញុំលោក គង់ សំអឿន(ស៊ីក)

ប្រហែលជា មានប្រធានបទផ្សេងទៀត ដែលលើកយកនិយាយ។ ហើយលោក អែម អឿន ខ្ញុំសូមអរគុណដែលអត់ធ្មត់ក្នុងការឆ្លើយសំណួរខ្ញុំ ហើយខ្ញុំសូមបញ្ចប់ការចោទសំណួរទៅលោកនៅត្រឹមនេះ។ លោកប្រធាន ខ្ញុំចប់ហើយ។

[០៩:៤២:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ កុំ -- មិនគប្បីដូរឈ្មោះមេធាវីទេ! មេធាវីឈ្មោះ គង់ សំអុន មិនមែន គង់ សំអឿន ទេ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ អង្គសវនាការទាំងមូល។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក អែម អឿន ខ្ញុំមានសំណួរតិចតួចទេ ដើម្បីសួរបញ្ជាក់លោក ហើយលោកនឹងបានបញ្ចប់ក្នុងពេលឆាប់ៗនេះ។ ជាដំបូង ខ្ញុំសូមឲ្យលោកជួយបញ្ជាក់ ទៅលើបញ្ហាធ្វើកំណត់ហេតុ នូវពាក្យបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ដែលលោកបានធ្វើនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ពីព្រោះខ្ញុំបានពិនិត្យនៅក្នុងឯកសារ ក៏ដូចជាអ្វីដែលលោកបានឆ្លើយបំភ្លឺក្នុងសវនាការកន្លងមកនេះ ឃើញថា ការបង្ហាញពីកាលបរិច្ឆេទជាដើម គឺមានការផ្លាស់ប្តូរ។ ឧទាហរណ៍ ដូចជាករណីការបាត់ខ្លួនឪពុករបស់លោក ក៏ដូចជាចំណុចខ្លះលោកបានបញ្ជាក់ថា ឪពុករបស់លោកត្រូវគេសម្លាប់។ កាលបរិច្ឆេទនេះឃើញថា ក្នុងឯកសារដំបូងលោកបានកំណត់យកថាខែ ឆ្នាំ៧៤ ជាឆ្នាំដែលឪពុកលោកត្រូវបានគេយកចេញទៅ តែក្រោយមកគឺមានបញ្ជាក់ទៅលើឆ្នាំ៧៦ ឬក៏ឆ្នាំ៧៧ ជាដើម។ ខ្ញុំចង់សួរថា តើចំណុចនេះការផ្លាស់ប្តូរនេះដោយសារបញ្ហាអ្វីដែរ? ដោយសារលោកមិនចងចាំ? លោកចាំមិនច្បាស់ ឬក៏មានអ្នកឲ្យយោបល់ទៅលើកាលបរិច្ឆេទនៃសមត្ថកិច្ចរបស់តុលាការនេះ ដែលបញ្ជាក់អំពីសមត្ថកិច្ច យុត្តាធិការពេលវេលាថាកំណត់ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ មករា ១៩៧៩។ ដោយយល់ឃើញថាវាអត់ចូលក្នុងសមត្ថកិច្ច ទើបមានការផ្លាស់ប្តូរ ឬមួយយ៉ាងម៉េច សូមលោកជួយបញ្ជាក់?

[០៩:៤៥:៤៣]

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូននូវសំណួរនេះ។ ខ្ញុំបានបញ្ជាក់ម្តងហើយថា ការធ្វើសំណួរ មូលហេតុ

ដែលប្រែប្រួល ប៉ុន្តែមុននឹងនិយាយខ្ញុំសូមបញ្ជាក់ថា ការពិតគឺវានៅតែការពិត ព្រោះសាច់រឿងវានៅតែរឿងមួយដដែល គ្រាន់តែកាលបរិច្ឆេទអាចនឹងខុសគ្នាខ្លះ។ ប៉ុន្តែត្រង់នេះ ខ្ញុំបានបញ្ជាក់ពីថ្ងៃចូលសវនាការមុននោះ ថ្ងៃមុននោះ ខ្ញុំមិនបានចាំថ្ងៃទេ ខ្ញុំបានប្រាប់ថានៅពេលដែលឆ្លងឯកសារមួយទៅមួយអាស្រ័យដោយខ្ញុំពឹងពាក់គេអ្នកចេះសរសេរបានលឿនទាន់សភាពការណ៍ ហើយខ្ញុំពឹងពាក់គាត់សរសេរឲ្យ ដល់ពេលគាត់យកទៅឲ្យខ្ញុំផ្តិតមេដៃ ខ្ញុំមិនបានពិនិត្យសាច់រឿងថាខុសត្រង់ណា អីត្រង់ណា ខ្ញុំមិនបានពិនិត្យទេ។ ធាតុពិតទៅភាពដើមវានៅតែភាពដើមដដែល ប៉ុន្តែថាការដាក់នេះអ្នក -- ទី១ គឺខាងការចងចាំរបស់ខ្ញុំផ្ទាល់តែម្តង ទី២ គឺខ្វះការប្រុងប្រយ័ត្ន ហ្នឹងសូមសារភាពត្រង់ លោកៗមេធាវីបាទ។ មិនមែនការផ្លាស់ប្តូរអីទេ មិនបានចម្លើយអីអ្នកណាទាំងអស់ ព្រោះខ្ញុំៗមិនមែន ទោះជឿគេយកភាសាយករឿងគេមកនិយាយបានទេ ព្រោះខ្ញុំសូមទោស ខ្ញុំសូមជម្រាបរឿងពិតរបស់ខ្ញុំ គឺខ្ញុំអ្នកកាន់ធម៌បាទ។

[០៩:៤៧:១១]

**ស៖** បាទ សូមអរគុណចំពោះការបំភ្លឺនេះ មូលហេតុដែលខ្ញុំចង់ដឹងនេះ ខ្ញុំយល់ថាអង្គជំនុំជម្រះត្រូវការព័ត៌មានពិតប្រាកដទាក់ទង ជាពិសេសទាក់ទងទៅនឹងការធ្វើពាក្យបណ្តឹងលើកដំបូងរបស់លោកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ។ បញ្ហាវាអាចមានការផ្លាស់ប្តូរ បើសិនជាមានការផ្តល់យោបល់ណាមួយឲ្យលោកកែប្រែពីអ្នកដទៃ ដែលមិនមែនជាអ្វីកើតឡើងដោយសារលោក។ តទៅទៀត ខ្ញុំចង់សួរបញ្ជាក់ទៅលើការប្រើពាក្យរបស់ថា "កំណត់យកកាលបរិច្ឆេទណាមួយ"។ ឧទាហរណ៍កំណត់យកឆ្នាំ១៩៧៤ ជាថ្ងៃដែលឪពុករបស់បាត់ខ្លួន ឬក៏ត្រូវគេនាំខ្លួន ឬក៏ត្រូវគេសម្លាប់។ ខ្ញុំចង់សួរបញ្ជាក់ថា តើពាក្យថា "កំណត់យកនេះ" ជាការកំណត់យកតាមការយល់របស់លោក ឬក៏ជាការដែលលោកបានដឹងបានចងចាំច្បាស់លាស់ សូមលោកជួយបញ្ជាក់?

[០៩:៤៨:២៨]

**ឆ៖** ត្រង់ហ្នឹងខ្ញុំបញ្ជាក់បន្ថែមជាមួយនឹងមុខមេធាវី។ ត្រង់ចំណុចថា មានពេលបរិច្ឆេទខុសគ្នាសរសេរខុសគ្នានេះ ខ្ញុំទទួលស្គាល់។ នៅពេលដែលខ្ញុំ ដាក់សរសេរឡើងចូលក្នុងមជ្ឈមណ្ឌលនេះគឺខ្ញុំនឹកឃើញភ្លាមៗ សរសេរភ្លាម។ ដល់ពេលខ្ញុំយកទៅពិចារណា ខ្ញុំរកមើលថា តើឪពុកខ្ញុំ ម្តាយខ្ញុំស្លាប់នៅពេលណា? ហើយឪពុកខ្ញុំទៅបាត់ចោលគាត់នោះពេលណា? ដល់ខ្ញុំគិតចុះគិតឡើង ថាខ្ញុំប្រៀបធៀបមើលថា ឱកាសនោះក្នុងពេលណា? ជួបអ្វីខ្លះ? ដល់មើលចុះមើលឡើងទៅ ក្នុងឱកាសដែលម្តាយខ្ញុំស្លាប់គឺនៅពេលយន្តហោះបេ-៥២ ទម្លាក់រហូតដល់គាត់ភ័យខ្លាចៗពេក ភ័យរន្ធត់ពេករហូតដល់គាត់

បាត់បង់ជីវិត។ ដល់ខ្ញុំ ពេលដែលខ្ញុំនឹករកបញ្ហាម្ដាយខ្ញុំស្លាប់ មូលហេតុដែលស្លាប់ មូលហេតុអីដែលស្លាប់? មើលចុះមើលឡើង អូ៎ ម៉ែខ្ញុំស្លាប់នៅក្នុងពេលយន្តហោះទម្លាក់គ្រាប់បែក។ ហើយខ្ញុំពិចារណាមើលទៀតថា ក្រោយពេលយន្តហោះ មុនពេលយន្តហោះ -- មុនពេលហ្នឹងតើមានរឿងអីទៀត ដល់មើលចុះមើល អ៎! មុនពេលទម្លាក់គ្រាប់បែកនេះ ឪពុកខ្ញុំត្រូវគេចាប់។ អ៊ីចឹងបូកសរុបទៅចុះឡើងៗ ថាយន្តហោះទម្លាប់នៅថ្ងៃណា? ឆ្នាំណា? បានខ្ញុំនឹកឃើញគឺជាឆ្នាំ៧៤ នេះឯង។ សូមលោកប្រធាន សូមលោកមេធាវីជ្រាបបាទ។

[០៩:៤៩:៥៣]

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ខ្ញុំមានសំណួរចង់បញ្ជាក់ថែមទៀតទៅលើការទម្លាក់គ្រាប់បែក។ អំមិញ លោកបានឆ្លើយថា "ដោយសារម្ដាយរបស់លោកស្លាប់ដោយសារតែភ័យនឹងគ្រាប់បែក៥២ទម្លាក់ពីលើយន្តហោះ" ចំណុចនេះខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ជាគ្រាប់បែក៥២ទម្លាក់ពីលើយន្តហោះ មិនមែនប្រភេទយន្តហោះផ្សេង ឬក៏មិនមែនប្រភេទគ្រាប់បែកផ្សេង?

**ឆ៖** ខ្ញុំថាដឹង មិនថាទេ គឺការដឹង គឺការចងចាំ នៅពេលដែលយន្តហោះទម្លាក់គ្រាប់បែក បើលោកចង់ដឹងថាជាគ្រាប់បែក៥២ ឬក៏គ្រាប់បែកអី? សូមលោកទៅមើលរណ្ដៅនៅក្បែរផ្ទះខ្ញុំ ព្រោះពេលនោះយន្តហោះទម្លាក់កិនខ្ញុំផងដែរ ព្រោះខ្ញុំដេកចាំលាយទ្រូ នៅវាល នៅព្រៃ ម្ល៉ោះហើយយន្តហោះទម្លាក់នៅពេលប៉ះខ្ញុំដែរ។ ម៉ែខ្ញុំក៏ភ័យ ខ្លួនឯងក៏ភ័យ។ អ៊ីចឹងបូកផ្សំការភ័យកន្លងមក ដែលឪពុកខ្ញុំបាត់ផងភ័យរន្ធត់មិនទាន់បាត់ មកជួបរឿងមួយទៀត គឺមកដល់ផ្ទះទៀត យន្តហោះទម្លាក់ពីយប់ ព្រលឹមឡើងម្ដាយស្លាប់ទៀត។ ការរន្ធត់ផ្ទួន។ ហ្នឹងសូមលោកមេធាវីជ្រាប។ អ៊ីចឹងហើយសូមបញ្ជាក់ យន្តហោះខ្ញុំស្គាល់ថាជាគ្រាប់បែក៥២របស់អាមេរិកាំងទម្លាក់នៅព្រៃបឹងខ្មោះ។ សូមជ្រាបបាទ ស្គាល់ទាំងព្រៃ បើលោកក្នួយទៅមើលឃើញហើយ ជួបគ្រាប់នៅ។

[០៩:៥១:៤៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ថា ចំណុចសំខាន់ លោកអាចរៀបរាប់ពីរណ្ដៅ ទំហំរណ្ដៅដែលទម្លាក់នៅជិតផ្ទះហ្នឹង ជិតផ្ទះលោកបានទេ?

**ឆ៖** ខ្ញុំអាចបញ្ជាក់បាន ទំហំនៃគ្រាប់បែក ប៉ុន្តែចំនួនខ្ញុំមិនអាចបកស្រាយឲ្យបានទេ បានច្បាស់ទេ ប៉ុន្តែគ្រាន់តែដឹងថាមាន។ រណ្ដៅមិនតិចជាង១០០ទេ ព្រោះវាទម្លាក់ម្ដងអស់ចម្ងាយមួយគីឡូដី ឬមួយគីឡូជាង។ អ៊ីចឹងរណ្ដៅ វាដែលឃើញរូបភាពជាក់ស្ដែង បើគ្រាប់ បើកន្លែងណាវាបាក់ដីហើយ

ក្លាយទៅជា២០ម៉ែត្រក៏មាន ៥០ម៉ែត្រក៏មាន។ តែភាគច្រើនឃើញ អន្លង់ភាគច្រើនគឺ២០ម៉ែត្រ ហើយជម្រៅវាមានដល់ប្រាំពីរ ឬប្រាំបីម៉ែត្រ។ មានដល់១០ម៉ែត្រ មានក្រោយ -- មានក្រោម១០ម៉ែត្រ។ ហ្នឹង សូមលោកមេធាវី ជ្រាបបាទ។

**ស៖** បាទសូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ខ្ញុំបាទសុំសួរបន្ថែមទៅលើចំណុចទាក់ទងទៅនឹងតួនាទីរបស់លោកក្នុងឋានៈជាប្រធានសិស្សពេទ្យ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោកអាចបញ្ជាក់បានទេថា លោកមានភារកិច្ច ឬអំណាចអ្វីខ្លះក្នុងឋានៈជាប្រធានសិស្សពេទ្យជំនាន់នោះ?

**ឆ៖** នៅក្នុងតំបន់២០ ខ្ញុំមាននាទីមួយសំខាន់ គឺមុនមករៀន និងក្រោយទៅរៀន ខ្ញុំមាននាទីមួយ គឺប្រធានបច្ចេកទេសសម្រាប់ហ្វឹកហ្វឺនបុគ្គលិកដែលត្រូវធ្វើពេទ្យនៅតំបន់២០។ ក្នុងនោះដែល ខ្ញុំបាទជាប់ជាសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា។ ដូច្នេះឯងហើយ បានខ្ញុំមានឋានៈហ្នឹងបាទ។ សូមជ្រាបបាទ។

[០៩:៥៤:៣៥]

**ស៖** បាទ សូមអគុណ។ អំមិញខ្ញុំ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងអំពីតួនាទី ភារកិច្ច ឬក៏អំណាចរបស់លោក សិទ្ធិអំណាចរបស់លោកក្នុងឋានៈជាប្រធានសិស្សពេទ្យ។ សូមលោកជួយបញ្ជាក់ថា តើលោកមានអំណាចចាត់ចែងគ្រប់គ្រង ឬក៏ដាក់វិន័យអីជាដើមយ៉ាងដូចម្ដេចដែរក្នុងសម័យនុ៎ង?

**ឆ៖** សំណួរនេះ ខ្ញុំបានឆ្លើយអំមិញថា ខ្ញុំមាននាទីមួយគឺមើលសិស្ស អប់រំសិស្សពីការរស់នៅ និងការហូបចុក និងការរៀនសូត្រ។ នាទីចាត់ចែងលើសពីនេះ លុះត្រាតែប្រធានមន្ទីរពេទ្យគេអនុញ្ញាត ឬប្រើបានខ្ញុំធ្វើ បានធ្វើ បើគេមិនប្រើខ្ញុំអត់មានសិទ្ធិធ្វើទេបាទ។

**ស៖** បាទ សូមអរគុណ។ បើខ្ញុំយល់មិនច្រឡំទេ ការឆ្លើយរបស់លោកកន្លងមកថា និស្សិត -- សិស្សពេទ្យដែលមករៀនក្នុងជំនាន់របស់លោកហ្នឹង គឺមានរហូតដល់ទៅប្រហែល ២.០០០នាក់ តើត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំសូម -- មិនមែនកែសម្រួល សូមបញ្ជាក់ពាក្យ។ អាត្រង់ហ្នឹងខ្ញុំនិយាយពីរដង ម្ដងនោះប្រហែលជា២.០០០នាក់ នៅពេលដែលខ្ញុំទៅរៀននយោបាយ។ ដល់ពេលរៀនពេទ្យគឺខ្ញុំនិយាយថាប្រហែលជា១.០០០ ឬក្រោម ១.០០០ សូមលោកមេធាវីមើលឯកសារខ្ញុំនិយាយបាទ។

[០៩:៥៦:៥៣]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់បន្ថែមថា ក្នុងចំណោមសិស្សពេទ្យទាំងអស់ ដែលលោកមានប្រសាសន៍ថា អាចមានចំនួនប្រហាក់ប្រហែល១.០០០ ឬក្រោម ១.០០០នេះ តើមានតែម្នាក់

ទេដែលជាប្រធានសិស្សនោះ? ហើយម្នាក់នោះគឺជារូបលោក អត់មានអ្នកផ្សេងទៀតទេ?

**ឆ៖** ក្នុងហ្នឹងតាមខ្ញុំចាំបាន មានបីនាក់ ប្រធាន អនុ និងសមាជិក។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ឲ្យហើយថា ខ្ញុំមិនដឹងថាគេនៅទីណាទេ ឯឈ្មោះគេក៏ខ្ញុំមិនបាននឹកឃើញដែរបាទ។ សូមបញ្ជាក់ឲ្យហើយ កុំឲ្យសួរទៀត។

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់និយាយពីលោកផ្ទាល់ ទាក់ទងទៅនឹងការចូលរួមវគ្គហ្វឹកហ្វឺន ឬក៏វគ្គរៀនសូត្រនយោបាយ ដែលលោកបានចូលរួម។ ខ្ញុំចង់សួរថា តើលោកបានចូលរួមពេញរាល់ថ្ងៃទាំងអស់នៅក្នុងវគ្គរៀនសូត្រនយោបាយដែរឬទេ? ឬមួយក៏លោកបានចូលរៀនតែក្នុងកម្រិតណាមួយដោយមានអវត្តមានចំពោះថ្ងៃណាខ្លះ? សូមលោកជួយបញ្ជាក់។

[០៩:៥៨:៥៣]

**ឆ៖** ខ្ញុំសូមបញ្ជាក់លោកមេធាវី។ ក្នុងការសិក្សារបស់ខ្ញុំ រយៈពេលពេលនោះ គឺខ្ញុំមានពេលរៀន៧ថ្ងៃ ប៉ុន្តែដោយកាតព្វកិច្ចរបស់ខ្ញុំត្រូវការសិក្សា និងមើលជំងឺច្រើននៅក្នុងមន្ទីរពេទ្យ លោកប្រធានបាន -- មន្ទីរពេទ្យគេបានកោះហៅ និងសុំខ្ចីសាលា -- សុំសិស្សនយោបាយមកវិញ ដើម្បីជួយបំពេញកាតព្វកិច្ចនៅក្នុងមន្ទីរពេទ្យ។ ដូច្នេះខ្ញុំរៀនបានតែ៤ថ្ងៃទេ បាទលោកប្រធាន។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមឲ្យបញ្ជាក់មកវិញថា វគ្គរៀនសូត្រនយោបាយដែលលោកបានចូលនៅពេលនោះ បានចូលរៀននៅពេលនោះ គឺមានតែ៧ថ្ងៃទេ ហើយៗលោកបានរៀនជាក់ស្តែងតែ៤ថ្ងៃទេ។ លោកអាចបញ្ជាក់បានទេថា តើ៤ថ្ងៃដែលលោកបានចូលរៀនហ្នឹង ជាថ្ងៃដំបូង ឬក៏ជាថ្ងៃចុងក្រោយ ឬក៏ជាកណ្តាល? សូមលោកជួយបញ្ជាក់។

[១០:០០:១៩]

**ឆ៖** ខ្ញុំសូមបញ្ជាក់ប្រាប់ថា ខ្ញុំចូលរៀន គឺជាថ្ងៃដំបូង។

**សៈ** អ៊ីចឹងមានន័យថា៤ថ្ងៃដំបូង មែនទេលោក?

**ឆ៖** បាទៗ។

**សៈ** អ៊ីចឹង ខ្ញុំចង់បញ្ជាក់ទៅលើប្រតិចារឹកដែលមាននៅក្នុងឯកសារ D22/3963 ដែលជាកំណត់ហេតុលោកបានឆ្លើយក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងជម្លួមណ្ឌលឯកសារកម្ពុជា។ លោកបានបញ្ជាក់ថា "លោក នួន ជា និយាយប្រហែល៣ថ្ងៃ និងលោក ខៀវ សំផន និយាយចាប់ពីថ្ងៃទី៤ ឬក៏ទី៥"។ អ៊ីចឹង ចំណុចនេះ ខ្ញុំចង់សួរបញ្ជាក់ថា លោកដឹងថាលោក ខៀវ សំផន និយាយយ៉ាងដូច

ម្តេចកើត បើលោកអត់បានចូលរួមនៅថ្ងៃចុងក្រោយផង?

[១០:០៣:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនៅក្នុងសំណួរនោះ ការបកប្រែសំណួរអម្បាញ់មិញនេះ គឺថា ខៀវ សំផន ធ្វើបទឧទ្ទេសនាមនៅថ្ងៃទី៥ តែប៉ុណ្ណោះ។ ខ្ញុំមិនដឹងថាលោកមេធាវី ខៀវ សំផន បាននិយាយអ៊ីចឹង ឬក៏យ៉ាងណាទេ។ ក៏ប៉ុន្តែនៅក្នុងការបកប្រែជាភាសាអង់គ្លេសនោះឮនិយាយយ៉ាងដូច្នេះ។ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកសាក្សី គឺថា "គាត់ឃើញ គាត់និយាយថាថ្ងៃទី៣ ថ្ងៃទី៤ គាត់បានឃើញលោក ខៀវ សំផន"។ ខ្ញុំមិនដឹងថាមានបញ្ហាការបកប្រែ ឬបញ្ហារបស់មេធាវីនោះទេ។ ក៏ប៉ុន្តែនៅក្នុងឯកសារ D22/3963 គឺថាមាន -- គឺថានៅថ្ងៃទី៤ និងថ្ងៃទី៥ ដែលលោកសាក្សីនេះឃើញលោក ខៀវ សំផន។ អ៊ីចឹងសូមឲ្យលោកមេធាវីរបស់លោក ខៀវ សំផន បញ្ជាក់សំណួរឡើយវិញ។

[១០:០៤:១៣]

**លោក គង់ សំអុន៖**

សូមអរគុណតំណាងសហព្រះរាជអាជ្ញា។ ខ្ញុំបានបញ្ជាក់រួចហើយ ហើយខ្ញុំគិតថាសាក្សីអាចឆ្លើយសំណួរនេះបាន ព្រោះខ្ញុំបាននិយាយច្បាស់ ដូចអ្វីលោកមានប្រសាសន៍អំមិញអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរ -- ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរ ដែលសួរឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់សំណើទៅលោកមេធាវីអ្នកតាំងសំណួរ។ សូមអធ្យាស្រ័យបញ្ហាដែលខ្ញុំបាននិយាយអម្បាញ់មិញ ប៉ុន្តែខ្ញុំផ្អែកទៅលើ មិនមែនផ្អែកទេ រឿងពិតរបស់ខ្ញុំអ៊ីចឹង។ មុននឹងនិយាយបាន ខ្ញុំបាទបានសូមទោសទុកជាមុនថា ការចងចាំមិនមែនដូចការថតទុក ហើយក៏មិនមែនដូចការសរសេរទេ ដូច្នេះអាចនឹងមានមុន ឬមានក្រោយ។ អ៊ីចឹងសូមលោកមេធាវី គួរតែទទួលស្គាល់ថាឱកាសនោះ ខ្ញុំជាអី? តើខ្ញុំស្ថិតនៅជាអ្នកណា? ហើយដល់ថ្ងៃនេះគឺខ្ញុំជាស្អី? អ៊ីចឹងសូមលោកមេធាវី

មេត្តាមើលឲ្យច្បាស់ថា ខ្ញុំបច្ចុប្បន្ននេះអាយុ៦០ តែពីពេលនោះ ខ្ញុំនៅអាយុប្រហែលជាជាង១០ឆ្នាំ ឬក្រោម២០ឆ្នាំ។ អ៊ីចឹងសូមលោកមេធាវីគួរអនុគ្រោះ ព្រោះខ្ញុំជួបការលំបាកច្រើនណាស់។ ដូច្នេះការចងចាំប្រហែលមិនអស់ទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ សំណួរបន្ត ខ្ញុំចង់សួរលោកថា តើលោកបានស្គាល់នរណាខ្លះ ដែលបានរៀនវគ្គនយោបាយជាមួយលោកនៅពេលនោះ ដែលលោកអាចចងចាំ ហើយជម្រាបជូនអង្គជំនុំជម្រះបាននៅពេលនេះ?

**ឆ៖** សូមៗសួរម្តង -- ខ្ញុំសូមសួរត្រង់ថា សួរថា ចងចាំហ្នឹង ចងចាំលោកគ្រូ ឬក៏ចងចាំសិស្សដូចគ្នាបាទ?

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់អ្នកដែលទៅរៀនជាមួយលោកនោះ ជាៗសិស្សទៅរៀនវគ្គនយោបាយ -- រៀនសូត្រវគ្គនយោបាយជាមួយលោក?

**ឆ៖** សូមបញ្ជាក់ជូនលោកមេធាវី ក្នុងចំណុចនេះ បើនិយាយការចងចាំ នៅពេលនោះផ្ទាល់តែម្តង ចូលៗទៅរៀននោះ ខ្ញុំមិនបានស្គាល់ពីណា ថាអ្នកណាឈ្មោះអី អ្នកណាឈ្មោះអីទេ។ អ៊ីចឹងបូកផ្សំមកដល់បច្ចុប្បន្ននេះទៀត ខ្ញុំវែកផងនោះ អាចនឹងមិន -- តែខ្ញុំចាំបាន ក្នុងឱកាសនោះចាំបានមនុស្សម្នាក់ដែលត្រូវជាឪពុកមារបស់ខ្ញុំនៅតំបន់២០ បានមករៀនដែរ ព្រោះគាត់មាននាទីជាប្រធានតំបន់២០ គឺតាគង់ សុគន្ធ ហៅទុយ ឈ្មោះដើមរបស់គាត់ហៅ ម៉ុក។ ហ្នឹងសូមជ្រាបបាទ។

[១០:០៨:១៤]

**ស៖** បាទ សូមអរគុណ។ លោកមានចាំអ្នកណាផ្សេងទេ នៅដែលមកពីតំបន់២០ លោកធ្លាប់រស់នៅទីនោះ?

**ឆ៖** ខ្ញុំមិនអាចចាំបានទេឈ្មោះ ខ្ញុំគ្រាន់តែដឹងថា ថ្នាក់គាត់នោះគឺឡើងទៅរៀនស្គាល់ឪពុកមាខ្ញុំដោយសារឪពុកមាផង។ អ៊ីចឹងសូមលោកមេធាវីមេត្តាអធ្យាស្រ័យបាទ។

**ស៖** បាទ សូមអរគុណ។ ឪពុកមារបស់លោកឈ្មោះ គង់ សុគន្ធ ហ្នឹងគាត់នៅមានជីវិតទេសព្វថ្ងៃហ្នឹង?

**ឆ៖** បាទ គាត់ស្លាប់បាត់បង់ជីវិតដោយសារ ប៉ុល ពត សម្លាប់បាត់តាំងពីមុន -- ក្រោយឆ្នាំ -- មើល៍ ខ្ញុំមិនដឹងថាស្លាប់ពេលណា ប៉ុន្តែដឹងថាគាត់ចាប់ដោយសារ ប៉ុល ពត សម្លាប់នៅឆ្នាំ៧៦ ឬក្រោយ

ឬដើមឆ្នាំ៧៧ បាទ។

[១០:០៩:៤៨]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមត្រឡប់ទៅចំណុចមួយ ដែលយើងបានពិភាក្សារួចហើយ ទាក់ទងទៅនឹងការទម្លាក់គ្រាប់បែក ហើយនៅពេលដែលលោកមានប្រសាសន៍ថា ម្ដាយរបស់លោកបានស្លាប់ដោយសារតែភ័យ នឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំង។ ហើយលោកបានចាំថា វាជាឆ្នាំ ១៩៧៤។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់អំពីព័ត៌មានផ្ទុយគ្នាមួយ ទាក់ទងទៅនឹងមរណភាពរបស់ម្ដាយរបស់លោកនេះ ដែលមាននៅក្នុងឯកសារ D22/3963។ ERN ជាភាសាខ្មែរ គឺលេខ 00786184 អ៎ សូមទោស ភាសាខ្មែរ 5730 -- 00573974 អ៎ សូមទោស 75 ត្រឡប់មួយទំព័រ។ សូមអធ្យាស្រ័យដោយសារខ្ញុំកិបវាបាត់លេខ។ ជាភាសាអង់គ្លេស 00751866, ជាភាសាបារាំង 00786184។

[១០:១២:០៥]

ខ្ញុំសូមអានជូនចំពោះវគ្គពាក់ព័ន្ធ។ លោកបានឆ្លើយថា “ឯម្ដាយខ្ញុំបាទត្រូវពួក ប៉ុល ពត ចាប់សម្លាប់តាំងពីឆ្នាំ ដែលឪពុកខ្ញុំត្រូវបានពួក ប៉ុល ពត ចាប់គាត់ យកទៅសម្លាប់ គឺចាប់យកពួកនេះចាប់កាត--” ខ្ញុំសូមអានតាមអក្សរ ព្រោះខ្ញុំអានអត់ដាច់។ “ចាប់កាតយកចេញពីវត្ត ដែលគាត់កំពុងធ្វើធម៌។ វត្តនោះ គឺវត្តព្រៃព្រះស្មោន នៅសព្វថ្ងៃនេះ”។ តើលោកចាំថា នេះជាសំណេររបស់លោកទេ? ហើយតើលោកអាចពន្យល់បានដូចម្ដេចចំពោះព័ត៌មានផ្ទុយគ្នា ដែលលោកបានឆ្លើយអម្បាញ់មិញ និងអ្វីដែលមាននៅក្នុងឯកសាររបស់លោកពីមុនមកនោះ?

**ឆ៖** ខ្ញុំត្រូវទទួលស្គាល់សំណេរដែលខ្ញុំបានសរសេរទុករួចទៅហើយ។ ប៉ុន្តែខ្ញុំសូមរំឭកលោកម្ចាស់សំណួរ ដែលបានសួរមក សូមរំឭកឡើងវិញថា ថ្ងៃនេះ ក៏ដូចជាថ្ងៃដែលសរសេរ ព្រោះខ្ញុំឥឡូវហាក់ដូចជាមានការភ្លេចភ្លាំងច្រើន។ ដូច្នេះ សូមលោកមេធាវីមេត្តាអធ្យាស្រ័យក្នុងបញ្ហានេះ។ ប៉ុន្តែក្នុងសាច់រឿងនេះ ពិតជាមានអ៊ីចឹងមែន។ យ៉ាងណាមិញ ខ្ញុំសូមពន្យាល់បន្តិចថា ដូចជាឪពុកចាប់នៅថ្ងៃ -- បាទ សូមអានបន្តិចឡើងវិញសិន ដើម្បីបញ្ជាក់ នៅព្រៃស្មោន រស់នៅសព្វថ្ងៃ វត្តដែលគាត់រស់នៅ។ ទីវត្ត ខ្ញុំសូមបញ្ជាក់ដល់លោកមេធាវី ធាតុពិត សាសនាវាត្រូវបាត់បង់ ដល់ខ្ញុំនិយាយវាបែរទៅជាមានអ៊ីចឹង សូមលោកមេធាវីទទួលស្គាល់ថា ខ្ញុំមានភាពភ្លេចភ្លាំងច្រើន។ ដូច្នេះទាំងអស់នេះ ខ្ញុំសូមទទួលថាពិតជាខ្ញុំសរសេរខុសមែនបាទ។

[១០:១៤:២៩]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកបដិសេធចំពោះសំណេរដែលមាននៅក្នុងឯកសារ D22/3963 នេះ ថាវាមិនត្រឹមត្រូវទេ។ ហើយលោកទទួលយកថា ម្ដាយរបស់លោកគឺស្លាប់ដោយសារការភ័យ នឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំង នៅឆ្នាំ១៩៧៤។ អ៊ីចឹងមែនទេ?

**ឆ៖** ហ្នឹងទទួលស្គាល់បាទ។

**លោក គង់ សំអុន៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអរគុណក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំបាទអស់សួរទៀតហើយ។ សូមអរគុណ។

[១០:១៥:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ អរគុណដើមបណ្ដឹងរដ្ឋប្បវេណី។

លោក អែម អឿន ឥឡូវនេះការតាំងសំណួរដេញដោល ចំពោះលោកហ្នឹងបានចប់ហើយ ប៉ុន្តែមុននឹងចប់ហ្នឹង អង្គជំនុំជម្រះផ្តល់ឱកាសឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខវេទនា និងស្ថានភាពព្យសនកម្ម ដែលមានចំពោះលោក ដូចជាអាទិ៍ ការខូចខាតផ្លូវចិត្ត រូបកាយ ឬសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលបានកើតមានពិតប្រាកដរហូតមកដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ទាំងបីរូប នួន ជា, អៀង សារី, ខៀវ សំផន ដែលប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១ គឺការកើតមាននៅក្នុងដំណាក់កាលជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទី២ គឺបើគិតពីពេលវេលា គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ដំណាច់ឆ្នាំ១៩៧៦។ ប្រសិនបើមាន លោកមានបំណងធ្វើដូច្នេះ គឺលោកអាចថ្លែងរៀបរាប់ជូនអង្គសវនាការបាន។

[១០:១៧:១៦]

**លោក អែម អឿន៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំនិយាយពីបញ្ហានេះ ខ្ញុំសូមសិទ្ធិលោកប្រធាន សុំសិទ្ធិ សុំ

អភ័យទោស និងសុំសិទ្ធិនិយាយអ្វីទាំងអស់ មុននឹងខ្ញុំថ្លែងអំពីបញ្ហានេះ សូមសិទ្ធិថា សុំសិទ្ធិនិយាយស្ដីអំពីបញ្ហាដែលខ្ញុំត្រូវរៀបរាប់។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតហើយ មានសុំអីទៀត ព្រោះអង្គជំនុំជម្រះផ្ដល់សិទ្ធិឲ្យលោកហើយ។ គ្រាន់តែឲ្យលោកកំហិតនូវអ្វីដែលកើតមានឡើងចំពោះលោក ទី១ គឺរឿងផ្ទាល់ខ្លួនរបស់លោក ទី២ កើតឡើងហ្នឹងវារហូត មានរហូតជាប់ជាៗ រហូតដល់ពេលបច្ចុប្បន្ននេះចំពោះលោក។ ទី២ បញ្ហាហ្នឹងកើតឡើងពាក់ព័ន្ធនឹងអង្គហេតុ ដែលចោទប្រកាន់ចំពោះជនជាប់ចោទ តែចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ដំណាច់ឆ្នាំ១៩៧៦ ប៉ុណ្ណោះ ឬយ៉ាងយូរបំផុតគឺ ខែ១ ខែ២ ខែ៣ ឆ្នាំ១៩៧៧ ព្រោះយើងនិយាយខែមករា ខែកុម្ភៈ ខែមីនា ក្រែងលោលោកមិនចេះ ព្រោះលោកបានឆ្លើយម្សិលមិញថា លោកមិនចេះខែរបៀបនេះទេ លោកចេះតែខែ១ ខែ២ ខែ៣។ នេះយើងឲ្យលោកកំហិតប៉ុណ្ណឹង ហើយលោកអាចរៀបរាប់បានអំពីទុក្ខវេទនា អំពីការខូចខាតផ្លូវចិត្ត រូបរាងកាយ ឬក៏សម្ភារៈ។

[១០:១៨:៤២]

**លោក អែម អឿន៖**

អរគុណលោកប្រធាន។ មុននឹងនិយាយ ខ្ញុំសូមអរគុណ អរគុណដល់ -- ខ្ញុំបាទសូមអរគុណដល់ដំណើរការនៃតុលាការនេះ។ នៅការថ្លែងអំណរគុណនេះ ខ្ញុំសូមមុននឹងនិយាយថ្លែងអំណរគុណ ខ្ញុំបាទសូមនិយាយអំពីលទ្ធភាព ដែលខ្ញុំធ្វើបាន។ ខ្ញុំសូមអរគុណដល់តុលាការ ដ៏វិសេសនេះ ព្រោះក្នុងជីវិតរបស់ខ្ញុំមិនស្មានថាបានឃើញបញ្ហានេះកើតឡើងដល់ខ្ញុំឡើយ។ នេះបញ្ហានេះ គឺតុលាការនេះពិសេសណាស់ក្នុងការវែកញែករកត្រូវ និងខុស ការពិតហៅថា រកយុត្តិធម៌។ អ៊ីចឹង ខ្ញុំសូមអរគុណណាស់ ទាំងបងប្អូនជាជនជាតិខ្មែរ និងទាំងបងប្អូននៅបរទេសដែលបានមក កាន់នៅតុលាការនេះ បានន័យថា ខ្ញុំមានសំណាងល្អណាស់នៅក្នុងវិស័យនេះ ក្នុងជាតិនេះតែម្ដង ព្រោះខ្ញុំមិនដែលឡើងបានដល់កន្លែងនេះទេ។ ដូច្នេះ សូមអរគុណទាំងលោកតុលាការ សូមអរគុណទាំងអ្នកធ្វើការនៅក្នុងទីនេះទាំងអស់ ទាំងជាតិ និងអន្តរជាតិ និងសូមអរគុណដល់បងប្អូនទាំងអស់ ដែលជាប្រជាពលរដ្ឋខ្មែរ ដែលបានមកផ្ទាល់មកឃើញផ្ទាល់ មកស្ដាប់ផ្ទាល់នៅទីនេះ។

[១០:១៩:៤៤]

អ៊ីចឹងដំណើរការដែលខ្ញុំត្រូវការនិយាយ ខ្ញុំសូមអភ័យទោសទុកជាមុន ទោះបីការនិយាយយ៉ាង -

- និយាយលំបាកលំបិនយ៉ាងណាក៏ដោយ ខ្ញុំសូមបញ្ជាក់ទុកជាមុនថា នោះខ្ញុំមានជំងឺមួយគឺនៅបំពង់ក ដូច្នេះហេតុផលទាំងអស់នេះទើបវាធ្វើឲ្យខ្ញុំនិយាយហាក់ដូចជាខ្ញុំមានការភ័យព្រួយ។ ប៉ុន្តែបំណងនេះគឺជាបំណងដ៏ស្រួចស្រាល់បំផុត ទោះបីខ្ញុំបានសំណាងពីអ្នកកសាងអំពើអាក្រក់ក៏ដោយ មិនបានក៏ដោយ ឲ្យតែខ្ញុំមកឡើងដល់កន្លែងនេះ ការថ្លែងពាក្យពិតរបស់ខ្ញុំនេះ គឺខ្ញុំបានន័យថាខ្ញុំអស់ៗមានការចោទប្រកាន់គេ អស់មានការសង្ស័យលើគេហើយ ព្រោះថាមូលហេតុម៉េច? គឺខ្ញុំសូមមកសម្តែងការពិត បើសិនខ្ញុំមិនដាក់ពាក្យចូលមកបញ្ហានេះទេ ខ្ញុំពិតជាមិនបានចូលមកនិយាយរឿងទាំងអស់ដែលដឹងឮឡើយ។ ដូច្នេះ ខ្ញុំសូមថ្លែង -- ខ្ញុំសូមនិយាយពីរឿងពិត និងការចង់បានរបស់ខ្ញុំផ្ទាល់។

អស់លោក លោកស្រី បងប្អូនជនរួមជាតិជាទីគោរព! ខ្ញុំឱកាសនេះគឺខ្ញុំបាទសូមតែនិយាយពីរឿងពិតៗ ដែលកើតឡើងពីព្រឹត្តិប័ត្រ ពីព្រឹត្តិការណ៍ដែលកើតឡើងចំពោះរូបខ្ញុំផ្ទាល់។ អ៊ីចឹង អ្វីក៏ដោយ ខ្ញុំសូមនិយាយអំពីបញ្ហាដែលខ្ញុំបាទត្រូវជួប ទោះបីការជួបនេះដូចគ្នានឹងបងប្អូនក៏ដោយ មិនដូចក៏ដោយ ខ្ញុំចាត់ទុកថា គេហៅថា រឿងរ៉ាវទាំងអស់ដែលកើតឡើងក្នុងអំឡុងនោះ គឺខ្ញុំយល់បានច្បាស់ថាពិតជាកើតដូចៗហ្នឹងខ្ញុំដែរ។ ដូច្នេះ ខ្ញុំសូមនិយាយអំពីបញ្ហាទាំងអស់នោះ ព្រោះមុននឹងនិយាយខ្ញុំបាទ សូមនិយាយឲ្យបងប្អូននិយាយដឹងជាមុន មុននឹងនិយាយ ខ្ញុំសូមនិយាយរឿងពិតដែលមានព្រះសេអាមេត្រីនៅខាងមុខ។

[១០:២១:២៥]

ដូច្នេះ សូមយកព្រះជាសាក្សីក្នុងការនិយាយស្តីរបស់ខ្ញុំ បើសិនជានិយាយខុសរឿង សូមព្រះអង្គកុំឲ្យខ្ញុំបើកមាត់រួចឲ្យសោះ ខ្ញុំសូមព្រះអង្គទទួល។

អ៊ីចឹងបងប្អូនទាំងអស់សូមជ្រាបដំណើរខ្ញុំនេះ ខ្ញុំសូមរៀបរាប់បញ្ហាខ្លះដែលខ្ញុំបានជួបប្រទះ។ តាំងពីតូចក្រូចឆ្មារមកដល់ខ្ញុំប៉ុណ្ណេះ មិនស្គាល់ទេសាលារៀន ខ្ញុំស្គាល់តែការលំបាក គឺកិច្ចការរបស់ខ្ញុំធ្វើជួសឪពុក ជួសម្តាយផង ជួសបង ជួសប្អូនផង រហូតដល់ខ្លួនឯងមិនបានរៀន។ ដូចក្នុងផ្ទាំងឯកសារដែលខ្ញុំបានសរសេរទុកនេះ គឺមិនបានរៀននេះឯង ន័យនេះមិនខ្ញុំសរសេរឲ្យពីរោះស្តាប់ទេ។ ធាតុពិតគឺខ្ញុំនិយាយអំពីសាច់រឿងរបស់ខ្ញុំផ្ទាល់តែម្តង ការផ្ទាល់នេះវាពាក់ព័ន្ធ--

**ប្រធានអង្គជំនុំ៖**

លោក អែម អឿន យើងឲ្យអនុញ្ញាតឲ្យលោកនិយាយថ្លែងអំពីទុក្ខសោកដែលលោកជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាយ៉ាងម៉េចដែរ? ហើយអន្តរាយជាក់ស្តែងដែលលោកកើតមានហ្នឹង

វាកើតមានបញ្ហាអីខ្លះ ដែលកើតមានចំពោះលោកនាំឲ្យលោកមានការកើតទុក្ខសោកវេទនាដូច្នេះ? មិនមែនឲ្យលោកព្រោកអីចឹងទេ។ យើងឲ្យលោក៥នាទី ដើម្បីថ្លែងឲ្យចំបញ្ហា។ ប្រសិនបើលោកមិនចង់ថ្លែងក៏បានដែរ ព្រោះសិទ្ធិរបស់លោក។

**លោក អែម អឿន៖**

សូមអរគុណលោកប្រធាន។ បាទ បញ្ហានេះដើម្បីកុំឲ្យវែងឆ្ងាយ ខ្ញុំបាទសូមអស់យោបល់។

**ប្រធានអង្គជំនុំ៖**

អរគុណលោក អែម អឿន។ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន របស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះអរគុណចំពោះលោក ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះជាច្រើនថ្ងៃកន្លងមកនេះ ដោយបានអត់ធ្មត់និងខិតខំអស់ពីសមត្ថភាពក្នុងការផ្តល់សក្ខីកម្ម។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ សូមលោកជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១០:២៥:១១]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏កន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅវិញបានហើយ។ ហើយលោក អែម អឿន អាចចាកចេញត្រឡប់ទៅវិញបានហើយ។

ហើយកិច្ចដំណើរការសវនាការជាបន្តនៅម៉ោងក្រោយនេះ នឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-480 ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្តីបន្ទាប់ពីសំណួរបឋមរបស់អង្គជំនុំជម្រះ។ សូមភាគីនិងសាធារណជនជ្រាប។

ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៥ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-480 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៥៦:៣៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកមានឈ្មោះអ្វី?

**លោក នង សុផង់៖**

**ផ៖** សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ នង សុផង់។

**ស៖** បាទ អរគុណ។ ហើយលោក នង សុផង់ ក្រៅពីឈ្មោះ សុផង់ ហ្នឹងលោកធ្លាប់ប្រើប្រាស់ឈ្មោះអ្វីផ្សេងពីនេះដែរឬទេ?

**ផ៖** បាទ ឈ្មោះដើមរបស់ខ្ញុំឈ្មោះ នង សេងជីម ឈ្មោះហៅក្រៅគ្មានទេបាទ។

**ស៖** បាទ អរគុណ។ ហើយបច្ចុប្បន្ននេះគឺលោកប្រើប្រាស់ឈ្មោះអ្វីនៅជាផ្លូវការ ក្នុងការៗរស់នៅសព្វថ្ងៃនេះ?

[១០:៥៧:៤៥]

**ផ៖** បាទ ឈ្មោះជាផ្លូវការរបស់ខ្ញុំគឺ នង សុផង់ បាទ។

**ស៖** បាទ អរគុណ។ ហើយលោក នង សុផង់ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថាតើលោកមានថ្ងៃខែឆ្នាំកំណើតហ្នឹង កើតថ្ងៃខែណាដែរ? ឬក៏អាយុប៉ុន្មានដែរ?

**ផ៖** បាទ ខ្ញុំកើតនៅថ្ងៃទី០២ ខែមករា ឆ្នាំ១៩៥២ អាយុ៦០ឆ្នាំបាទ។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះ តើលោករស់នៅទីកន្លែងណា?

**ផ៖** បាទ ខ្ញុំអាសយដ្ឋានរបស់ខ្ញុំគឺ ភូមិដីក្រហម ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង បាទ។

**ស៖** បាទ អរគុណ។ ហើយតើសព្វថ្ងៃនេះលោកប្រកបមុខរបបរកស៊ីធ្វើអ្វី?

**ឆ៖** បាទ ខ្ញុំជាគ្រូបង្រៀនចូលនិវត្តន៍បាទ។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកគាត់ឈ្មោះអ្វី?

**ឆ៖** ឪពុករបស់ខ្ញុំឈ្មោះ នង ជឹម។

**ស៖** បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោក?

**ឆ៖** ម្ដាយខ្ញុំឈ្មោះ អ៊ុន ទឹត។

**ស៖** បាទ អរគុណ។ ហើយប្រពន្ធរបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទ ឈ្មោះ ញ៉ើក ហំ។

**ស៖** បាទ អរគុណ។ ហើយលោកមានកូនប៉ុន្មាននាក់?

[១១:០០:០៣]

**ឆ៖** បាទ មានបីនាក់បាទ។

**ស៖** បាទ អរគុណ។ ហើយលោក នង សុផង់ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ គាត់រាយការណ៍កាលពីម្សិលមិញថា តាមសមត្ថភាពដែលលោកដឹង លោកមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបដែរ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** ហើយតាមរបាយការណ៍ដដែលនេះ គឺក្រឡាបញ្ជីបានរាយការណ៍ថាលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយ កាលពីម្សិលមិញ។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែន។

[១១:០១:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះគឺអង្គជំនុំជម្រះប្រាប់អំពីសិទ្ធិ និងករណីកិច្ចក្នុងនាមលោកជាសាក្សី។ លោក នង សុផង់ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំ

ឱ្យដាក់ពិរុទ្ធភាពលោកខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឱ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សី លោកត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ ដោយត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះបានសួរចំពោះលោក លើកលែងតែសំណួរ ឬអំណះអំណាងណាដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់ខាងលើអម្បាញ់មិញនេះ។ ហើយលោកជាសាសក្សីត្រូវតែនិយាយតែការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬក៏ចៅក្រមអង្គជំនុំជម្រះសួរលោក។

[១១:០២:២៧]

តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីដែរឬទេ ដែលយើងបានជម្រាបលោកអម្បាញ់មិញនេះ?

**លោក នង សុផង់៖**

បាទ ខ្ញុំយល់បាទ។ សូមអរគុណបាទ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក នង សុផង់ តើលោកដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើធ្លាប់ តើការធ្វើសម្ភាសន៍នោះប្រព្រឹត្តនៅ ទៅប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? ហើយនៅពេលណា?

**លោក នង សុផង់៖**

**ឆ៖** បាទ អ្នកស៊ើបអង្កេតបានធ្លាប់ទៅសម្ភាសខ្ញុំពីរដងបាទ គឺនៅក្នុងសាលាបឋមសិក្សា ហ៊ុនសែន អូរអន្លក់ ក្នុងអំឡុងឆ្នាំ២០០៩ បាទ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬក៏អាននូវកំណត់ហេតុដែលលោកផ្តល់សក្ខីកម្ម ដែលលោកធ្លាប់បានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលោកបានឆ្លើយអំមិញនេះថាធ្វើនៅអូរអន្លក់កាលពីឆ្នាំ២០០៩ នេះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអាន។

**ស៖** បាទ អរគុណ ហើយបើតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ ថាតើអាចបញ្ជាក់បានទេ ថាកំណត់ហេតុស្ដាប់សក្ខីកម្មដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ ឬស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយរបស់លោក ដែលលោកបានធ្វើសម្ភាសនជាមួយនឹងអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៩ នោះដែរឬទេ?

[១១:០៤:៤៩]

**ឆ៖** បាទ ឯកសារនោះក៏វាស៊ីគ្នានឹងបទសម្ភាសន៍របស់ខ្ញុំដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបដល់តំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ និងសូមគោរពលោក លោកស្រីទាំងអស់ ដែលចូលរួមនៅក្នុងអង្គសវនាការនេះ។

[១១:០៥:៤២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** សួស្ដីលោក នង សុផង់។ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំមានសំណួរមួយចំនួននឹងសួរលោក។ ប៉ុន្តែមុននឹងសួរ ខ្ញុំសូមប្រាប់ទៅលោកថា ប្រសិនបើលោកមិនយល់សំណួរខ្ញុំទេ លោកអាចសួរមកខ្ញុំវិញបាន។ ខ្ញុំរីករាយនឹងទទួលនូវអ្វីដែលលោកស្នើសុំពីខ្ញុំវិញ។ តទៅនេះ ដូចលោកបានរៀបរាប់ជូនលោកប្រធានអង្គវសនាការហើយថា លោកបានអានឯកសារដែលក្រុមចៅក្រមស៊ើបអង្កេតគាត់បានទៅសួរលោក។ ខ្ញុំសួរនៅក្នុងឯកសារ ERN 00328023 ដល់ 24 ជាភាសាខ្មែរ, 00334044 ជាភាសាអង់គ្លេស និង 00411693 ជាភាសាបារាំង។ ក្នុងនោះចម្លើយរបស់លោកទៅកាន់ចៅក្រមស៊ើបសួរ ដែលមានឯកសារ E3/64 លោកបាននិយាយថា "នៅឆ្នាំ១៩៧៣ គឺឈ្មោះ ហង់

ជាគណៈតំបន់ព្រះវិហារ ជាអ្នកជ្រើសរើសរូបលោកឲ្យទៅធ្វើការនៅគណៈមជ្ឈិមនៅ ប-១៧"។ ខ្ញុំ -- ក្នុងសំណួរនេះ ខ្ញុំចង់ដឹងថាតើឈ្មោះ ហង់ នោះឈ្មោះពេញលោកស្គាល់ទេ? ទី១។ ទី២ ហេតុអ្វីបានជាលោកស្គាល់គាត់? ហើយតើលោកធ្លាប់ជួបគាត់ទេក្រោយមក?

**លោក នង សុផង់៖**

**ផ៖** បាទ នៅឆ្នាំ៧៣ លោក ហង់ បានរើសខ្ញុំមក ប-១៧។ ខ្ញុំមិនស្គាល់ឈ្មោះពិតរបស់លោក ហង់ ស្អីទេ ប៉ុន្តែគាត់មានតួនាទីជាគណៈតំបន់ព្រះវិហារ។ គាត់ឈ្មោះហង់ គេហៅថា ហង់ៗ គ្រប់គ្នា អ៊ីចឹងតែម្តងបាទ។ ឯឈ្មោះដើមយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំអត់ដឹងទេបាទ។

[១១:០៨:៣៤]

**ស៖** ខ្ញុំសួរលោកសំណួរដដែលទេថា តើមូលហេតុអ្វីបានជាលោកអាចស្គាល់លោក ហង់ ហ្នឹង?

**ផ៖** បាទមុននឹងគាត់រើសពួកខ្ញុំមក ប-១៧ ហ្នឹង គាត់បានធ្វើការប្រជុំអប់រំនយោបាយដើម្បីបំពាក់បំប៉នខាងផ្នែកសតិអារម្មណ៍ ដើម្បីឲ្យយើងខ្ញុំចេញទៅកន្លែងមជ្ឈិមហ្នឹងឲ្យបាន -- ឲ្យមានវិន័យល្អ ឲ្យ ហៅថា និយាយរួម គឺណែនាំបំពាក់បំប៉នតាមគោលការណ៍របស់អង្គការអង្គាល់ហ្នឹង ឲ្យមានវិន័យ ឲ្យមានសីលធម៌រស់នៅល្អ មុនគេនាំយើងខ្ញុំមកខាងមជ្ឈិមនេះបាទ។

**ស៖** ខ្ញុំសូមសួរបន្តទៀត។ ក្រោយមកនេះ តើលោកដែលធ្លាប់ជួបលោក ហង់ ទេ? ហើយដឹងថា គាត់ទៅណាទេសព្វថ្ងៃហ្នឹង?

**ផ៖** បាទ ខ្ញុំអត់ដឹងទេ។ អត់ដែលឃើញ អត់ដែលជួបទេបាទ។

**ស៖** តើលោកដឹងថា ប-១៧ ហ្នឹងជាកន្លែងអ្វីដែរ? អាហ្នឹងទី១ សំណួរ ហើយកន្លែងនេះស្ថិតនៅត្រង់ណា? ហើយអ្នកណាជាមេដឹកនាំនៅប-១៧ នេះបាទ?

**ផ៖** បាទ នៅប-១៧ គឺជាកន្លែងលត់ដំ បង្កបង្កើនផលដាំបន្លែបង្ការ សម្រាប់ឧបត្ថម្ភអង្គការបាទ ហើយក៏ជាកន្លែងមួយដែលសម្រាប់សាកល្បង មុននឹងចូលទៅកន្លែងមជ្ឈិមគេសាកល្បងមើលខាងផ្នែកជំហររបស់យើង។ ហើយអ្នកដែលគ្រប់គ្រងនៅប-១៧ ហ្នឹងគឺឈ្មោះលោក ឌឹម បាទ។ លោក ឌឹម គាត់ស្លាប់ហើយបាទ។

[១១:១២:០៧]

**ស៖** សូមទោសលោក។ តើប-១៧ នេះស្ថិតនៅកន្លែងណាដែរ?

**ផ៖** ខ្ញុំមិនសូវស្គាល់ចំណុចភូមិសាស្ត្រហ្នឹងទេ តែតាមខ្ញុំចាំឮគេនិយាយថា ជិតភូមិបិតធ្នូ

ហើយមិនស្គាល់ថា នៅក្នុងឃុំអី ស្រុកអីទេ។ ដឹងថា នៅម្តុំកំពង់ចាម ខេត្តកំពង់ចាមបាទ។

**ស៖** សកម្មភាពនៅ ប-១៧ នេះ តើពេលនោះលោកធ្វើអ្វីដែលជាក់លាក់ជាងគេ?

**ឆ៖** នៅកន្លែង ប-១៧ ហ្នឹង គឺខ្ញុំធ្វើជាអ្នកដាំបន្លែបង្ការ ដាំចេក ដាំអំពៅ តែប៉ុណ្ណឹង។ អត់មានភារកិច្ចអីក្រៅពីហ្នឹងទេបាទ។

**ស៖** លោកចងចាំទេ តើឆ្នាំណាដែលលោកទៅរៀនទូរលេខនុ៎ងបាទ?

**ឆ៖** បាទ គឺនៅក្នុងពាក់កណ្តាលឆ្នាំ៧៣ បាទ។ ពីព្រោះខ្ញុំធ្វើការនៅប-១៧ហ្នឹង គឺប្រហែលជាជិតកន្លះឆ្នាំបានគេបញ្ជូនខ្ញុំទៅកន្លែងអង្គការហ្នឹងបាទ។

**ស៖** ពេលនោះអ្នកណាជ្រើសរើសលោកឲ្យទៅរៀនសារទូរលេខ?

**ឆ៖** ខ្ញុំមិនដឹង ខ្ញុំមិនស្គាល់ឈ្មោះអ្នកដែលជ្រើសរើសខ្ញុំទេ ស្រាប់តែថ្ងៃមួយគេយកម៉ូតូមកឌុបខ្ញុំទៅក្នុងព្រៃតែម្តង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅសកម្មភាពរបស់លោកជាក់ស្តែង។ តើអ្នកណាជាអ្នកបង្រៀនសារទូរលេខដល់លោក? ហើយអ្នកដែលរៀនជាមួយលោកហ្នឹងមានប៉ុន្មាននាក់? ហើយរយៈពេលនៃការរៀនហ្នឹង បើគិតជាខែ ប៉ុន្មានខែ? ប៉ុន្មានឆ្នាំ? ហើយគេរៀនពីអ្វីខ្លះ?

[១១:១៥:៤៧]

**ឆ៖** បាទ អ្នកដែលបង្រៀនខ្ញុំ ឲ្យបកប្រែសារទូរលេខនោះ គឺឈ្មោះ ប៉ុន ដែលជាមេក្រុមរបស់ខ្ញុំ។ ហើយក្រៅពីហ្នឹង គឺមានអ្នកដែលរួមការងារមាន ថេរ ដែលខ្ញុំចាំជាងគេ ហើយនិងមានប៉ុន្មាននាក់ទៀត ដូចជាភ្លេចឈ្មោះគ្នាអស់ហើយបាទ។ ហើយការរៀនរបស់ខ្ញុំក្នុងការបកសារទូរលេខហ្នឹង គឺថារៀនបណ្តើរ ធ្វើបណ្តើរ។ មិនជាយូរប៉ុន្មាន ក៏អាចយល់ អាចក្តាប់បាន បច្ចេកទេសហ្នឹងបានយ៉ាងជំនាញដែរបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់លោកឡើងវិញ ថាតើអ្នកដែលរៀនសារទូរលេខ ជាមួយលោកហ្នឹងប៉ុន្មាននាក់? ហើយពេលដែលលោករៀនហ្នឹងមានរយៈពេលប៉ុន្មាន? ហើយគោលដៅនៃការរៀនហ្នឹងគឺមានអ្វីខ្លះបាទ?

**ឆ៖** បាទ ការរៀនហ្នឹងគឺថា ដែលខ្ញុំទៅភ្លាម គឺរៀនតែខ្ញុំម្នាក់ឯងទេ អត់មានអ្នកណាជាក្រុមអីផ្សេងទៀតទេបាទ។ ហើយការបង្រៀនហ្នឹង គឺមានគោលដៅដើម្បីបកប្រែ និងទទួលបកប្រែសារទូរលេខសម្ងាត់ ដែលគេបញ្ជូនមកឲ្យខ្ញុំបកបាទ ដើម្បីធ្វើការងារបញ្ជូន អ៎! បកប្រែសារទូរលេខហ្នឹង ឲ្យ

អង្គការបាទ។

[១១:១៧:៥៩]

**សៈ** ខ្ញុំសូមអានចម្លើយ ដែលលោកបានប្រាប់ទៅចៅក្រមស៊ើបសួរ។ នៅក្នុង ERN លេខ 00328024 ខ្មែរ, ហើយ ERN ជាភាសាអង់គ្លេស 00334044, ជាភាសាបារាំង 00411694។ ពេលនោះ លោកបានប្រាប់ថា "ប៉ុន ជាមេក្រុម ជាអ្នកបង្រៀនខ្ញុំ។ ក្រុមបកប្រែសារទូរលេខរបស់ខ្ញុំ មានគ្នាប្អូនទៅប្រាំនាក់"។ ហើយអម្បាញ់មិញនេះលោកឆ្លើយថា តែម្នាក់ឯងទេ តើចំណុចនេះ លោកកែប្រែយ៉ាងម៉េចដែរ?

**ឆៈ** បាទ ថា -- បាទចម្លើយនេះគឺពិតជាត្រឹមត្រូវហើយ។ ប៉ុន្តែការដែលគេយកខ្ញុំទៅរៀន តែម្នាក់ខ្ញុំទេ ដែលរៀនពេលហ្នឹង។ ឯប៉ុន្មាននាក់ គេចេះរួចអស់ហើយ គេមិនបាច់រៀនអី បាទ។

**សៈ** អរគុណលោក សុផង់ ដែលខ្ញុំមិនច្បាស់ ឥឡូវច្បាស់ហើយ។ ឥឡូវ ខ្ញុំសួរសំណួរទៀត។ បញ្ហាការអនុវត្តជាក់ស្តែង ដែលលោកមានប្រសាសន៍អម្បាញ់មិញ តើការអនុវត្តជាក់ស្តែងហ្នឹងសារណែនាំពីលើចុះក្រោម ឬក៏ពីក្រោមឡើងលើ ឬក៏យ៉ាងម៉េច សូមជួយពន្យល់បន្តិចមើល៍?

[១១:១៩:៥០]

**ឆៈ** បាទ កាអនុវត្តជាក់ស្តែង គឺពេលណាដែលខ្ញុំបានទទួលសារទូលេខជាលេខកូដសម្ងាត់រួចហើយ ខ្ញុំក៏បកប្រែទៅតាមឯកសារសម្ងាត់។ បានវាចេញជាខ្លឹមសារឯកសារ រួចមកក៏ខ្ញុំប្រគល់ជូនទៅលោក ប៉ុន ដើម្បីយកខ្លឹមសារទូរលេខដែលខ្ញុំបកបានហើយហ្នឹង លោកចាត់ចែងជូនទៅអង្គការបាទ។ ឯការជាក់ស្តែងគឺថា មានសារទូរលេខដែលខាងមូលដ្ឋាន ខាងភូមិភាគ ឬមួយក៏ខាងសមរភូមិគេបញ្ជូនមកតាមរយៈវិទ្យុទាក់ទង ទូរលេខ។ រួចហើយគេមាននីរសារបញ្ជូនឲ្យខាងក្រុមលោក ប៉ុន នេះ ហើយលោក ប៉ុន ប្រគល់សារហ្នឹងមកឲ្យតាមទិសតាមមុខព្រួញដែលខ្ញុំត្រូវទទួល។ អានេះ និយាយអំពីសារចូល។

[១១:២១:១៤]

ឯសារចេញទៅវិញ ក៏ដូច្នោះដែរ។ ពេលលោក ប៉ុន ទៅទទួលខ្លឹមសារជាសារទូរលេខ ជាអក្សរធម្មតា ហើយគេបញ្ជូនមកទិស ឬមុខព្រួញណាដែលយើងទទួលខុសត្រូវ ហើយយើងប្រែខ្លឹមសារហ្នឹងទៅជាលេខកូដសម្ងាត់។ ពេលដែលយើងប្រែរួចហើយ បានយើងបញ្ជូនទៅតាមឲ្យនីរសារ បញ្ជូនទៅកន្លែងវាយទូរលេខ បញ្ជូនទៅចេញទៅបាទ។

**ស៖** អរគុណលោក។ នៅក្នុងចម្លើយរបស់លោកប្រាប់ចៅក្រមស៊ើបអង្កេត ឯកសារខ្មែរ ERN 00328024, អង់គ្លេស 00334044, បារាំង 00411694។ លោកបានប្រាប់ចៅក្រមស៊ើបអង្កេតថា "នៅប-១៧ លោកបានជួប ប៉ុល ពត, នួន ជា"។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើប-១៧ នេះជាកន្លែងរបស់ ប៉ុល ពត និងកន្លែង នួន ជា គាត់ស្នាក់នៅ និងធ្វើការនៅទីនោះ ឬមួយក៏យ៉ាងម៉េចដែរបាទ?

**ឆ៖** បាទ កន្លែងប-១៧នេះ គឺគ្រាន់តែជាទីស្នាក់ការមួយសម្រាប់លត់ដំ មុននឹងបញ្ជូនទៅកន្លែងអង្គការ មិនមែនជាកន្លែងធ្វើការរបស់លោក ប៉ុល ពត ឬក៏លោក នួន ជា ទេបាទ។

**ស៖** ខ្ញុំចង់ដឹងទៀតថា តើលោកដឹងថា ប៉ុល ពត និង នួន ជា ហ្នឹង គាត់មកប-១៧ ធ្វើសកម្មភាពយ៉ាងដូចម្តេចដែរពេលហ្នឹង?

**ឆ៖** បាទ គាត់មកប-១៧ គ្រាន់តែថា កន្លែងហ្នឹងជាកន្លែងបង្កបង្កើនផល។ ដូច្នេះគឺ របៀបជាដំណើរពិនិត្យមើលខាងការងារបង្កបង្កើនផលហ្នឹង មានបានទទួលផលអីខ្លះ មានការរីកចម្រើនយ៉ាងម៉េច ហើយក៏ទន្ទឹមហ្នឹងក៏មកមើលចលនាបង្កបង្កើនផល។ ហើយតាមខ្ញុំយល់គឺថា ប្រហែលជាគាត់ដើម្បីជាដំណើរកំសាន្ត ឲ្យធូរអារម្មណ៍របស់គាត់ដែរតាមមើល។

[១១:២៤:៥១]

**ស៖** តើពេលនោះ ហេតុអ្វីបានដឹង បានលោកស្គាល់ថា គាត់ហ្នឹងជា ប៉ុល ពត? ហើយលោកស្គាល់ថា គាត់នោះជាលោក នួន ជា? តើធ្វើម៉េចបានដឹងពីរឿងហ្នឹង?

**ឆ៖** បាទ មានអស់លោកដែលគេរស់នៅធ្វើការងារនៅប-១៧ ហ្នឹងមិនមែនមានតែខ្ញុំម្នាក់ឯងទេ មានអ្នកដែលគេមកមុនៗនៅកន្លែងហ្នឹង គេស្គាល់ ហើយខ្ញុំក៏មិនស្គាល់ ខ្ញុំក៏សួរគេថា លោកអីដែលធំៗអ៊ីចឹង? ខ្ញុំក៏មិនដែលស្គាល់ មិនដែលឃើញ គេក៏ប្រាប់ថាហ្នឹងហើយ បងប៉ុល, បងនួន បាទអ៊ីចឹងទៅបាទ។ រឿងហ្នឹងវាអ៊ីចឹងបាទ។

**ស៖** ក្រៅពីៗលោកស្គាល់លោក ប៉ុល ពត និងលោក នួន ជា តើលោកមានឃើញមេដឹកនាំណាផ្សេងទៀតដែលលោកស្គាល់ហើយទៅប-១៧ នេះទេបាទ?

[១១:២៦:២៤]

**ឆ៖** បាទ មិនដែលស្គាល់ ហើយក៏មិនដែលឃើញទេបាទ។

**ស៖** ខ្ញុំសួរសំណួររៀងថយក្រោយបន្តិច អម្បាញ់មិញខ្ញុំសួរលោកថា តើលោករៀនសារទូរលេខនេះរយៈពេលប៉ុន្មានខែ ឬប៉ុន្មានឆ្នាំ? ហើយលោកដូចជាមិនទាន់ឆ្លើយនៅចំណុចនេះ អ៊ីចឹងខ្ញុំសូមសួរ

សាថ្មី ថាតើលោករៀនហ្នឹងវាប៉ុន្មានខែ? ប៉ុន្មានឆ្នាំ? បន្ទាប់មក ពេលដែលលោកចេះហើយនេះ លោកទៅធ្វើការនៅទីណាបន្តទៀតបាទ?

**ផះ** បាទ ខ្ញុំធ្វើការរៀនសូត្រនៅក្នុងឆ្នាំ៧៣ហ្នឹង ដោយរៀនផងធ្វើផងជាបណ្ដើរៗ ហើយដល់ខ្ញុំរៀនចេះគឺតាមប៉ាន់ស្មានមើលគឺថា ដល់ឆ្នាំ៧៤ បានខ្ញុំម្ចាស់ការ ហើយក៏គេបានបំបែកកម្លាំងខ្ញុំឲ្យទៅធ្វើការនៅកន្លែងមួយផ្សេងទៀតនៅម្តុំព្រៃចេក ប-២០ បាទ។

**សះ** នៅប-២០ហ្នឹង លោកមានឋានៈជាអ្វីដែរពេលនុ៎ង?

**ផះ** បាទ នៅប-២០ ខ្ញុំមានឋានៈជាប្រធានបកប្រែទូរលេខ ប្រធានក្រុមបាទ។

**សះ** លោកអាចប្រាប់តុលាការបានទេថា តើអ្នកគ្រប់គ្រងទូទៅនៅប-២០ នោះអ្នកណាពេលហ្នឹង?

**ផះ** បាទ ខ្ញុំអត់ស្គាល់ទេបាទ។

[១១:២៩:១៤]

**សះ** សូមលោកជួយបញ្ជាក់ផងដែរថា ប-២០នេះ ជាកន្លែងសម្ងាត់សម្រាប់ផ្នែកយោធា ឬក៏ជាកន្លែងសម្រាប់ជនស៊ីវិលធម្មតាអាចទៅបានដែរទេ?

**ផះ** បាទ ប-២០ គឺជាកន្លែងបង្កបង្កើនផលមួយដែរសម្រាប់ឧបត្ថម្ភទៅសមរភូមិមុខ ហើយក៏ជាទីស្នាក់ការមួយដែរ ឯខ្ញុំ ខ្ញុំមិនដែលទៅកន្លែងទូលាយទូទៅ កន្លែងទីស្នាក់ការទូទៅនោះទេ ពីព្រោះខ្ញុំនៅតែក្នុងព្រៃចេកតែប៉ុណ្ណឹងមិនមានសិទ្ធិអីដើរហើរឆ្វេចឆ្វាចទៅកន្លែងណាផ្សេង ក្រៅពីម្តុំព្រៃចេកខ្ញុំហ្នឹងទេបាទ។

**សះ** ខ្ញុំសួរថាក្រុមបកប្រែសារទូរលេខ ដែលលោកប្រធានក្រុមហ្នឹង មានមនុស្សចំនួនប៉ុន្មាននាក់ដែលបកប្រែសារទូរលេខហ្នឹង? ហើយពេលនោះ ប៉ុន មាននៅទីនោះដែរទេបាទ?

**ផះ** បាទ អ្នកដែលនៅក្រុមជាមួយខ្ញុំហ្នឹង គឺមានខ្ញុំជាប្រធាន ហើយមាន វង់ ហើយនិងមានម្នាក់ទៀត ឈ្មោះអី ដួច ដាម! ខ្ញុំមិនចំណាំទេ ដូចភ្លេច ឈ្មោះ ដាប អីអាម៉េចទេ ហើយគាត់ហ្នឹងអ្នកថ្មីដែរ។ តែបីនាក់ទេ ហើយនិង -- ឯ ប៉ុន ពេលនោះមិននៅជាមួយខ្ញុំទេបាទ។ គាត់ទៅធ្វើការនៅ -- ព្រោះក្រុមហ្នឹងចែកជាពីរ ខាងខ្ញុំនេះទទួលខាងសមរភូមិក្រោយ ឯលោក ប៉ុន ហ្នឹង គាត់ទៅធ្វើការនៅសមរភូមិមុខជាមួយនឹង ប៉ុល ពត នៅខាងលិចភ្នំពេញបាទ។

[១១:៣២:០៣]

**សៈ** តើលោកអាចរៀបរាប់ពីរចនាសម្ព័ន្ធសារទូរលេខ ដែលលោកធ្វើការនៅទីនោះជូនអង្គសវនាការស្ដាប់បានទេ?

**ធៈ** បាទ និយាយពីការរៀបចំការងារនៅខាងខ្ញុំនេះ មានទំនាក់ទំនងបីអង្គភាពបាទ។ គឺទី១ គឺក្រុមខ្ញុំហ្នឹងខាងបកប្រែសារទូរលេខ ហើយក៏មិនមានរចនាសម្ព័ន្ធអីពីណាមកគ្រប់គ្រងពីលើខាងខ្ញុំទៀតដែរ ព្រោះជាក្រុមមួយឯករាជ្យសម្រាប់តែបកប្រែសារទូរលេខហ្នឹង សូម្បីតែប្រធានមន្ទីរប-២០ ក៏មិនមានសិទ្ធិមកគ្រប់គ្រងត្រួតត្រាពិនិត្យពីលើក្រុមខ្ញុំនេះបានដែរ។ ក្រុមខ្ញុំនេះ គឺក្រុមឯករាជ្យ។ ហើយមានមួយក្រុមទៀត គឺអង្គភាពមួយទៀត ជាអង្គភាពទទួលនិងបញ្ជូនសារទូរលេខ។ ហើយអង្គភាពមួយទៀត គឺជាអង្គភាពផ្សាយសំឡេង វិទ្យុផ្សាយសំឡេង។ ឯអង្គភាពទាំងបីនេះ គឺនៅដាច់ៗដោយឡែកពីគ្នា មិនដែលឃើញមុខគ្នា មិនដែលស្គាល់មុខគ្នាទេបាទ។ គឺការរៀបចំរបស់អង្គការគេហ្នឹងគឺអ៊ីចឹង មិនមានឲ្យមានការទាក់ទងគ្នាពីក្រុមមួយទៅក្រុមមួយទេ គឺរៀងៗខ្លួនបាទ។

[១១:៣៣:៥៥]

**សៈ** អរគុណលោក សុផង់។ នៅមុននេះបន្តិចលោកបានប្រាប់ថា នៅប-២០ អ៎! នៅប-១៧ គឺលោកបានជួបមេដឹកនាំលោក ប៉ុល ពត និង នួន ជា។ ឥឡូវនេះនៅប-២០ វិញ តើមេដឹកនាំណាខ្លះដែលលោកបានជួបបាទ?

**ធៈ** បាទ នៅប-២០ ខ្ញុំមិនមានជួបអ្នកដឹកនាំណាទេ ពីព្រោះរាល់នូវសារទូរលេខទាំងឡាយណាដែលខ្ញុំបករួចហើយ ក៏មាននីរសារសម្រាប់នាំទៅជូនអ្នកដឹកនាំ -- ដែលមិនដឹងជាគេនៅកន្លែងណាខ្ញុំមិនដឹង។ អ៊ីចឹង គឺខ្ញុំមានភារកិច្ចតែបកប្រែសារទូរលេខ ឯរឿង -- គេយកសារទូរលេខដែលខ្ញុំបកហើយ ទៅជូនអ្នកណាៗទៀត ខ្ញុំអត់បានដឹង អត់បានឃើញ និងអត់ស្គាល់ទេបាទ។

**សៈ** តើពេលនោះនៅប-២០នេះ លោកស្គាល់ ប៉ង់ ទេ? ហើយ ប៉ង់ ហ្នឹងជានរណាដែរបាទ?

**ធៈ** បាទ ខ្ញុំបានស្គាល់ ប៉ង់ ហ្នឹងគឺតាំងពីខ្ញុំមកប-១៧ មកម្ល៉េះបាទ។ ពីព្រោះ ប៉ង់ ពេលដែលខ្ញុំមកដល់ភ្នាម គឺ ប៉ង់ ហ្នឹងហើយអ្នកចាត់ចែងឲ្យខ្ញុំមកនៅប-១៧ ហើយបំពាក់បំប៉ននយោបាយ សតិអារម្មណ៍អីៗ គឺ ប៉ង់ ហ្នឹងហើយជាអ្នកនៅពីលើ ឌីម ហ្នឹងទៀតបាទ។

[១១:៣៦:១៨]

**សៈ** ខ្ញុំចង់ដឹងថា មន្ទីរសារទូរលេខនៅប-២០ ហ្នឹង គឺជាកន្លែងរបស់មជ្ឈិម តើមែនទេ? ទី១ ហើយរវាងប-២០ ហើយនិងកន្លែងមន្ទីរមជ្ឈិមនេះវានៅជាមួយគ្នា ឬក៏នៅចម្ងាយ ឬក៏នៅទីណាផ្សេង

គ្នាបាទ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ ព្រោះខ្ញុំមានភារកិច្ចតែបកសារ។ ឯមិនប៊ានទាំងសួរគេថា មន្ទីរមជ្ឈិមនោះត្រង់ណាអីត្រង់ណា? ខ្ញុំអត់ដែលបានដឹង ហើយក៏មិនដែលប៊ានសួរគេផងបាទ។

**ស៖** លោកមិនដឹងថា មន្ទីរមជ្ឈិមនៅទីណា។ ខ្ញុំចង់ដឹងថា តើលោកអាចដឹងថា តើ ប៉ុល ពត នោះធ្វើការនៅទីណា លោកអាចដឹងទេពេលនុ៎ង? ហើយចម្ងាយប៉ុន្មានពីប-២០ ហ្នឹងបាទ?

**ឆ៖** បាទ កាលខ្ញុំនៅប-២០ ខ្ញុំមិនដឹងមន្ទីរមជ្ឈិមតាំងនៅណាទេ។ ប៉ុន្តែកាលខ្ញុំនៅរៀននៅទូរលេខហ្នឹង នៅក្នុងព្រៃបានខ្ញុំដឹងថា មន្ទីរមជ្ឈិមគឺតាំងនៅក្នុងព្រៃហ្នឹងហើយ ក្នុងព្រៃជ្រៅហ្នឹង។ ប៉ុន្តែក្រោយមកពេលដែលឆ្នាំ៧៤ មានការបែងចែកក្រុមខ្ញុំជាពីរ មួយទៀតខាងសមរភូមិមុខទៅ មួយទៀតគឺនៅសមរភូមិក្រោយអ៊ីចឹង។ ដូច្នេះរឿងមន្ទីរមជ្ឈិមនៅត្រង់ណា ខ្ញុំមិនដឹងទាំងអស់បាទ។

[១១:៣៨:៣៦]

**ស៖** ឥឡូវនេះខ្ញុំចូលទៅដល់សំណួររវាងលម្អិតបន្តិច ទាក់ទងនឹងការបញ្ជូនសារចូល ជាមួយនឹងការបញ្ជូនសារចេញ។ បញ្ជូនសារចូលវាជារបាយការណ៍ បញ្ជូនសារចេញជាសេចក្ដីណែនាំ ឬក៏ពីរហ្នឹងតើវាខុសគ្នាយ៉ាងដូចម្ដេចបាទ?

**ឆ៖** បាទ សារចូល និងសារចេញមានការខុសគ្នា។ ដូចលោកបានមានប្រសាសន៍អំមិញហ្នឹងគឺថា សារចូលគឺជារបាយការណ៍ ដែលខាងមូលដ្ឋាន ឬក៏ខាងសមរភូមិមុខ គេរាយការណ៍មកខាងសមរភូមិក្រោយ។ អាហ្នឹងគឺជាដំណឹងប្រយុទ្ធ ជាដំណឹងពីសមរភូមិបាទ។ អានេះគឺហៅថាជាដំណឹងផ្សេងៗ ដែលរាយការណ៍ពីកន្លែងខាងក្រោមមកខាងលើ។ នេះគេហៅថារបាយការណ៍។ ឯការបញ្ជូនសារចេញទៅវិញ គឺជាសេចក្ដីណែនាំ អាហ្នឹងគឺៗជាវិធានការផ្សេងៗ ជាសេចក្ដីណែនាំ ដើម្បីឲ្យមូលដ្ឋានគេយកទៅអនុវត្ត។ បាទនេះហៅថាសេចក្ដីណែនាំ។ ឲ្យថ្នាក់ក្រោមគេយកទៅអនុវត្ត។

**ស៖** អរគុណលោក។ ខ្ញុំនឹងបន្ថែមចំណុចនេះមួយទៀត។ ទាក់ទងនឹងរបាយការណ៍ពីក្រោមឡើងមកលើ តើពីក្រោមនោះ គេសរសេរដោយដៃ ឬមួយក៏គេចុចសារទូរលេខទីតៗ តតៗ ជូនលោក? ហើយបន្ទាប់មក លោកបានលទ្ធផលហ្នឹង លោកបញ្ជូនរបាយការណ៍ហ្នឹងទៅថ្នាក់លើ តើអ៊ីចឹងមែនដែរទេ? បើខុសពីហ្នឹង សូមលោកជួយបង្ហាញបាទ។

[១១:៤១:៣៧]

**ឆ៖** បាទ រឿងនេះគឺដំបូង គឺវាជាលេខកូដសម្ងាត់ ដែលគេបញ្ជូនមកឲ្យខ្ញុំបកប្រែហ្នឹង។ គឺជា

លេខដែលយើង -- លេខទាំងអស់តែម្ដង គ្រប់ទំព័រសុទ្ធតែលេខបាទ សុទ្ធតែលេខសម្ងាត់ ដែលគេវៃតាមអាទិចទិចតាហ្នឹង វាចេញជាលេខ ឬមួយក៏វាចេញជា *ម៉ស* ខ្មែរក៏មានដែរ។ អ៊ីចឹងគេហៅថា វាប្រើសញ្ញាបាទ វាចេញចាសញ្ញាទូរលេខ វាចេញជាលេខ។ ពេលខ្លះវាចេញជាអក្សរ អាហ្នឹងគឺហៅថា "*ម៉ស*"។ *ម៉ស* នេះគេប្រើសម្រាប់ទទួលព័ត៌មានចំហាពីសមរភូមិ ដំណឹងប្រយុទ្ធអីផ្សេងៗ គេវៃជា *ម៉ស* មក ចេញជាអក្សរមក។ ហើយគេបញ្ជូនសារទាំងលេខកូដសម្ងាត់ ទាំងសារលេខកូដចំហនេះ តាមរយៈនីរសារមកជូនដល់កន្លែងខ្ញុំអ្នកទទួល។ ទាំងដំណឹងផ្សេងៗ ក៏ដូចជាសារទូរលេខជាលេខកូដសម្ងាត់ ដើម្បីខ្ញុំបកប្រែ និងខ្ញុំចាត់ចែងតាមទៅឲ្យថ្នាក់លើវិញ តាមរយៈនីរសារដែរ។ ពេលណាខ្ញុំបកប្រែ -- បើសារជា*ម៉ស* ខ្មែរ គឺខ្ញុំមិនបាច់បកអីទៀត។ ខ្ញុំរៀបចំបញ្ជូនដាក់សំបុត្រ។ បើសារសម្ងាត់បានជាលេខទើបខ្ញុំបកប្រែចេញជាខ្លឹមសារហើយ បានខ្ញុំរៀបចំបញ្ជូនដាក់សំបុត្រជូនទៅតាមនីរសារបាទ។

[១១:៤៣:៤៨]

**ស៖** អរគុណលោក។ ដោយសារបញ្ហានេះ វាបច្ចេកទេស អ៊ីចឹងខ្ញុំចង់សួរលោកមួយសាទៀត។ ទាក់ទងជាមួយនឹងសេចក្ដីណែនាំពីថ្នាក់លើមកវិញ តើគេបញ្ជូនជាសារសម្ងាត់ ទីត១ តត១ ឬមួយក៏គេសរសេរដៃយកមកឲ្យលោក ដើម្បីលោកបំលែងឯកសារហ្នឹងបញ្ជូនចេញទៅថ្នាក់ក្រោមវិញបាទ?

**ឆ៖** បាទ ដំបូងឡើយ សារទាំងឡាយណាដែលថ្នាក់លើត្រូវបញ្ជូនទៅក្រោម ថ្នាក់លើ ឬមួយក៏លោកមានលេខារបស់លោកទៅទទួលកត់ត្រាពាក្យពេចន៍ទាំងឡាយណាដែលលោកចង់ណែនាំ ជាសារទូរលេខ អ៊ំ! ជាលិខិត ជាទូរលេខធម្មតា អក្សរធម្មតា។ រួចហើយលោកផ្ញើតាមនីរសារមកចូលមកកន្លែងខ្ញុំដើម្បីបកប្រែឲ្យទៅសារសម្ងាត់។ យកអក្សរទាំងអស់ហ្នឹងមកធ្វើឲ្យទៅជាសារសម្ងាត់ ឲ្យទៅជាលេខវិញបាទ។ ឲ្យទៅជាលេខមួយជាន់អ៊ីចឹងហើយ មិនទាន់សម្រេចទៀត ខ្ញុំត្រូវបង្វែងដានទៅអីពីរបីជាន់ទៀត បានចេញទៅជាលេខកូដទាំងអស់តែម្ដង។ អត់មាននរណាមើលស្គាល់ថាអីៗទេ មើលទៅឃើញតែលេខអ៊ីចឹងបាទ។ រួចហើយបានខ្ញុំដាក់ក្នុងស្រោមសំបុត្រ ហើយបញ្ជូនទៅឲ្យនីរសារវៃកន្លែងទៅតាមខាងផ្នែកវាយបញ្ជូនសារទូរលេខបាទ។

[១១:៤៦:៣២]

**ស៖** អរគុណលោក។ សូមលោកជួយប្រាប់អង្គសវនាការមើល ថាតើសារដែលគេបញ្ជូនពីសមរភូមិគេហៅថារបាយការណ៍ ហើយសេចក្ដីណែនាំពីថ្នាក់លើទៅថ្នាក់ក្រោម អ្នកណាជាអ្នកបញ្ជូនសារ ឬក៏របាយការណ៍ពីក្រោមឡើងទៅលើ ទៅឲ្យថ្នាក់ដឹកនាំមួយណាដែលលោកគិតថា ញឹកញាប់

ជាងគេដែលលោកបានឃើញពេលនោះបាទ?

**ឆ៖** បាទ ចំពោះរបាយការណ៍ផ្សេងៗ គឺគេបញ្ជូនមកសំដៅអង្គការ ហើយក៏ខ្ញុំនៅពេលនៅក្នុងព្រៃនុំង ខ្ញុំមិនដឹងថា សារទូរលេខហ្នឹង ត្រូវជូនទៅលោកណាៗទេ ហើយក៏មិនស្គាល់ថា លោកណាជាអង្គការដែរកាលហ្នឹង គឺកាលណាខ្ញុំបករួចហើយ មាននីរសារទៅ។ គេយកទៅកន្លែងណា ខ្ញុំក៏មិនដឹង។ ជូនទៅលោកណា ខ្ញុំក៏មិនដឹងបាទ។ ហើយអ្នកដែលញឹកញាប់ជាងគេ ដាក់ក្នុងហត្ថលេខាសារបស់គាត់ហ្នឹងគឺ សំខាន់គឺ បើកាលខ្ញុំនៅក្នុងព្រៃគឺ លោកដាក់ថា ប៉ុលៗ អ៊ីចឹងតែម្តង។ បាទ សរសេរដាក់ ប៉ុលពីក្រោមអ៊ីចឹង អ្នកចុះហត្ថលេខាលើសារហ្នឹងបាទ។ ប៉ុល ហ្នឹងគឺតាមខ្ញុំយល់បែប ប៉ុល ពត ហ្នឹងហើយបាទ ដែលមានសារញឹកញាប់ជាងគេបាទ។

[១១:៤៩:២២]

**សៈ** ចុះសារ ដែលមិនសូវញឹកញាប់ ហើយលោកបានជួបប្រទះនោះ គេបានរាយការណ៍ ឬក៏បញ្ជូនទៅៗអ្នកណាដែរបាទ?

**ឆ៖** បាទ សារដែលម្តងម្កាល គឺមានទៅ គេសរសេរជូន បងនួន អ៊ីចឹងដែរបាទ។ អាហ្នឹងម្តងម្កាលទេ មិនជាញឹកញាប់ទេបាទ។

**សៈ** ខ្ញុំមានសំណួរមួយទៀត ភ្ជាប់ជាមួយនឹងរបាយការណ៍ ឬគេហៅថា សារដែលបញ្ជូនពីក្រោមឡើងមកលើ ហើយលោកបានបំលែងសារនោះទៅជាអក្សរ។ តើនៅពេលដែលបំលែងវាហើយអ្នកណាដែលមានសិទ្ធិដាក់ថា ចម្លងជូនទៅមេដឹកនាំនេះ មេដឹកនាំនោះ? តើលោកបានដឹងទេចំណុចហ្នឹង?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ដំណាក់កាលដែលខ្ញុំធ្វើការសារទូរលេខវាមានពីរដំណាក់កាល។ ដំណាក់កាលដែលនៅក្នុងព្រៃ ខ្ញុំមិនសូវដឹងអីទេបាទ ប៉ុន្តែដល់ពេលដែលឆ្នាំ៧៥ ពេលដែលរំដោះភ្នំពេញហើយ ខ្ញុំក៏ត្រូវបានផ្លាស់ប្តូរទៅកន្លែងមកនៅភ្នំពេញដែរ ពេលហ្នឹងបានខ្ញុំដឹងថា គេ -- អ្នកណាដែលមានសិទ្ធិចាត់ចែង ហើយគឺមានតែប្រធានក្រុមខ្ញុំទេ ដែលគាត់អាចមានសិទ្ធិដាក់ថា ចម្លងជូនលោកណាៗគឺលោក ប៉ុន បាទ។

[១១:៥២:២០]

**សៈ** កន្លែងនេះ ខ្ញុំសូមសួរលម្អិតលោកបន្តិច តើរបាយការណ៍ពីក្រោមឡើងមកលើហ្នឹងលោកដែលឃើញគេភ្ជាប់មកជាមួយដាក់ថា ចម្លងជូនទៅអ្នកណាៗដែរទេបាទ?

**ផ៖** បាទ របាយការណ៍ចូលមកខ្ញុំមិនដែលឃើញគេដាក់ថា ចម្លងជូនអ៊ំណាៗទេ មានតែក្បាលខាងលើគេដាក់ថា “ជូនបងជាទីគោរព ឬមួយក៏ជូនអង្គការ ៨៧០” អាហ្នឹង គេដាក់ខាងក្បាលរួចហើយ។ ឯរឿងចម្លងជូននេះ មិនដែលមានរបាយការណ៍ណាដាក់ថា ចម្លងជូនបងនេះបងនោះទេ។ អ្នកដែលមានសិទ្ធិដាក់ថា ចម្លងជូនបងណាៗគឺលោក ប៉ុន បាទ។

**ស៖** អរគុណណាស់លោក នង សុផង់ ខ្ញុំនឹងសួរសំណួរបន្ថែមទៀត។ ឥឡូវហ្នឹងខ្ញុំសួរអំពីសេចក្តីណែនាំពីលើចុះក្រោមវិញម្តង តើខ្លឹមសារ និងអត្ថន័យនៃសេចក្តីណែនាំពីលើចុះក្រោមហ្នឹងលោកចងចាំទេ? តើគេនិយាយពីអ្វីខ្លះបាទ?

[១១:៥៤:១៤]

**ផ៖** បាទ សេចក្តីណែនាំគឺមានគ្រប់ទិដ្ឋភាពទាំងអស់ គឺវាអាស្រ័យទៅលើរបាយការណ៍ដែលខាងក្រោមគេស្នើសុំយោបល់ពីថ្នាក់លើ។ ឯថ្នាក់លើជូនមតិ ឬក៏ផ្តល់មតិទៅវិញក៏វាសមស្របទៅនឹងរបាយការណ៍ដែលគេរាយការណ៍មក។ ឯសេចក្តីណែនាំរបស់ថ្នាក់លើ គឺវាមានគ្រប់ទិដ្ឋភាពទាំងផ្នែកនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងការទំនាក់ទំនងអីផ្សេងៗ សភាពការណ៍រួមផ្សេងៗដើម្បីឱ្យខាងមូលដ្ឋាន ឬមួយក៏ថ្នាក់ដឹកនាំក្រោមៗ យល់អំពីសភាពការណ៍តាមកាលៈទេសៈនីមួយៗវាយ៉ាងដូចម្តេច។ នេះជាសេចក្តីណែនាំពីលើទៅក្រោម បាទ។

**ស៖** លោក ផង់ លោកនិយាយអម្បាញ់មិញថាទាក់ទងជាមួយនឹងសេចក្តីណែនាំ ទាក់ទងនឹងសេដ្ឋកិច្ចជាមួយនឹងវប្បធម៌ លោកបានពិនិត្យអាហ្នឹង។ តើមេដឹកនាំណាមួយដែលណែនាំទាក់ទងនឹងសេដ្ឋកិច្ច និងវប្បធម៌ ដែលលោកបានបញ្ជូនតាមទូរលេខហ្នឹងបាទ?

[១១:៥៦:២២]

**ផ៖** បាទ សេចក្តីណែនាំភាគច្រើន គឺចេញអំពីគណៈ៨៧០ បាទ។ គណៈ៨៧០ ណែនាំទៅវាគ្រប់ទិដ្ឋភាពទាំងអស់ រួមទាំងមូល សភាពការណ៍រួមបាទ។ អ៊ីចឹងក្នុងទិដ្ឋភាពរួមហ្នឹង វាមានគ្រប់ផ្នែកបាទ។ ដោយឡែក បញ្ហាវប្បធម៌ បញ្ហាសេដ្ឋកិច្ច ថ្នាក់ដឹកនាំដែលចាត់ចែងបញ្ហាសេដ្ឋកិច្ច បញ្ហាវប្បធម៌ហ្នឹងផ្សេង សេដ្ឋកិច្ចហ្នឹងផ្សេង អត់មានលាយឡំគ្នាទេ។ វាមានផ្នែករបស់វា។ ខាងសេដ្ឋកិច្ចគឺអ្នកដែលទទួលខុសត្រូវពេលហ្នឹង ដូចជារាយការណ៍អំពី អំ! ដូចជាទាក់ទងបញ្ហាសម្ភារៈផ្សេងៗ ដែលលោកបញ្ជូនទៅតាមមូលដ្ឋានហ្នឹង។ អ្នកចាត់ចែងខាងហ្នឹង គឺលោក ខៀវ សំផន បាទ។ ឯខាងវប្បធម៌ទាក់ទងរឿងវប្បធម៌ មានបញ្ហាអ្វីដែលប៉ះពាល់ខាងសីលធម៌ ខាងអីៗ គឺលោក នួន ជា តែម្តង គាត់អ្នក

ណែនាំ មានភារកិច្ចរបស់គាត់ គឺផ្សេងៗគ្នា បាទ។ ឯខាងលោក ប៉ុល ពត គាត់ណែនាំរួមទាំងអស់តែម្តង អ្វីក៏គាត់មានសិទ្ធិនិយាយដែរបាទ។

[១១:៥៨:២៤]

**ស៖** លោកថា ផ្នែកសម្ភារៈ ឬក៏សេដ្ឋកិច្ចហ្នឹង គឺទាក់ទងជាមួយនឹងលោក ខៀវ សំផន ហើយធ្វើម៉េច បានប្រាកដថា គាត់ហ្នឹងជា ខៀវ សំផន នោះបាទ?

**ឆ៖** បាទ លោក ខៀវ សំផន ពីព្រោះក្នុងសម័យនោះ គឺលោកហ្នឹងហើយជាអ្នកពេលមានភ្ញៀវរដ្ឋអីមកពីណាៗ គឺលោកចេញមុខ អ្នកណាក៏អាចដឹងថាលោកជាគណៈប្រធានរដ្ឋជាលោក ខៀវ សំផន ហ្នឹងក៏គេស្គាល់បាទ។ ហើយសាររបស់លោកហ្នឹង គឺលោកមុននឹងចាត់ចែងសម្ភារៈទៅភូមិភាគ ឬតំបន់ណា លោកបញ្ជូនសារទូរលេខហ្នឹង មកឲ្យខ្ញុំមុន ដើម្បីវៃប្រែជាទូរលេខសម្ងាត់ ទៅជូនទៅខាងមូលដ្ឋានឲ្យគេបានដឹងថា សម្ភារៈនេះមានប៉ុន្មាន នោះប៉ុន្មានៗ អាហ្នឹង គឺលោកធ្វើតាមសារទូរលេខ។ លោកផ្ញើមកខាងក្រុមខាងខ្ញុំនេះ បាទ។

**ស៖** អរគុណលោក សុផង់។ ទាក់ទងជាមួយនឹងសំណួរបន្តទៅទៀត ខ្ញុំសួរលោកថាតើលោកនៅចងចាំទេថា មានសារទូរលេខសេចក្តីណែនាំ ស្តីពីការកាន់កាប់ ឬក៏ចូលវាយលុកទីក្រុងភ្នំពេញទេពេលនុំងបាទ?

[១២:០០:៤៤]

**ឆ៖** បាទ សារទូរលេខនោះ ខ្ញុំចងចាំបានច្បាស់ណាស់ ពីព្រោះមានរបាយការណ៍ ហើយក៏ដូចខ្ញុំឃើញជាក់ស្តែងដែរ គឺឃើញថានៅក្នុងឆ្នាំ -- តាំងពីចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨ មក ខ្ញុំក៏ឃើញសារ ដែលវៀតណាមបានលើកទ័ពជាបន្តបន្ទាប់ ធ្វើឲ្យមានការប៉ះទង្គិចគ្នាតាមព្រំដែនជាបន្តបន្ទាប់។ ហើយទន្ទឹមនេះក៏ខ្ញុំបានឃើញយុទ្ធជន ដែលត្រូវរបួសមកគេដឹកមកភ្នំពេញជាបន្តបន្ទាប់ដែរបាទ។ ដោយសារតែមានការប៉ះទង្គិចគ្នានៅតាមតំបន់ព្រំដែនខាងកើតនេះបាទ។

**ស៖** អរគុណលោក សុផង់ ក៏ប៉ុន្តែ ខ្ញុំអត់ទាន់បានសួរ -- ខ្ញុំនឹងសួរពេលក្រោយទៀត ទាក់ទងនឹងឆ្នាំចិតសិបជាងហ្នឹងណ៎ា។ ខ្ញុំសួរមុន៧៥បន្តិច មុនពេលការរៀបចំត្រៀមវៃកាន់កាប់ផ្តួលរំលំទីក្រុងភ្នំពេញនេះ តើមានសារទូរលេខ ស្តីពីការប្រជុំមុនវាយទីក្រុងភ្នំពេញហ្នឹង ទៅដល់លោកដែរឬទេ?

**ឆ៖** សូមទោសលោកសួរម្តងទៀត។ តើសំណួរ វៃទីក្រុងភ្នំពេញ តើខាងវៀតណាមវៃចូលភ្នំពេញ ឬមួយក៏កងទ័ពកម្ពុជាប្រជាធិបតេយ្យវៃភ្នំពេញ? អានេះសូម -- សំណួរលោកនិយាយឲ្យច្បាស់។

**សៈ** អរគុណលោក នង សុផង់។ ខ្ញុំចង់បានអ៊ីចឹង ប្រសិនបើមិនច្បាស់សូមលោកប្រាប់ខ្ញុំវិញមក ខ្ញុំនឹងសួរសាថ្មី។ បាទ អរគុណ។ ខ្ញុំចង់សួរថា មុនឆ្នាំ៧៥ គឺនៅក្នុងសាធារណរដ្ឋ ដែលមាន លន់ នល់ គ្រប់គ្រងទីក្រុងភ្នំពេញ ហើយមុនពេលដែលកម្ពុជាប្រជាធិបតេយ្យ វាយយកទីក្រុងភ្នំពេញ វាត្រូវមានសារបញ្ជូនគ្នាទៅវិញទៅមក ស្តីពីការវាយទីក្រុងភ្នំពេញ ស្តីពីការគ្រប់គ្រង និងការជម្លៀសប្រជាជនជាច្រើនម៉ឺននាក់នៅទីក្រុងភ្នំពេញ។ ខ្ញុំចង់សួរថាតើលោកបានទទួលសារ ឬក៏ដំណឹងនេះទេបាទ?

[១២:០៣:៥០]

**ផៈ** បាទ អំពីការរៀបចំវ៉ៃរំដោះក្រុងភ្នំពេញពីលោក លន់ នល់ ខ្ញុំបានទទួលសារ ហើយនិងធ្លាប់បានទទួលការណែនាំ អំពីការរៀបចំឲ្យកងទ័ពយើងវ៉ៃខាងណាៗ អីខាងណាៗ គឺកាលហ្នឹងគឺ មានការរៀបចំជាផែនការ រៀបចំជាអាវុធគ្រាប់រំសេវ ហើយនិងខាងមូលដ្ឋាន ក៏មានសំណើសុំដែរ។ សំណើសុំអាវុធគ្រាប់រំសេវអី ដើម្បីវ៉ៃឲ្យមានប្រសិទ្ធភាពហ្នឹង អានេះគឺធ្លាប់មាន ធ្លាប់បានឃើញ។ ប៉ុន្តែអំពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ខ្ញុំមិនដែលបានឃើញសារអ្វីទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណតំណាងសហព្រះរាជអាជ្ញា។

ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងពីររសៀលទើបអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់ទីកន្លែងសម្រាកដល់សាក្សីរូបនេះ សម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីក្នុងអំឡុងពេលឈប់សម្រាកអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងពីររសៀល។

អង្គជំនុំជម្រះសូមជម្រាបជូនភាគីនិងសាធារណជនជ្រាបថា នៅរសៀលថ្ងៃនេះ ហេតុដែលអង្គជំនុំជម្រះនឹងធ្វើសវនាការដោយចាប់ផ្តើមពីម៉ោងពីរ ដោយហេតុនៅរសៀលនេះក្នុងអំឡុងពេលឈប់សម្រាកពិសាថ្ងៃត្រង់ ថ្ងៃនេះជនជាប់ចោទ អៀង សារី នឹងត្រូវទទួលនូវការត្រួតពិនិត្យសុខភាពពីសំណាក់អ្នកជំនាញខាងជំងឺមនុស្សចាស់។ អ្នកជំនាញត្រូវការពេលវេលាសមស្របក្នុងការបំពេញការងាររបស់ខ្លួន។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១២:០៦:០១]

**លោក អេនគ្រូ អ៊ីទ្ធហ្ស៊ីះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ ខ្ញុំងើបឡើងដើម្បីជម្រាបអង្គជំនុំជម្រះថា កូនក្តីរបស់ខ្ញុំគាត់មានបញ្ហាឈឺក្បាល ឈឺខ្នង ឈឺចង្កេះ ហើយមិនមានផ្តង់អារម្មណ៍បាន។ ហេតុដូច្នេះគាត់សុំអនុញ្ញាតថា តាមដានកិច្ចដំណើរការកិច្ចដំណើរការនីតិវិធីពីបន្ទប់ខាងក្រោម ហើយយើងនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិជូនទៅអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំះ**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈពេលមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការនៅរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាព។

អង្គជំនុំជម្រះសម្រេចយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ដោយរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមកិច្ចដំណើរសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងពីររសៀល។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៨ នាទី ដល់ម៉ោង ១៤:១៧ នាទី)*

[១៤:១៧:២១]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** សួស្តីលោក នង សុផង់ ជាថ្មីម្តងទៀត។ កាលពីព្រឹកមិញ លោក នង សុផង់ បានផ្តល់ព័ត៌មានមកដល់ការិយាលសហព្រះរាជអាជ្ញាជាច្រើនហើយ។ ឥឡូវនេះ ខ្ញុំសូមបន្តសំណួរទៅលោកបន្ថែមទៀត។ ខ្ញុំសួរថា តើនៅមុនឆ្នាំ១៩៧៥ លោកបានដឹងទេនៅតាមភូមិភាគដែលគ្រប់គ្រងដោយកងទ័ពខ្មែរក្រហម នៅពេលនោះគេមានបង្កើតមន្ទីរសារទូរលេខដែរទេបាទ?

**លោក នង សុផង់៖**

**ផ៖** បាទ ចំពោះសំណួរនេះ គឺនៅគ្រប់មូលដ្ឋាន ភូមិភាគ និងតំបន់ ព្រមទាំងអង្គភាពកងពលគឺសុទ្ធតែមានការរៀបចំវិទ្យុទាក់ទង និងវិទ្យុទូរលេខគ្រប់ភូមិភាគ គ្រប់កងពលបាទ។

[១៤:១៩:៥៧]

**ស៖** អរគុណលោក។ សំណួរបន្ទាប់ទៀត នៅមុនឆ្នាំ១៩៧៥ ដដែល តើលោកធ្លាប់បានទទួលសារទូរលេខពីបរទេសដែរទេបាទ?

**ផ៖** បាទ មុនឆ្នាំ៧៥ មិនមានសារទូរលេខពីបរទេសទេបាទ។ តែក៏ខ្ញុំក្តាប់មិនបានទេ មិនដឹងជាមាន ឬមិនមាន តែចំពោះមុខសញ្ញាដែលខ្ញុំទទួលគឺអត់មានទេណ៎ា គឺអត់មានទេ។

**ស៖** ឥឡូវនេះខ្ញុំបន្តសំណួរក្រោយឆ្នាំ៧៥ គឺក្រោយថ្ងៃ១៧ មេសា ៧៥។ សួរ -- ខ្ញុំសួរថាតើលោកមកភ្នំពេញនៅពេលណា?

**ឆ៖** បាទ ខ្ញុំមកពេលភ្នំពេញ គឺពេលដែលគេរៀបចំស្រួលបួលហើយ គឺពេលចុងឆ្នាំ៧៥ ហើយបានខ្ញុំរើកន្លែងរបស់ខ្ញុំមកភ្នំពេញបាទ។

**ស៖** ខ្ញុំចង់ដឹងថា អ្នកណាបញ្ជាលោកឲ្យចូលមកទីក្រុងភ្នំពេញ? ហើយនៅក្នុងស្ថានភាពនោះលោកបានឃើញទីក្រុងភ្នំពេញមានលក្ខណៈយ៉ាងដូចម្ដេចដែរបាទ?

[១៤:២២:១៥]

**ឆ៖** បាទ លោក ប៉ុន ជាមេក្រុមរបស់ខ្ញុំដែលគាត់ជាអ្នកបញ្ជា ហើយចាត់ចែងឲ្យខ្ញុំមកភ្នំពេញបាទ។ ពេលដែលខ្ញុំមកដល់ភ្នំពេញ គឺភ្នំពេញមានសភាពស្ងាត់ មិនមានប្រជាជនទេបាទ មិនមានប្រជាជនច្រើនកុះករដូចឥឡូវហ្នឹងទេបាទ។

**ស៖** អរគុណលោក សុផង់។ នៅពេលដែលចូលមកដល់ទីក្រុងភ្នំពេញ លោកមានប្រសាសន៍អម្បាញ់មិញថា ប្រហែលជាចុងឆ្នាំ៧៥ តើលោកនៅទីតាំងកន្លែងណាដែរបាទ?

**ឆ៖** បាទ ទីតាំងការិយាល័យរបស់ខ្ញុំ គឺនៅកន្លែងសាលារៀនសម្ដេច សុធារស បាទ។

**ស៖** លោកមានមុខងារធ្វើអ្វីដែរនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំជាគ្រូបង្រៀន និងទទួលការងារខាងបណ្ដុះបណ្ដាល។ បណ្ដុះបណ្ដាលឲ្យកុមារដែលគេបញ្ជូនពីបណ្ដាខេត្តមកឲ្យមានចំណេះដឹងខាងលេខ ខាងអក្សរ រហូតដល់ចេះវ៉ៃអង្គុលីលេខ ហើយនិងបង្រៀនឲ្យគេចេះភាសា -- អក្សរឡាតាំង បារាំង អង់គ្លេសអីខ្លះ។ ហើយព្រមជាមួយនេះ ក៏ជាបណ្ដើរៗ គឺបង្រៀនគេឲ្យបកប្រែសារទូរលេខសម្ងាត់។ ហើយក្រៅពីការបង្រៀន ពេលដែលខ្ញុំចប់ពីភារកិច្ចបង្រៀន គឺខ្ញុំមានទទួលការបកប្រែសារទូរលេខ ដែលខាងលោក ប៉ុន ចាត់ចែងមកឲ្យខាងក្រុមខាងខ្ញុំនៅក្រៅនេះបាទ។

[១៤:២៥:០៧]

**ស៖** ពេលដែលលោកបង្រៀនសិស្សកូនក្មេងតូចៗនេះ តើកូនក្មេងនេះអាយុប៉ុន្មាន? ទី១។ អាយុប្រហែលជាប៉ុន្មាន? ហើយបង្រៀនសារទូរលេខសម្ងាត់នេះ ក្នុងគោលដៅអីច្បាស់លាស់ដែរ ពេលនុំងលោកដឹងដំណឹងទេបាទ?

**ឆ៖** បាទ ការបង្រៀនពេលនោះ គឺគោលដៅដែលបង្រៀនគឺដើម្បីកុមារទាំងអស់នោះមានជំនាញក្នុងការប្រកប ក្នុងការបម្រើការងារទៅអនាគត ខាងផ្នែកបកប្រែសារទូរលេខ ហើយក៏ដូចជាចេះខាងជំនាងខាងវ៉ៃអង្គុលីលេខ ដើម្បីទាំងអស់ហ្នឹង គឺថាគេមានជំនាញទៅ គេអាចយកទៅបម្រើ

ការងារទៅតាមការចាំបាច់ដែលអង្គការតម្រូវការ។ ហើយម្យ៉ាងវិញទៀតកុមារទាំងអស់ហ្នឹង គឺភាគច្រើនអាយុពី១២ឆ្នាំៗ ១០ទៅ១២ឆ្នាំបាទ។

[១៤:២៦:៥៤]

**ស៖** ខ្ញុំចង់បញ្ជាក់បន្តិចដែរ ពីព្រោះរៀនសារទូរលេខនេះ ហើយកូនក្មេងអាយុ ១០ ទៅ១២ឆ្នាំ គឺសារទូរលេខជាលេខសម្ងាត់ តើគោលបំណងបម្រើជនស៊ីវិល ឬក៏បម្រើយោធាបាទ?

**ឆ៖** បាទ ខ្ញុំពេលនុំងគឺមិនដឹងទិសដៅអីច្បាស់លាស់ទេ។ អង្គការណែនាំឲ្យខ្ញុំមានភារកិច្ចបណ្ដុះបណ្ដាល ខ្ញុំមានភារកិច្ចតែបណ្ដុះបណ្ដាល។ ពេលណាដែលគេមានជំនាញហើយ អង្គការចាំបាច់ត្រូវប្រើខាងយោធាក៏ខ្ញុំមិនដឹង ខាងស៊ីវិលក៏ខ្ញុំមិនដឹង។ ហ្នឹងតាមតែតម្រូវការរបស់អង្គការ។

**ស៖** អរគុណលោក។ ខ្ញុំនឹងបន្តសំណួរទៅបន្ទាប់ទៀត។ ក្រៅពីការបង្រៀន តើលោកមានធ្វើអ្វីផ្សេងពីនេះទេ? អម្បាញ់មិញលោកប្រាប់ថា ក្រៅពីការបង្រៀនលោកបកប្រែសារ។ ហើយខ្ញុំសួរភ្ជាប់ទៅនឹងសំណួរនេះ តើបុគ្គលិកនៅក្រោមបង្គាប់របស់លោកមានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ បុគ្គលិកដែលអាចធ្វើការងារបាន ដែលក្រោយពីខ្ញុំបណ្ដុះបណ្ដាលទៅ គឺមានបានតែបួនដប់នាក់ទេ ដែលអាចមានសមត្ថភាព។ កុមារវាមានច្រើន មានកាលហ្នឹងដូចជា៤០នាក់អីប្លាយ។ តែអ្នកដែលអាចធ្វើការបាន ជួយធ្វើការងារបកប្រែបានគឺមានចំនួនតែបួនដប់នាក់ទេ។

**ស៖** នៅពីក្រោមលោកបួនដប់នាក់ ឬក៏ដែលលោកប្រើការនេះ។ ចុះនៅពីលើលោកវិញ អ្នកណាខ្លះ លោកអាចជម្រាបបានទេ?

**ឆ៖** បាទ អ្នកគ្រប់គ្រងនៅពីលើខ្ញុំ គឺលោក ប៉ុន ហើយនិង ថេរ បាទ។

**ស៖** ខ្ញុំចង់ដឹងឲ្យច្បាស់ផងដែរថា ក្រៅពីបកប្រែសារទូរលេខ តើលោកវាយសារទូរលេខហ្នឹងដោយខ្លួនឯងដែរទេបាទ?

[១៤:៣០:១៥]

**ឆ៖** ខ្ញុំមិនអាចវាយបញ្ជូនសារទូរលេខដោយខ្លួនឯងបានទេបាទ។

**ស៖** អរគុណ។ ខ្ញុំនៅតែសំណួរចុងក្រោយមួយទៀតទេ ហើយបន្ទាប់មក ក្រុមការងាររបស់ខ្ញុំនឹងសួរលោកបន្ត។ ខ្ញុំចង់ដឹងថា តើប្រធានមន្ទីរសារទូរលេខនៅមជ្ឈិមហ្នឹង -- នៅភ្នំពេញហ្នឹងអ្នកដែរបាទ?

**ឆ៖** បាទ ប្រធានដែលគ្រប់គ្រងសារទូរលេខដែលនៅពីលើខ្ញុំ គឺមានលោក ប៉ុន ហើយនិង ថេរ។

គាត់ជាអ្នកធំជាងគេនៅខាងផ្នែកហៅថាទូរគមនាគមន៍របស់កម្ពុជាប្រជាធិបតេយ្យនៅពេលនោះបាទ។

**លោក វ៉េង ហ៊ាត់៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ អរគុណ។

[១៤:៣១:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សួស្តីក្រុមប្រឹក្សាជំនុំជម្រះ ភាគីមេធាវីទាំងអស់ និងសូមសួស្តីលោក នង សុផង់។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អនុញ្ញាតឲ្យខ្ញុំថ្លែងអំណរគុណលោក ក្នុងនាមជា -- ក្នុងនាមការិយាល័យសហព្រះរាជ-អាជ្ញា ដែលលោកបានធ្វើដំណើរមកជួយផ្តល់បង្ហាញអំពីការងាររបស់លោក ពាក់ព័ន្ធនៅក្នុងរយៈកាលឆ្នាំ៧៥ និង៧៩ ហើយសូមអរគុណលោកផងដែរ ដែលលោកមកជួយបង្ហាញនូវការពិត។

ខ្ញុំនឹងចាប់ផ្តើមសំណួររបស់ខ្ញុំ ជាបឋមនោះគឺ ខ្ញុំសូមឲ្យលោកបញ្ជាក់បំភ្លឺខ្លីៗទៅលើទីតាំងមួយចំនួនដែលលោកបានលើកឡើងរួចមកហើយ។ បន្ទាប់មកខ្ញុំនឹងបន្តសួរសំណួរពាក់ព័ន្ធទៅនឹងការងាររបស់លោកនៅក្នុងក្រុងភ្នំពេញ ឲ្យមានលក្ខណៈលម្អិតជាងមុន។

លោកបានពន្យល់ជូនយើងខ្ញុំមុននេះថា មានលិខិតទំនាក់ទំនងតាមរយៈសារទូរលេខពីមូល -- ពីភូមិភាគទៅ -- ពីភូមិភាគ ពីសមរភូមិនេះបញ្ជូនឡើងទៅថ្នាក់លើ ហើយលោកក៏បានជួយក្នុងការបកប្រែសារទូរលេខទាំងអស់នោះផងដែរ។ សំណួររបស់ខ្ញុំដំបូងនេះ ខ្ញុំសូមសួរលោកថា តើលោកៗនឹកឃើញដែរឬទេ ភូមិភាគណាខ្លះដែលបានរាយការណ៍ទៅថ្នាក់លើនោះ ក្នុងពេលដែលលោកធ្វើការងារនៅទីនោះ?

[១៤:៣៤:១៤]

**លោក នង សុផង់៖**

**ឆ៖** បាទ សូមអរគុណ។ ភូមិភាគ ហើយនិងកងទ័ពដែលបានរាយការណ៍មកខាងលើនេះមានបណ្តាញទាក់ទងកាលមុន៧៥ លោកៗសួរមុន៧៥ សូមបញ្ជាក់ម្តងទៀត។ មុន៧៥ ឬមួយក៏៧៥

ហើយបាទ?

**ស៖** បាទ ជាការពិត គឺរយៈកាលមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។

**ឆ៖** អូខេ។ មុនឆ្នាំ៧៥ អង្គភាពដែលមានការទាក់ទងជាមួយខាងលើនេះមាន ភូមិភាគពិសេស ភូមិភាគបូព៌ា ភូមិភាគឧត្តរ ភូមិភាគឦសាន ភូមិភាគពាយ័ព្យ ភូមិភាគនិរតី ភូមិភាគបស្ចិម ហើយនិងតំបន់ស្វយ័តបីទៀតគឺព្រះវិហារ មណ្ឌលគិរី និងសៀមរាប-ឧត្តមានជ័យ។ ឯផ្នែកកងទ័ពគឺមានតែឯកឧត្តម សុន សេន មួយទេដែលឡើងត្រង់ទាក់ទងមកខាងលើនេះបាទ។ ក្រៅពីហ្នឹងកងពលទាំងអស់មិនមានសិទ្ធិឡើងត្រង់មកខាងមជ្ឈិមទេ។

**ស៖** សូមអរគុណច្រើនដែលលោកបានឆ្លើយយ៉ាងលម្អិត។ ពាក់ព័ន្ធទៅនឹងភូមិភាគ ត្រឡប់មកនិយាយអំពីភូមិភាគវិញ តើលោកអាចយល់សារទូរលេខនោះដោយរបៀបណា? ឧទាហរណ៍ថា សារទូរលេខនោះមកពីភូមិភាគបូព៌ា តើលោកដឹងដោយរបៀបណាទៅសារមួយចំនួននោះមកពីភូមិភាគបូព៌ា? ខ្ញុំសួរនេះគឺអំឡុងមុនឆ្នាំ៧៥ដដែលលោក។

[១៤:៣៧:០៧]

**ឆ៖** បាទ សារទូរលេខសុទ្ធតែមានលេខកូដសម្ងាត់។ សារទូរលេខដែលគេបញ្ជូនមក គឺសុទ្ធតែជាលេខទាំងអស់ តែគេមានក្បាលរបស់គេ។ មុនដំបូងគេដាក់ “NR” ប៉ុន្មានទៅ ហើយបន្ទាប់មកទៀតគេដាក់ “CK” បានសេចក្តីថា “CK” ហ្នឹងគឺជាចំនួនខ្ទង់សារទូរលេខ បន្ទាប់មកទៀតគេដាក់ “ចុះកាលបរិច្ឆេទថ្ងៃខែឆ្នាំ” ហើយចុងបំផុត គេដាក់ “ទិស” តាមលេខកូដដែលគេបានកំណត់។ ឧទាហរណ៍ភូមិភាគបូព៌ាលេខកូដសម្ងាត់គេដាក់ “ទិសA75” អេ អក្សរ “A” -- “A75” បាទ។ ពេលដែលឃើញ “A75” គឺបានន័យថា “ភូមិភាគបូព៌ា” បាទ។

**ស៖** សូមអរគុណ។ តើនរណាគេជាអ្នកដាក់លេខកូដនោះ? ឧទាហរណ៍ថា លេខកូដ “A75” នេះសម្រាប់ភូមិភាគបូព៌ា ហើយលេខកូដផ្សេងទៀតនោះ សម្រាប់ភូមិភាគផ្សេងនោះ តើនរណាគេជាអ្នកដាក់លេខកូដនេះ?

[១៤:៣៨:៥៤]

**ឆ៖** បាទ លេខកូដទាំងអស់នុ៎ង គឺខ្ញុំជាមួយនឹង ប៉ុន បានរួមគ្នាដាក់លេខកូដទាំងអស់នេះពិភាក្សាគ្នាទៅសម្រេចថា ឯកសារ -- លេខសម្ងាត់ទិសរបស់បូព៌ាហ្នឹង គឺយើងដាក់“A75” ឧទាហរណ៍អ៊ីចឹង។ តែខ្ញុំ -- ជាក់ស្តែងខ្ញុំមិនចាំទេ អង្គាល់នុ៎ងមិនដឹងជាប៉ុន្មានទេ។ នេះជាឧទាហរណ៍ទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនតូចពាក់ព័ន្ធទៅនឹងរយៈកាលមុនខែមេសា ឆ្នាំ១៩៧៥ នេះដដែល តើលោកអាចជម្រាប និងនឹកឃើញដែរឬទេថា ជាមធ្យមនោះតើញឹកញយប៉ុនណាដែលភូមិភាគនីមួយៗនោះ រាយការណ៍ឡើងទៅថ្នាក់លើនោះ?

**ឆ៖** បាទ អំពីសារទូរលេខដែលភូមិភាគទាក់ទងញឹកញាប់ មិនញឹកញាប់ វាអាស្រ័យទៅលើសភាពការណ៍របស់ភូមិភាគនោះ ដែលមានសកម្មភាពប្រយុទ្ធគ្នា។ បើភូមិភាគណាដែលមានការប្រយុទ្ធគ្នាខ្លាំង មានទូរលេខ២៤ម៉ោង បាទ គឺជាប់សួរ ឯភូមិភាគណាដែលបានរំដោះហើយ កន្លែងរំដោះហើយមិនសូវមានទេ។ ជាក់ស្តែង គឺកាលហ្នឹង គឺខ្លាំងជាងគេ គឺសមរភូមិជុំវិញភ្នំពេញ ភូមិភាគពិសេស ភូមិភាគបូព៌ា ញឹកញាប់ណាស់លោក២៤ម៉ោងពេញ២៤ម៉ោងតែម្តង ហើយនិងខាងអគ្គមេ-បញ្ជាការកងទ័ព សុន សេន ហ្នឹងក៏ ២៤ម៉ោងពេញតែម្តង បាទ។

[១៤:៤១:៣៦]

**ស៖** នៅក្នុងរយៈកាលនោះ ប្រសិនបើយើងមើលទូរលេខវិញ ជាមធ្យមនោះ តើមានសារទូរលេខចូលមកចំនួនប៉ុន្មាន ដែលលោកបានធ្វើការបកប្រែក្នុងមួយថ្ងៃនោះ ជាមធ្យម? ហើយតើមានសារទូរលេខប៉ុន្មានដែរជាមធ្យមនោះ ដែលផ្ញើចេញទៅខាងក្រៅនោះ តាមអ្វីដែលលោកចាំនោះ?

**ឆ៖** បាទ ខ្ញុំចាំមិនបានអស់ទេ ពីព្រោះថា កាលកន្លងមកនេះវា -- ញឹកញាប់ជាងគេ គឺដែលច្រើនជាងគេ គឺដូចខ្ញុំបានជម្រាបលោកខាងលើហើយ គឺថាវាច្រើនណាស់ ពេលខ្លះពួកខ្ញុំត្រូវធ្វើទាំងយប់ទាំងថ្ងៃ ទាល់ភ្លឺក៏មានដែរ អំ! មួយយប់ទាល់ភ្លឺក៏មានដែរ មិនបាន -- សម្រាកបានតិចតួចទេបាទ។

**ស៖** ចំពោះសារទូរលេខដែលបញ្ជូនចេញទៅថ្នាក់លើនោះ តើគឺវាដូចគ្នាទៅនឹងការងារដែលលោកធ្វើសារទូរលេខ ចំពោះសារទូរលេខដែលផ្ញើទៅកាន់ភូមិភាគនីមួយៗដូចគ្នា និងវាដូចទៅនឹងសារទូរលេខដែលលោកផ្ញើទៅកាន់ខាងយោធាហ្នឹង ដូចដែលលោកបានលើខាងដើមហ្នឹង ឬក៏យ៉ាងម៉េច?

[១៤:៤៣:៣៤]

**ឆ៖** សូមអត់ទោស សូមមានប្រសាសន៍ម្តងទៀត បាទ សំណួរហ្នឹង គឺខ្ញុំមិនសូវយល់បាទ។

**ស៖** សូមអធ្យាស្រ័យវាឲ្យលោកពិបាកយល់។ លោកនិយាយអំពីសារទូរលេខដែលផ្ញើចូលមក ហើយលោកបានបញ្ជាក់ថា សារទូរលេខទាំងអស់នោះ គឺបានផ្ញើមកពីភូមិភាគនានា។ ដូច្នេះ ខ្ញុំសូមសួរលោក តើមានសារទូរលេខផ្ញើពីប-២០ នោះ ទៅតាមភូមិភាគ និងទៅតាមតំបន់ដែរឬទេ តាមការចងចាំរបស់លោក?

**ឆ៖** បាទ ការនាំចេញមិនសូវមានញឹកញាប់ទេ មានតិចទេ មានតិចជាងសារចូលបាទ។

**ស៖** យើងបន្តពេលវេលាទៅមុខទៀត គឺរយៈកាលខាងមុខៗ លោកបានរៀបរាប់ថា មានពេលមួយនោះ អង្គភាពរបស់លោកនេះ ត្រូវបានបំបែកជាពីរក្រុម។ ក្រុមមួយនោះនៅប-២០ ដដែល ដែលលោកធ្វើការនៅប-២០ នុ៎ង។ ហើយមួយក្រុមទៀតដែលមាន ប៉ុន ធ្វើការងារនៅក្នុងហ្នឹងគឺ បានបញ្ជូនទៅសមរភូមិមុខខាងលិចភ្នំពេញ។ តើលោកចាំទេ ការបំបែកជាពីរក្រុមនេះ នៅមុនឆ្នាំ៧៥ ចុងឆ្នាំ -- មុនឆ្នាំ៧៤ ចុងឆ្នាំ៧៤ ឬក៏នៅដើមឆ្នាំ៧៥ តាមការចងចាំរបស់លោកទៅលើពេលវេលានោះ?

[១៤:៤៥:៤១]

**ឆ៖** បាទ ការបំបែកជាពីរក្រុមនេះ គឺនៅចុងឆ្នាំ៧៤ ហើយបាទ។

**ស៖** នៅពេល ប៉ុន ចាកចេញទៅដឹកនាំក្រុមនៅខាងលិចភ្នំពេញនោះ តើលោកនឹកឃើញទេគាត់បានទៅជាមួយនរណាដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថា ប៉ុន ហ្នឹងគឺនៅជាប់ផ្ទាល់ជាមួយលោក ប៉ុល ពត។ ដូច្នេះលោក ប៉ុល ពត ទៅទីណា ក៏យក ប៉ុន ទៅទីនោះដែរបាទ។

**ស៖** នៅពេល ប៉ុន ចាកចេញទៅ តើលោកដឹងទេខាងលិចភ្នំពេញហ្នឹង គឺនៅម្តុំត្រង់កន្លែងណាដែរ ដែលគាត់ទៅធ្វើការងារនៅទីនោះ នោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹង អត់ស្គាល់ទេបាទ។

**ស៖** សូមអរគុណលោកច្រើន។ ក្រោយពេល ប៉ុន ចេញទៅក្នុងចុងឆ្នាំ៧៤ តើ ប៉ុល ពត ឬក៏គាត់ហ្នឹងនៅតែអាចបញ្ជូនសារទូរលេខ ពីទីតាំងថ្មីរបស់គាត់នៅខាងលិចភ្នំពេញហ្នឹងមកលោកដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ព្រោះខ្ញុំ -- ផ្នែកខាងក្រោយ គឺខ្ញុំ។ ផ្នែកខាងមុខគឺ ប៉ុន។ អ្វីដែល ប៉ុល ពត ចង់បញ្ជូនមកខាងខ្ញុំ គឺលោកមានសិទ្ធិទាក់ទងជាមួយខ្ញុំ២៤ម៉ោងបាទ។

[១៤:៤៨:២៣]

**ស៖** តើ ប៉ុន នោះធ្វើទំនាក់ទំនងជាមួយលោកដោយរបៀបណា? តាមរយៈសារទូរលេខ ឬដោយមធ្យោបាយផ្សេង?

**ឆ៖** បាទ ការទាក់ទងជាមួយ ប៉ុន គឺតាមរយៈសារទូរលេខសម្ងាត់ មិនមែនមានទូរស័ព្ទដូចសម័យនេះទេ គឺបញ្ជូនតាមវិទ្យុទាក់ទង តិចៗតាហ្នឹងហើយ ហើយគេបញ្ជូនជាលេខមកខាងខ្ញុំហ្នឹងទេ

ហើយខ្ញុំក៏ទទួលពី ប៉ុន ហ្នឹងមានពីរប្រភេទ។ ទី១ ជាសារសម្ងាត់ជាលេខ។ ទី២ ជាដំណឹងជ័យជម្នះដែលបានទទួលពី ដែលខាងមុខហ្នឹង ខាង ប៉ុន ហ្នឹងគេប្រមូលបានពីសមរភូមិនានា ដើម្បីយកមកឲ្យខាងខ្ញុំនៅក្រោយនេះបញ្ជូនទៅវិទ្យុផ្សាយសំឡេងបាទ។

[១៤:៤៩:៤១]

**ស៖** ខ្ញុំចង់សួរសំណួរបន្តទៀត តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា នៅពេលដែលទទួលបានជ័យជម្នះនោះ នៅពេលទទួលបានជ័យជម្នះនៅក្នុងទីក្រុងភ្នំពេញនោះ ការធ្វើទំនាក់ទំនងធ្វើឡើងតាមរយៈសារទូរលេខ ដោយមានលេខកូដសម្ងាត់ ហើយបន្ទាប់មកលោកនេះជាអ្នកធ្វើការបកប្រែលេខកូដសម្ងាត់នោះ ដើម្បីយកព័ត៌មាននៅក្នុងសារទូរលេខទាំងអស់នោះនៅទៅផ្សាយតាមវិទ្យុ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ សូមទោសអានេះ វាខ្សោយណាស់ ខ្ញុំស្ដាប់មិនសូវបាន។

*(មន្ត្រីតុលាការប្ដូរឧបករណ៍សំឡេងជូនសាក្សី)*

[១៤:៥០:៥៣]

**ស៖** ខ្ញុំនឹងសួរសំណួររបស់ខ្ញុំឡើងវិញ សូមអរគុណ។ ខ្ញុំគិតថា លោកបាននិយាយថា ប៉ុន ទំនាក់ទំនងមកកាន់លោក តាមរយៈសារទូរលេខ តាមលេខកូដសារទូរលេខពាក់ព័ន្ធទៅនឹងជ័យជម្នះនៅសមរភូមិ។ បន្ទាប់មកនោះ លោកធ្វើការបកប្រែលេខកូដនោះដើម្បីយកទៅផ្សព្វផ្សាយតាមវិទ្យុ។ ដូច្នេះខ្ញុំសួរលោក តើនៅពេលដែលលោកបកប្រែនោះ គឺលោកបកប្រែសារទូរលេខសម្ងាត់ពាក់ព័ន្ធទៅនឹងជ័យជម្នះថ្ងៃ១៧ មេសា ឬក៏សារទូរលេខផ្សេងទៅវិញទេ?

**ឆ៖** បាទ រឿងទូរលេខ វាមានបែងចែកជាសារទូរលេខ បែងចែកជាពីរប្រភេទ គឺទូរលេខសម្ងាត់ និងសារចំហ។ សារដែលជាដំណឹងជ័យជម្នះពីសមរភូមិ គេមិនបាច់ធ្វើជាលេខសម្ងាត់ទេបាទ គេវ៉ៃជា *ម័ស* ឧទាហរណ៍ តិតិតា ចេញជាអក្សរ “ក” តែម្ដងបាទ។ ដូច្នេះ ខ្ញុំមិនចាំបាច់ធ្វើការបកប្រែអ្វីទៀតទេ គឺបានទទួលដំណឹងហ្នឹងជាអក្សរខ្មែរផ្ទាល់តែម្ដងបាទ។

[១៤:៥២:៣៦]

**ស៖** សូមអរគុណច្រើនដែលលោកបានបញ្ជាក់បំភ្លឺ។ តើលោកនឹកឃើញដែរឬទេ ទៅលើសារទូរលេខនេះ តើលោកនៅចាំទេ តើសារទូលេខដែលលោកលើកឡើងអម្បាញ់មិញនេះគឺ លោកជាអ្នកទទួលដោយផ្ទាល់ បន្ទាប់មកយកទៅផ្សព្វផ្សាយអំពីការទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា -- ១៧

មេសានោះ ឬក៏គេផ្សាយនាពេលក្រោយទេ?

**ឆ៖** បាទ ធម្មតាវាមិនសូវលឿនប៉ុន្មានទេសម័យហ្នឹង មិនសូវជាទំនើបទេ ដូច្នេះការផ្សព្វផ្សាយវាមិនបានទាន់ -- ឧបមាថា ថ្ងៃ១៧ មេសា ខ្ញុំចាំទាំងម៉ោងទៀត ម៉ោងប្រាំបួនកន្លះទៀត តែការបញ្ជូនសារមកដល់កន្លែងខ្ញុំ វាមិនបានម៉ោងប្រាំបួនកន្លះទេ វាអត់ម៉ោងដប់ ម៉ោងអីហើយ ម៉ោងដប់ជាងទៅហើយ។ ហើយអ៊ីចឹងទម្រាំខ្ញុំរៀបចំសំបុត្រស្នាមអីទៅខាងវិទ្យុផ្សាយសំឡេងហ្នឹង វាមិនបានទាន់ម៉ោងប្រាំកន្លះដូចសភាពការណ៍នៅសមរភូមិហ្នឹងទេ អ៊ីចឹងអារឿងហ្នឹងហើយដែលគេស្តីបន្ទោសឲ្យខ្ញុំថា "ខ្ញុំហ្នឹងវាធ្វើការយឺតយ៉ាវហ្នឹង ឲ្យការផ្សាយដំណឹងជ័យជម្នះហ្នឹងមិនទាន់បានពេលវេលាហ្នឹង"។ រៀបចំវាមិនទាន់ម៉ោងប្រាំបួនកន្លះឈ្នះ ហើយផ្សាយឯណាទាន់ដល់ម៉ោងប្រាំបួនកន្លះហ្នឹង ទាល់តែមានម៉ោងដប់មួយបានវិទ្យុផ្សាយសំឡេងម្តងទៀត។ តាមខ្ញុំចាំដូចជាម៉ោងដប់មួយបានផ្សាយដំណឹងជ័យជម្នះរំដោះក្រុងភ្នំពេញហ្នឹង។

[១៤:៥៣:៥៩]

**ស៖** យើងកំពុងតែពិភាក្សាថ្ងៃ កាលបរិច្ឆេទ ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ គឺចំណុច -- គឺថ្ងៃនុ៎ងហើយដែលសារទូរលេខហ្នឹងផ្សព្វផ្សាយហ្នឹងមែនទេលោក?

**ឆ៖** សូមទោស មិនមែនជាសារទូរលេខទេ គឺជាដំណឹងជ័យជម្នះបាទ គេហៅថា "ដំណឹងជ័យជម្នះ" ដូច្នេះមិនមែនជាសារទូរលេខសម្ងាត់ទេបាទ។ គឺជាដំណឹងជ័យជម្នះពីសមរភូមិៗភ្នំពេញបាទ។

[១៤:៥៥:៣០]

**ស៖** សូមអរគុណ។ មានសំណួរមួយទៀតពាក់ព័ន្ធទៅនឹងរយៈកាលមុនឆ្នាំ១៩៧៥។ នៅក្នុងចម្លើយដែលលោកបានឆ្លើយ លោកបានរៀបរាប់ពិពណ៌នាអំពីការចាត់តាំងឲ្យលោកទៅធ្វើការងារនៅក្នុងឆ្នាំ១៩៧៣ដោយ ប៉ង់ -- ដោយ ហង់។ ហើយការដែលចាត់តាំងការងារនេះ គឺវាពាក់ព័ន្ធនឹងថ្ងៃដប់ -- នៅមន្ទីរប-១៧។ ឯកសារនេះ គឺឯកសារ E3/64, ERNខ្មែរគឺមានលេខ 00328023, បារាំង ERN គឺលេខ 00411694, អង់គ្លេស ERN គឺ 00334042។ ខ្ញុំនឹងអានចំណុចដែលមាននៅក្នុងចម្លើយរបស់លោក ហើយតើលោកមានន័យយ៉ាងម៉េច? "នៅក្នុងឆ្នាំ១៩៧៣ គណៈតំបន់ព្រះវិហារឈ្មោះ ហង់ បានជ្រើសរើសខ្ញុំមកធ្វើការនៅគណៈមជ្ឈិមបក្សនៅប-១៧ ដែលជាកន្លែងលត់ដំ ដោយធ្វើការដូចជាបង្កបង្កើនផល"។ ខ្ញុំគ្រាន់តែចង់សួរលោក តើលោកដឹងដោយរបៀបណាថា ប-១៧ នេះគឺជាគណៈមជ្ឈិមបក្សនោះនៅពេលនុ៎ង? តើលោកដឹងដោយរបៀបណាដែរ?

**ឆ៖** បាទ ខ្ញុំពេលហ្នឹងដែលគេបញ្ជូនមក ខ្ញុំមិនបានដឹងថា ប-១៧ ជាកន្លែងមជ្ឈិមបក្សទេ។ ប៉ុន្តែខ្ញុំដឹងតាមលោក ហង់ ដែលមានទិសដៅគេអប់រំខ្ញុំថា ខ្ញុំហ្នឹងត្រូវគេបញ្ជូនទៅកន្លែងមជ្ឈិម។ អ៊ីចឹងខ្ញុំដើររយៈពេល១ខែ បានមកដល់កន្លែងប-១៧។ ហើយខ្ញុំមកដល់ប-១៧ហើយ ខ្ញុំអត់មានទៅណាទៀតទេ។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា អូ! ប្រហែលហ្នឹងហើយ ជាកន្លែងមជ្ឈិមហ្នឹង។

[១៤:៥៨:២២]

**ស៖** សូមអរគុណលោកច្រើន។ នៅពេលនេះ គឺខ្ញុំសូមបន្តទៅសួរពាក់ព័ន្ធទៅនឹងការងាររបស់លោកនៅក្នុងក្រុងភ្នំពេញ។ លោកបានពិពណ៌នាប្រាប់សហព្រះរាជអាជ្ញាជាតិរួចមកហើយថា ការងាររបស់លោកនៅក្នុងក្រុងភ្នំពេញ រួមមានសកម្មភាពពីរបែប។ ទី១ គឺការបង្រៀនក្មេងៗអាយុ ១២ឆ្នាំ នៅក្នុងតំបន់ដែលពាក់ព័ន្ធទៅនឹងការបកប្រែសារទូរលេខ។ ហើយសកម្មភាពការងាររបស់លោកមួយផ្នែកទៀតនោះ គឺដឹកនាំមន្ទីរបកប្រែសារទូរលេខ។ នៅពេលនេះ គឺខ្ញុំសូមសួរលោកអំពីការងារដែលលោកបង្រៀនក្មេងៗ តើក្មេងៗទាំងអស់នោះត្រឡប់មកមូលដ្ឋានវិញដែរឬទេ ក្រោយពេលដែលពួកគេទទួលបានការបណ្តុះបណ្តាលពីលោកហើយនោះ?

[១៤:៥៩:៥០]

**ឆ៖** បាទ ក្មេងៗទាំងអស់នោះ មួយចំនួនអង្គការតម្រូវឲ្យទៅជួយធ្វើការងារតាមមូលដ្ឋានដែលមិនមានជំនាញក្នុងការ -- ការងារទូរលេខ ការងារបកប្រែហ្នឹង ហើយមួយចំនួនទៀតដែលមិនមានហៅថា សមត្ថភាពគ្រប់គ្រាន់ក្នុងការបកសារទូរលេខ ខ្ញុំក៏បានឲ្យក្មេងៗទាំងអស់នោះទៅរៀនផ្នែកមួយទៀត គឺផ្នែកវាយ និងទទួលសារទូរលេខ បាទ ហើយខ្លះទៀតក៏អាចរៀនរហូតទៅដល់ទូរពុម្ព *ហ្វាក់*អីក៏មានដែរ នៅ -- ដែលខ្ញុំបញ្ជូនទៅ។ ហើយមួយចំនួនទៀតដែលអ្វីក៏មិនចេះ អ្វីក៏វាខ្សោយ ក៏បានឲ្យទៅរៀនខាងបច្ចេកទេសបើកបរឡាន បាទ។

**ស៖** ក្មេងៗ ដែលត្រូវបានគេបញ្ជូនមកមូលដ្ឋានវិញ ដើម្បីធ្វើការងារបកប្រែសារទូរលេខ។ តាមការចងចាំរបស់លោក តើក្មេងទាំងអស់នោះធ្វើការងារនៅតាមមន្ទីរបកប្រែសារទូរលេខនៅមូលដ្ឋានដែរឬទេ ដែលទទួលខុសត្រូវលើការបញ្ជូនសារទូរលេខទៅដល់មជ្ឈិមបក្សនៅក្នុងឆ្នាំ១៩៧៣ នោះ?

**ឆ៖** បាទ ខ្ញុំ តាមខ្ញុំចាំគឺមានក្មេងពីរនាក់ដែលបានបញ្ជូនទៅខាងភូមិភាគពិសាន។ មាននៅខាងមណ្ឌលគិរីម្នាក់ ហើយនិងខាងក្រចេះម្នាក់បាទ បានពីរនាក់ដែរ។ ក្រៅពីហ្នឹងភូមិភាគផ្សេងៗ គេ -- បើគេមិនមានជំនាញ គេបញ្ជូនមកឲ្យខ្ញុំណែនាំ រួចហើយគេយកអ្នកហ្នឹងទៅមូលដ្ឋានគេវិញ បាទ។

**ស៖** សូមអរគុណលោក។ ថាតើលោកធ្វើការបណ្ដុះបណ្ដាលជាលើកទី១ហ្នឹង គឺនៅពេលណាដែរ? លោកបាន១និយាយថាមកដល់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ៧៥ ថាតើលោកដំណើរការវគ្គបង្រៀនហ្នឹង គឺក្នុងពេលណាដែរ? នៅក្នុងឆ្នាំណាដែរ?

[១៥:០៣:០៧]

**ឆ៖** បាទ ខ្ញុំបង្រៀនពីរវគ្គបាទ។ ៧៦ ហ្នឹងបានមួយវគ្គ ហើយដល់ឆ្នាំពាក់កណ្ដាល៧៧ ហើយទេ បានមួយវគ្គទៀត។ បានតែពីរវគ្គទេ ក្នុងរយៈ៣ឆ្នាំហ្នឹងបាទ។

**ស៖** ប្រសិនបើលោកចាំ នៅក្នុងវគ្គបង្រៀនទាំងអស់នោះ តើលោកមានកម្មាភិបាលមកពីភូមិភាគនានានៅក្នុងទូទាំងប្រទេស ឬមួយក៏មានតែអ្នកមកពីភូមិភាគខ្លះៗទេ?

**ឆ៖** បាទ មិនមែនកម្មាភិបាលមកពីភូមិភាគមករៀនជាមួយខ្ញុំទេបាទ គឺជាកុមារ ឬមួយក៏ជាអ្នកបច្ចេកទេស ដែលគេទទួលភារកិច្ចខាងអក្សរសម្ងាត់ ដែលគេមករៀនជាមួយខ្ញុំបាទ។

**ស៖** សូមអរគុណ ដែលលោកបានកែនូវការប្រើប្រាស់ពាក្យរបស់ខ្ញុំ។ ឥឡូវនេះយើងនិយាយអំពីសំណួរនេះ គឺយើងនិយាយអំពីក្មេងៗ ដែលមកពីគ្រប់តាមភូមិភាគ ឬមួយក៏តើក្មេងៗទាំងអស់ហ្នឹងគាត់មកពីគ្រប់ភូមិភាគទាំងអស់ ឬមួយក៏មកពីភូមិភាគមួយចំនួនទេ?

[១៥:០៥:០៦]

**ឆ៖** បាទ តាមខ្ញុំក្ដាប់បានគឺមិនគ្រប់ទាំងអស់ទេ គឺមួយចំនួនទេបាទ មួយចំនួន។

**ស៖** សូមអរគុណលោក។ មុននឹងយើងបន្តទៅនឹងបញ្ហាការងារនៅក្នុងមន្ទីរសារទូរលេខ ខ្ញុំសូមសួរលោកនូវសំណួរមួយ។ លោកធ្វើការនៅប-២០ រហូតដល់ចុងឆ្នាំ៧៥។ ហើយបន្ទាប់មកលោកបន្តនៅការងារនៅការិយាល័យ ឬក៏នៅមន្ទីរបកប្រែសារទូរលេខ។ តាមដែលលោកដឹង តើមានការបញ្ជូន -- ថាតើមានមន្ទីរបកប្រែសារទូរលេខ ឬក៏មានមន្ទីរបញ្ជូនសារទូរលេខនៅទីក្រុងភ្នំពេញទេ គឺខ្ញុំនិយាយមុនពេលដែលមកដល់ទីក្រុងភ្នំពេញ? តើមានទេនៅទីក្រុងភ្នំពេញ?

**ឆ៖** បាទ ខ្ញុំមកទីក្រុងភ្នំពេញហ្នឹង វាជិតចុង៧៥ហើយ។ ដូច្នេះការរៀបចំមន្ទីរសារទូរលេខ មន្ទីរបកសារទូរលេខអី គឺគេរៀបចំមុនខ្ញុំអស់ហើយបាទ។ គឺមានក្រុម ប៉ុន ហ្នឹង គេមកចូលមុនខ្ញុំ។ អីចឹងគឺក្រុម ប៉ុន ចាត់ចែងហើយ ក្រុមទូរលេខ ត្រង់ណាបក ត្រង់ណាវ៉ៃ ត្រង់ណាអី គេរៀបចំមុនខ្ញុំអស់ហើយបាទ។

[១៥:០៧:២៣]

**សះ** តើលោកដឹងដែរឬទេ ថាតើតំបន់ ឬក៏ថាតើផ្នែកទាំងនោះត្រូវបានបង្កើតភ្លាមៗក្រោយពេលរំដោះភ្នំពេញ ឬក៏ត្រូវបានគេបង្កើតនៅពេលក្រោយមកទៀត? បានន័យថាបង្កើតភ្លាមៗ ឬក៏នៅពេលក្រោយមកទៀត? ប្រសិនបើលោកដឹង សូមជម្រាប បើលោកមិនដឹងទេ សូមឆ្លើយថាមិនដឹង។ សូមអរគុណ។

**ឆះ** បាទ សូមបញ្ជាក់គឺថា តំបន់ដែលរៀបចំភ្លាមៗហ្នឹង គឺលោកសំដៅថាអង្គភាពភូមិភាគតំបន់ដែលខ្ញុំនិយាយខាងដើមហ្នឹងឬ? បាទ អំពីការរៀបចំ អ៊ីចឹងគឺមិនមែនធ្វើភ្លាមៗនោះទេ គឺការរៀបចំបណ្ដាញទាក់ទងតាមភូមិភាគ តាមតំបន់ស្វយ័ត គឺវាមានលំនាំតាំងពីកាលសម័យតស៊ូរវើគ្នាជាមួយអាមេរិកាំងមកម្ល៉េះបាទ។

[១៥:០៨:៥៣]

**សះ** ឥឡូវនេះខ្ញុំសូមបន្តទៅលើបញ្ហានៃមន្ទីរជាច្រើនដែល ប៉ុន គាត់ជាអ្នកគ្រប់គ្រងនៅទីក្រុងភ្នំពេញ។ ដូច្នេះសូមឲ្យលោកជួយដល់យើងក្នុងការពិភាក្សានេះ ហើយខ្ញុំនឹងអានន្ទូវចម្លើយរបស់លោក ហើយខ្ញុំនឹងសួរសំណួរទាក់ទងទៅនឹងចម្លើយរបស់លោក។ ឥឡូវនេះ គឺយើងពិនិត្យមើលទៅលើឯកសារ E3/64 គឺមានលេខ ERN ដូចតទៅ ភាសាខ្មែរគឺមានលេខ 00328028, ភាសាបារាំងគឺមានលេខ 00411699, និងភាសាអង់គ្លេសគឺមានលេខ 00334049។ ដូច្នេះខ្ញុំសូមអានន្ទូវចម្លើយរបស់លោកដែលបានផ្ដល់ លោក សុផង់ "មន្ទីររបស់ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុន និង ធី។ ពួកគាត់គ្រប់គ្រងទៅលើការិយាល័យបញ្ជូនវិទ្យុ និងបញ្ជូនទូរសារ គឺនៅក្នុងអតីតមន្ទីរ -- អតីតស្ថានទូតអាមេរិកចាស់។

[១៥:១០:១៧]

ប៉ុន គឺជាប្រធានខាងទូរគមនាគមន៍ ហើយក្នុងនោះ គឺ -- ហើយនៅក្នុងនុំងគឺជាខាងវិទ្យុទាក់ទងនៅទូតអាមេរិកចាស់ ហើយមួយទៀត គឺផ្នែកបកប្រែទូរលេខនៅ ក-១ ដែលវាជាសាលារៀនរបស់ខ្ញុំ"។ ពិនិត្យមើលទៅលើមន្ទីរទាំងអស់នេះ តើយើងយល់ត្រឹមត្រូវដែរឬទេ ដែលថានៅទីនោះគឺមានផ្នែកបកប្រែសារទូរលេខចំនួនពីរ? ទី១ គឺនៅក្នុង ក-១ និងមួយទៀតគឺនៅក្បែរសាលារបស់លោក ថាតើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆះ** បាទ ត្រឹមត្រូវណាស់ ពីព្រោះថា មិនមែនក្បែរសាលារបស់ខ្ញុំទេ គឺក្នុងសាលារបស់ខ្ញុំតែម្ដង។ មួយគឺនៅ ក-១ គឺ ប៉ុន អ្នកទទួលខុសត្រូវ។ ឯក្នុងសាលាសម្ដេចសុធារស គឺខ្ញុំជាអ្នកទទួលខុសត្រូវ

ហើយនិង ប៉ុន ហ្នឹងគេនៅពីលើខ្ញុំទៀតបាទ។ នេះជាការគ្រប់គ្រងបាទ។ ឯខាងវ៉ៃ និងបញ្ជូនសារទូរលេខនៅស្ថានទូតអាមេរិកចាស់ គឺមានលោក យស់ ជាអ្នកគ្រប់គ្រង។ អ៊ីចឹងគឺ ប៉ុន ហ្នឹងគេមានសិទ្ធិគ្រប់គ្រងអង្គភាពខ្ញុំផង ហើយ ប៉ុន -- មិនមែនតែ ប៉ុន ទេ ប៉ុន និង ថេរ គ្រប់គ្រងពីលើអង្គភាពខ្ញុំផង ហើយនិងគ្រប់គ្រងខាងផ្នែកវាយ និងបញ្ជូនសារទូរលេខនៅស្ថានទូតអាមេរិកចាស់ផងបាទ។

[១៥:១២:៣២]

**ស៖** សូមអរគុណលោក។ នៅពេលដែលយើងមើលទៅលើមន្ទីរដែលនៅស្ថានទូតអាមេរិកចាស់ គឺជាមន្ទីរ ឬក៏គឺជាកន្លែងបញ្ជូនសារ គឺមន្ទីរនេះស្ថិតក្រោមការគ្រប់គ្រងរបស់ឈ្មោះ យុគ -- គឺឈ្មោះ យស់ ថាតើមន្ទីរ ក-១៨ ហ្នឹងគឺមន្ទីរដែលនៅទូតអាមេរិកចាស់ហ្នឹង គេហៅថា ក-១៨ ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** បាទ ត្រឹមត្រូវណាស់ គឺថា នៅកន្លែងស្ថានទូតអាមេរិកចាស់ គឺជាកន្លែងទទួលសារទូរលេខ និងបញ្ជូនសារទូរលេខ មកពីគ្រប់ទូទាំងប្រទេសបាទ។ ហើយកន្លែងហ្នឹងគឺ គេហៅថា ក-១៨ ហើយសូមបញ្ជាក់ជូនលោកថា យស់ ជាប្រធាននៅសម័យហ្នឹង។ ហើយនៅពីលើ យស់ មិនមែនមានតែ ប៉ុន និង ថេរ ទេ គឺមាន ប៉ង់ នៅពីលើហ្នឹងទៀតបាទ។ ពីលើ ក-១៨ ហ្នឹងបាទ។

[១៥:១៤:២៧]

**ស៖** ឥឡូវនេះ គឺយើងពិនិត្យជាទូទៅ គឺយើងមិនទាន់ចូលទៅដល់ចំណុចលម្អិតនោះទេ។ ដូច្នេះ តើលោកអាចបញ្ជាក់បានដែរឬទេថា ទាក់ទងទៅនឹងទូរសារដែលគេបញ្ជូនចូល គឺទូរសារហ្នឹងបានទទួល ត្រូវគេទទួលនូវ -- ត្រូវបានបញ្ជូនមក ក-១៨។ មុនពេលដែលគេបកប្រែទូរលេខនោះ អាចថាគេបកនៅ ក-១ ឬក៏បកប្រែនៅសាលារបស់លោក។ ដូច្នេះ តើខ្ញុំនិយាយអំពីដំណើរវិវត្តន៍នៃការបញ្ជូនទូរលេខហ្នឹង តើខ្ញុំនិយាយបែបនេះត្រឹមត្រូវទេ?

**ឆ៖** បាទ ដំណើរការ គឺដូច្នេះ ពេលខាងភូមិភាគ ឬតំបន់ ឬក៏លោកគណៈបញ្ជាការ សុន សេន លោកបញ្ជូនមកតាមរយៈ ក-១៨ ហើយខាង ក-១៨ ទទួលបានមក គេចាត់ចែងឲ្យនីរសារបញ្ជូនទៅខាង ក-១ ឬក៏ខាងខ្ញុំ។ ពីព្រោះគេបានកំណត់ថាទិសណាដែលត្រូវបកខាងខ្ញុំ ទិសណាដែលគេត្រូវបកទៅ ក-១ គេបានដឹងអស់រួចហើយ។ បើទិសណាដែលជូនទៅក្នុង គេដាក់ជូនទៅខាង ប៉ុន ហ្នឹង។ បើទិសណាដែលជាមុខសញ្ញារបស់ខ្ញុំ គេបញ្ជូនជូនទៅសាលាសម្ដេចសុធារស ដែលកន្លែងដែលខ្ញុំនៅបាទ។

[១៥:១៦:៤៣]

**ស៖** ឥឡូវនេះ គឺយើងពិភាក្សាទៅលើអ្វីដែលលោកបានពន្យល់កន្លងមកហើយនេះ។ តើលោកអាចជួយពន្យល់ខ្ញុំបន្ថែមបានទៀតទេ? តើអ្នកណាដែលជាអ្នកសម្រេចថា ទូរលេខដែលបញ្ជូនចូលមកត្រូវបញ្ជូនទៅ ក-១ ដើម្បីធ្វើការបកប្រែ ឬមួយក៏ត្រូវបញ្ជូនទៅសាលារបស់លោក ដើម្បីធ្វើការបកប្រែ? តើអ្នកណាជាអ្នកសម្រេចនូវបញ្ហានេះ?

**ឆ៖** បាទ ព្រោះ ប៉ុន គេ គាត់ជាអ្នកមានសិទ្ធិចាត់ចែងផ្នែកសារទូរលេខ។ កំណាត់ណាដែលខ្ញុំបកប្រែ ហើយទិសណាដែលគាត់ត្រូវទទួល។ គឺបានដឹងរួចអស់ហើយ ហើយក៏គាត់បានប្រាប់ទៅខាង យស់ ថាបើឃើញទិសនេះ ទិសរបស់គាត់ បញ្ជូនទៅ ក-១។ បើទិសណាដែលជូនមកខ្ញុំ គេថាជូន៣៨។ លេខកូដ៣៨ ហ្នឹង គឺខ្ញុំហើយបាទ។ ឯលេខកូដសម្ងាត់កាលហ្នឹង ទៅខាង យស់ ហ្នឹង ខ្ញុំដាក់ថាជូន៥៧។ លេខ៥៧ គឺកន្លែង ក-១៨ហ្នឹង ជាកន្លែងបញ្ជូន និងទទួលសារហ្នឹងបាទ។

[១៥:១៨:៣១]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ ដើម្បីឲ្យខ្ញុំយល់ច្បាស់។ តើ ប៉ុន គឺជាអ្នកសម្រេច ថាតើទូរលេខប្រភេទណា ដែលត្រូវបញ្ជូនទៅ ក-១? ទូរលេខប្រភេទណាដែលត្រូវបញ្ជូនមកសាលារៀនរបស់លោក? បានន័យថា គាត់គឺជាអ្នកធ្វើសម្រេចជាបន្តបន្ទាប់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គាត់ជាអ្នកសម្រេចជាបន្តបន្ទាប់។ ឧទាហរណ៍ថា នៅលើសារ គេមានដាក់ខាងចុងសារ គេមានដាក់ទិសរួចហើយ ដូចខ្ញុំប្រាប់លោកខាងដើមហើយ គឺថាមានកូដសម្ងាត់។ ឧទាហរណ៍ថា ភូមិបូព៌ា គេដាក់ "A75"។ អ៊ីចឹង កន្លែងគេហៅថា ខាងបូព៌ានេះ គឺជាចំណុចដែលយួនវាវៀឈ្លានពានចូល។ អ៊ីចឹង គឺកន្លែងហ្នឹងហើយ ដែលគេជាទិសចាំបាច់ដែលខាង ប៉ុន ហ្នឹង គេត្រូវបកប្រែនៅ ក-១។ ឯទិសណាដែលមិនសំខាន់ មិនប្រញាប់ហ្នឹង ដូចជាខាងមូលដ្ឋានផ្សេងៗ ដែលមិនមានការប្រយុទ្ធគ្នាទេ គឺគេឲ្យខ្ញុំហើយបាទ។

**ស៖** ដើម្បីឲ្យយើងអាចបំពេញបន្ថែម នូវដំណើរវិវត្តន៍ នៃទូរលេខ គឺថា ក-១៨ជាអ្នកទទួលហើយបន្ទាប់មកគឺត្រូវបញ្ជូនទៅលោក ឬក៏ទៅបញ្ជូនទៅការិយាល័យ ប៉ុន។ នៅត្រង់ចំណុចនេះ គឺនៅពេលនុ៎ង គឺលោក ឬក៏ ប៉ុន បានន័យថា ការិយាល័យរបស់លោក ឬក៏ការិយាល័យរបស់ ប៉ុន គឺជាអ្នកបកប្រែទូរលេខទាំងនោះ។ បន្ទាប់ពីបកប្រែហើយ តើមានអ្វីកើតឡើងបន្តទៅទៀត?

[១៥:២០:៥៣]

**ឆ៖** បាទ បន្ទាប់ពីបកប្រែទៅជាសារទូរលេខ ជាអក្សរខ្មែរបានហើយ យើងយកខ្លឹមសារហ្នឹង

ទៅវាយម៉ាស៊ីនអង្គុលីលេខ។ វាយម៉ាស៊ីនអង្គុលីលេខហើយ ដូចជាខ្ញុំហ្នឹងដាក់ស្រោមជូនទៅខាង ប៉ុន ដាក់ថា "ជូនក-១" បាទ។ ជូនក-១ គឺបានន័យថា ជូនទៅ ប៉ុន ហើយ ដើម្បីគាត់ចាត់ចែង បាទទូរលេខហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយថា គោលដៅរបស់លោកគឺ ក-១។ តើលោកចង់និយាយថា ជាទូរលេខដែលត្រូវផ្ញើជូន ទៅមន្ទីរផ្សេងៗទៀតនៅក្នុងទីក្រុងភ្នំពេញ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ ចង់និយាយ -- លោកសួរអំមិញគឺថា ទូរលេខដែលចូលមក មិននិយាយពីរឿងចេញទេ គឺនិយាយពីចូលមកគឺ មុនដំបូងមកចូលជាលេខ លេខហើយគឺថា បានគេបកឲ្យទៅជាអក្សរ ជាខ្លឹមសារទូរលេខ ហើយជាខ្លឹមសារអក្សរ ចេញជាអក្សរ ចេញជាខ្លឹមសារ។ ហ្នឹងគឺខ្ញុំចង់បញ្ជាក់ជូនលោកថា មិនមែនយកសារហ្នឹងទៅជូនអ្នកភ្នំពេញហ្នឹងទេ គឺជូនទៅអ្នកដឹកនាំបាទ មិនមែនជូនទៅមន្ទីរក្រសួងផ្សេងៗនៅភ្នំពេញហ្នឹងទេ ជូនទៅក-១ គឺសំដៅឲ្យ ប៉ុន ហ្នឹងចាត់ចែង ទៅជូនអ្នកដឹកនាំបាទ។

**ស៖** សូមអរគុណ។ យើងនឹងពិភាក្សាបញ្ហានេះនៅពេលក្រោយ។ ក្នុងពេលឥឡូវនេះ យើងសូមពិនិត្យមើលដោយសង្ខេបទៅលើទូរលេខចេញនៅក្នុងរយៈពេលនេះ។ ដូច្នេះ ដើម្បីសន្សំពេលវេលា ខ្ញុំសូមអាននូវចម្លើយរបស់លោក ហើយយើងនឹងពិភាក្សាឲ្យបានលម្អិតទៅលើចម្លើយនេះ។

[១៥:២៣:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានគឺឯកសារ E3/63, E3/64 ហើយភាសាខ្មែរ គឺមានលេខ 00328020, ភាសាបារាំងគឺមានលេខ 00411699, ហើយភាសាអង់គ្លេសគឺមានលេខ 00334049។ ហើយនេះគឺជាអ្វីដែលលោកបានរៀបរាប់។ ខ្ញុំសូមដកស្រង់៖ "ប្រសិនបើការិយាល័យ -- ប្រសិនបើមន្ទីរ៨៧០ -- ប្រសិនគណៈ៨៧០ ចង់បញ្ជូនសារ គឺ ប៉ុន និង ចេរ ជាអ្នកទៅទទួលផ្ទាល់ពីគណៈ៨៧០ គឺគាត់ទៅកត់ត្រាពាក្យពេចន៍ របស់គណៈ៨៧០ រួចហើយយកសំណេរសារទូរលេខមកឲ្យក្រុមការងារបកប្រែសារទូរលេខដើម្បីបំភ័ន្តអក្ខរៈ។ ពេលដែលបំភ័ន្តអក្ខរៈរួចហើយប្រគល់ឲ្យទៅនីរសារដែលនៅជាមួយខ្ញុំផ្ទាល់ ឬក៏នៅក-១ យកទៅកន្លែងវិទ្យុទាក់ទងនៅទូតអាមេរិកចាស់។ អង្គភាពវិទ្យុទាក់ទងមានឈ្មោះយក់ -- យស់ ជាអ្នកគ្រប់ គ្រងនៅទីនោះ ហើយគាត់ចាត់ចែងបញ្ជូនទៅតាមមុខព្រួញដែលគេចង់បញ្ជូនទៅ។ ហើយចុងក្រោយគឺនិយាយថា "សារទូរលេខដែលអង្គភាពវិទ្យុទាក់ទងបញ្ជូនទៅគឺជាលេខកូដដែលក្រុមបកប្រែបំភ័ន្តអក្ខរៈរួច សូម្បីតែអង្គភាពដែលត្រូវទទួលក៏ជាលេខសម្ងាត់ដែរ"។ ដូច្នេះ ខ្ញុំចង់

ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចនេះ គឺទូរលេខដែលបញ្ជូនចេញ គឺជាទូរលេខសរសេរផ្ទាល់ដៃដោយ ប៉ុន និង ថេរ ហើយបន្ទាប់មកយកទៅបកប្រែ ដោយបកប្រែនៅមន្ទីរក-១ ឬមួយនៅមន្ទីររបស់លោកដែលនៅសាលារៀន។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

[១៥:២៦:២២]

**ឆ៖** បាទ ត្រឹមត្រូវណាស់ ពីព្រោះនេះជាការអនុវត្តកន្លងមក។ គឺពេលដែលគណៈមជ្ឈិមលោកមានកិច្ចការអី លោកហៅ ប៉ុន និង ថេរ ហ្នឹងហើយទៅកត់ត្រាពាក្យពេចន៍ ខ្លឹមសារដែលលោកចង់ណែនាំទៅតាមភូមិភាគ ឬតំបន់ផ្សេងៗ។ ពេលដែលបានជាខ្លឹមសារហ្នឹងហើយ លោកជូនទៅក្រុមលោកនៅក អ៎! ទិសណាដែលទាក់ទងនឹងក្រុមលោកបកប្រែនៅក-១ ក៏លោកធ្វើជាឲ្យគេបំភ័ន្តអក្ខរៈជាមួយនឹងឯកសារសម្ងាត់មួយទៀត មិនមែនបញ្ជូនខ្លឹមសារហ្នឹងទៅត្រង់ទាំងដុលទេ គឺថាគេធ្វើជាទូរលេខសម្ងាត់ចេញជាលេខទាំងអស់បាទ។ កន្លែងខ្ញុំក៏អ៊ីចឹងដែរ បើសិនណាជាខ្លឹមសារដែលលោកទៅទទួលហ្នឹងជាមុខសញ្ញាដែលគេត្រូវឲ្យខាងខ្ញុំបកប្រែ ខ្ញុំក៏បំភ័ន្តអក្ខរៈដូចគ្នា ហើយបង្វែងដានទៀតពីរបីជាន់ឯណោះលោក។ ស្មុគស្មាញណាស់ បើនិយាយអំពីរឿងបច្ចេកទេសនោះ វានិយាយមួយថ្ងៃនេះមិនអស់ទេ។ បាទៗ រឿងដំណើរការគឺដូចក្នុងចម្លើយខ្ញុំ អត់មានប្រែប្រួលទេបាទ។

**ស៖** យើងយល់ថានេះគឺជាបញ្ហាមួយដ៏ស្មុគស្មាញ ហើយសូមអរគុណលោកដែលលោកបានជួយដល់យើងក្នុងការពន្យល់។ ហើយខ្ញុំនឹងមិនពិភាក្សាឲ្យដល់កម្រិតស៊ីជម្រៅលម្អិតបែបនោះទេ។ ហើយយើងនិយាយអំពីទូរលេខចូល ហើយនិងទូរលេខចេញ។ តើលោកអាចប៉ាន់ស្មានបានដែរឬទេតាមការចងចាំរបស់លោកនោះ តើមានទូរលេខចូលប្រហែលប៉ុន្មាន ដែលគេបញ្ជូនមកការិយាល័យរបស់លោក គឺមកសាលារបស់លោក ដែលលោកត្រូវធ្វើការបកប្រែក្នុងមួយថ្ងៃ?

[១៥:២៨:០៧]

**ឆ៖** បាទ ការបកប្រែទូរលេខនៅក្នុងសម័យដែលយើងរំដោះហើយហ្នឹង គឺបើប្រៀបធៀបទៅគឺក្នុងសម័យសង្គ្រាមវាច្រើនណាស់ត្រូវធ្វើទាំងយប់ទាំងថ្ងៃ។ ក៏ប៉ុន្តែបើប្រៀបធៀបមកដល់ពេលដែលយើងរំដោះភ្នំពេញហើយ ការងារក៏វាបានធូរស្រាល មិនជាច្រើន បកទាំងយប់ទាំងថ្ងៃនោះទេ វាមានពេលសម្រាកខ្លះដែរ។ ជាមធ្យមគឺថាប្រហែលជាសារបួន-ដប់អីប៉ុណ្ណឹងទេម៉្ងៃៗហ្នឹង មិនជាច្រើនអីប៉ុន្មានទេបាទ។

**ស៖** នេះគឺនិយាយអំពីទូរលេខចូល តើលោកចាំដែរឬទេ តើទូរលេខចេញគឺមានប្រហែលជា

ប៉ុន្មានដែលលោកត្រូវធ្វើការបកប្រែនៅក្នុង១ថ្ងៃៗ?

**ឆ៖** បាទ ទូរលេខចេញក៏មិនជាច្រើនប៉ុន្មាន។ ភាគច្រើនក្នុងសម័យហ្នឹង គឺសារខ្លីៗដែរទេ មិនជាវែងប៉ុន្មានទេ។ ឯចេញនោះ គឺភាគច្រើនគឺរឿងបញ្ជូនសម្ភារៈដែលលោក ខៀវ សំផន ហ្នឹងលោកចង់ជូនចែកចាយទៅមូលដ្ឋានអី លោក -- ពេលណាលោកត្រូវបញ្ជូនទៅមូលដ្ឋាន លោកតែងតែឲ្យទូរលេខហ្នឹងមកឲ្យក្រុមខ្ញុំបកប្រែ ដើម្បីឲ្យដឹងថា ភាគីម្ខាងទៀតហ្នឹង គេរង់ចាំទទួល ថាតើគេត្រូវបានសម្ភារៈអីខ្លះ ប៉ុន្មានៗ បាទ។ គឺអាហ្នឹងគឺច្រើនខាង ផ្នែកខាងចែកចាយសម្ភារៈបាទ។

[១៥:៣១:៤០]

**ស៖** តើលោកចាំទេ សារទូរលេខនោះ ខៀវ សំផន បញ្ជូនសារទូរលេខក្នុង១ថ្ងៃនោះ ញឹកញាប់ប៉ុនណា? គឺ១ថ្ងៃបញ្ជូនតែមួយ ឬក៏១ខែបញ្ជូនប៉ុន្មាន? តើញឹកញយប៉ុនណាដែលគាត់បញ្ជូនមកហ្នឹងតាមលោកចាំ?

**ឆ៖** បាទ មិនជាច្រើនប៉ុន្មានដែរទេ ជួនកាលបួន-ដប់ថ្ងៃម្តង។ ប៉ុន្តែម្តងៗវាច្រើនដែរ ព្រោះគ្រប់ភូមិភាគហ្នឹង។ ឧបមាថា រឿងហ្នឹងតែមួយ តែដល់គ្រប់ភូមិភាគ គ្រប់តំបន់ទៅ វាឡើងមួយ វាទៅគុណនឹងដប់ គុណនឹងអីទុំងនោះ ខ្លឹមសារដែលរឿងចែកសម្ភារៈមួយហ្នឹងបាទ។ អ៊ីចឹងប្រហែលជាបួន-ដប់ថ្ងៃមានម្តងមែន ប៉ុន្តែម្តងៗ ១គុណនឹងប៉ុន្មានដណ្តប់នោះ គ្រប់មូលដ្ឋាន គ្រប់ភូមិភាគបាទ។

**ស៖** ខ្ញុំចង់ពិនិត្យមើលដោយសង្ខេបទៅលើការបញ្ជូនចេញ និងបញ្ជូនមកពីភូមិភាគ លោកបានឆ្លើយប្រាប់យើងខ្ញុំថា មុនឆ្នាំ៧៥ មានសារទូរលេខបញ្ជូនមកពីភូមិភាគ និងបញ្ជូនមកពីតំបន់។ តើក្រោយឆ្នាំ៧៥ ក្រោយខែមេសា ឆ្នាំ១៩៧៥នោះ មានទូរលេខបញ្ជូនមកពីភូមិភាគ និងតំបន់មកលោកទៀតដែរឬទេ?

[១៥:៣៣:៥៤]

**ឆ៖** បាទ ការរៀបចំភូមិភាគ និងតំបន់ គឺវាទៅតាមលំនាំមុន៧៥ដែរ។ លើកលែងតែភូមិភាគមួយដែលមិនមានការទំនាក់ទំនងខាងផ្នែកទូរលេខនោះ គឺភូមិភាគពិសេស ពីព្រោះភូមិភាគពិសេស គឺនៅភ្នំពេញស្រាប់ហើយ។ ឯក្រៅពីហ្នឹងបន្តការទាក់ទងដូចកាលពីមុន៧៥ដែរ។

**ស៖** តើការទាក់ទង តាមសារទូរលេខនេះ នៅតែបន្តពេញមួយរបបនោះតែម្តង នៅពេលដែលលោកធ្វើការនៅក្នុងទីក្រុងភ្នំពេញនោះ ឬក៏មិនបន្តពេញមួយរបបនោះទេ?

**ឆ៖** បាទ ការទាក់ទងហ្នឹងបន្តរហូតដល់ថ្ងៃដែលវៀតណាមវាយលុកចូលភ្នំពេញ។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរអំពីការបញ្ជូនសារទូរលេខចេញចូលជាក់ស្ដែងតែម្ដង។ ខ្ញុំចង់ពិនិត្យមើលចម្លើយរបស់លោក ដែលលោកឆ្លើយលើកទី២ ហើយឲ្យលោកជួយពន្យល់លម្អិតបន្ថែម ឯកសារ E3/67។ អត្ថបទដែលខ្ញុំយោងទៅនេះត្រង់ ERN ជាភាសាខ្មែរលេខ 00294542, បារាំង ERN គឺ 00374938, អង់គ្លេសគឺ 00483971។ នៅក្នុងនោះគឺលោកបានឆ្លើយដូចតទៅលោក សុផង់ ដកស្រង់សម្ដីរបស់លោក "នៅក្នុងការទាក់ទងជាមួយនឹងគណ:៨៧០ ពួកគេមានពេលវេលារបស់គេ។ ឧទាហរណ៍ នៅក្នុងភូមិភាគមួយគេត្រូវទាក់ទងនៅម៉ោងប្រាំពីរព្រឹក ដប់ព្រឹក ឬក៏មួយរសៀល ម៉ោងដប់ប្រាំបួន នេះគឺជាឧទាហរណ៍ចេញមកពីភូមិភាគមួយ ភូមិភាគផ្សេងក៏ទាក់ទងតាមម៉ោងកំណត់ផងដែរ"។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា ភូមិភាគនីមួយៗ គឺត្រូវបានគេកំណត់ម៉ោងជាក់លាក់នៅក្នុងថ្ងៃនីមួយៗ ដែលជាម៉ោងពួកគេអាចបញ្ជូនលេខកូដសារទូរលេខមក មន្ទីរក-១៨?

[១៥:៣៧:២៤]

**ឆ៖** បាទ ជាការត្រឹមត្រូវណាស់ ពីព្រោះការទាក់ទងគ្នាតាមរលកអាកាស វាមានទៅតាមម៉ោងកំណត់។ បើយើងមិនឡើងតាមគ្នាតាមកំណត់ទេ ម៉េចដែគូទាំងសងខាងទាក់ទងគ្នាបាន ទាល់តែណេះក៏ឡើង ខាងណោះក៏ឡើង បានទំនាក់ទំនងគ្នាបាន បាទ។ គ្រប់កន្លែងគឺសុទ្ធតែមានឯកសារទាក់ទងតាមរលកអាកាស គ្រប់ភាគីទាំងអស់គឺមានកាលបរិច្ឆេទកំណត់ មានពេលមានម៉ោង។ កន្លែងខ្លះត្រូវទាក់ទងគ្នាមួយថ្ងៃបីដង កន្លែងខ្លះកំណត់ថាទាក់ទងពីរដងក៏បាន។ រហូតដល់កន្លែងខ្លះ ដែលមិនសូវមានបញ្ហាអី គេអាចទំនាក់ទំនងគ្នាមួយថ្ងៃម្ដងក៏បានដែរបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់ តើខ្ញុំយល់ចម្លើយរបស់លោកបានត្រឹមត្រូវដែរឬទេ? តើអម្បាញ់មិញនេះលោកបានធ្វើការបកប្រែ តើលោកធ្វើការបកប្រែសារទូរលេខរបស់ភូមិភាគនីមួយៗដែរឬទេ? ដូចថាពីភូមិភាគបស្ចិមទៅដល់ភូមិភាគផ្សេង។ ដូច្នេះតាមការយល់របស់ខ្ញុំ តើលោកធ្វើការបកប្រែសារទូរលេខពីភូមិភាគមួយទៅភូមិភាគមួយ ឬក៏យ៉ាងម៉េច តាមដែលខ្ញុំយល់?

[១៥:៣៩:១៥]

**ឆ៖** បាទ ការបកប្រែហ្នឹងវាមិនមានក្រុមខ្ញុំនិង ប៉ុន ហ្នឹង វាមានសិទ្ធិបកប្រែទៅតាមការចាំបាច់។ កន្លែងខ្ញុំនេះក៏មានសិទ្ធិបកប្រែសារមកពីគ្រប់ភូមិភាគ តំបន់ដូចគ្នាដែរ។ ប៉ុន្តែកាលៈទេសៈខ្លះក្នុងករណីដែលមានភូមិភាគខ្លះ មានបញ្ហាមមាញឹក ដូចជានៅខាងបូព៌ា នៅខាងពួ្លសានអីជាដើម។ ឧទាហរណ៍ សារហ្នឹង មុខសញ្ញាហ្នឹង ខ្ញុំ គេប្រគល់ឲ្យខ្ញុំទេ ក៏ប៉ុន្តែសភាពការណ៍ កាលៈទេសៈហ្នឹងវា

ត្រូវការឆ្លើយឆ្លងឲ្យគ្នាឲ្យបានរហ័ស។ អ៊ីចឹងគេត្រូវដកឯកសារដែលខ្ញុំ ទោះបីខ្ញុំកាន់ក៏ដោយទិសហ្នឹងក៏គេដកឯកសារហ្នឹងទៅ ក-១ ទៅធ្វើនៅ ក-១ បានដែរ។ នេះជា គេបត់បែនទៅតាមកាលៈទេសៈ មិនមែនងាប់ក្រឡាថា បកអីគឺនៅឲ្យកាន់តែអាហ្នឹងទេបាទ។

**សៈ** ខ្ញុំមិនប្រាកដថា តើលោកឆ្លងតបទៅនឹងសំណួររបស់ខ្ញុំ ប្រហែលជាលោកមានការភ័ន្តច្រឡំសំណួររបស់ខ្ញុំនោះ គឺចង់សួរថា នៅក្នុងពេលដែលលោករៀបរាប់ពេលវេលាអម្បាញ់មិញដែលលោកបានបញ្ជាក់មកកំណត់សម្រាប់ភូមិភាគនីមួយៗនោះ តើភូមិភាគនីមួយៗដែលបញ្ជូនសារទូរលេខទៅវិញទៅមកនោះ គឺដូចជាឧទាហរណ៍ថា ពីខាងភូមិភាគបូព៌ា បញ្ជូនទៅភូមិភាគបស្ចិមនោះ តើមានម៉ោងកំណត់របស់គេដែរឬទេ?

[១៥:៤១:២៣]

**ឆៈ** រឿងទាក់ទងរឿងភូមិភាគនិងភូមិភាគ ខ្ញុំអត់ដឹងទេបាទ។ ខ្ញុំដឹងតែការទាក់ទងពីភូមិភាគមកកន្លែងយើងខ្ញុំ។

**សៈ** សូមអរគុណលោកដែលលោកបានបញ្ជាក់ត្រង់នេះ។ តើការធ្វើទំនាក់ទំនងតាមវិទ្យុរវាង ក-១៨ និងភូមិភាគ គេបានធ្វើឡើង ហើយមានដំណើរការទាក់ទងគ្នាដូច្នេះ ២៤ម៉ោងក្នុង១ថ្ងៃដែរឬទេ? ឬក៏ការទាក់ទងគ្នារវាងកន្លែងទាំងពីនេះ មានលក្ខណៈតិចតួច?

**ឆៈ** បាទ ការទាក់ទងគ្នារវាង ក-១៨ ជាមួយនឹងភូមិភាគ គឺទៅតាមពេលវេលា និងម៉ោងដែលបានកំណត់គ្នាក្នុងឯកសារទាក់ទងតាមរលកអាកាស។ ដូចខ្ញុំជម្រាបលោកហើយ ជួនកាលកន្លែងខ្លះបីដងក្នុង១ថ្ងៃ ពីរដងក្នុង១ថ្ងៃ ឬមួយដងក្នុង១ថ្ងៃ ទៅតាមសភាពការណ៍ជាក់ស្តែងដែលឯកសារបានកំណត់។ ក៏ប៉ុន្តែក្នុងករណីដែលមានសភាពការណ៍កើតឡើង គេអាចសន្យាគ្នាថា យើមិនបាច់ទាក់ទងតាមកំណត់នោះទេ យើងបើចំហ ២៤ម៉ោង ឡើងពេលណាក៏ជួបគ្នាបាន។

[១៥:៤៣:៥៨]

**សៈ** តាមការយល់ដឹងរបស់លោក តាមរយៈការងារនោះ ការងាររបស់លោក តើសារទូរលេខដែលបញ្ជូនចេញពី ក-១៨ តើសារទូរលេខទាំងអស់នោះ តែងតែទៅដល់ភូមិភាគនានា និងមន្ទីរនានាដែលបញ្ជូនចេញពី ក-១៨ ឬក៏មិនទៅដល់ទេ ជានិច្ចកាលនោះ?

**ឆៈ** បាទ ខ្ញុំមិនអាចដឹងបានអស់ទេ រឿងដល់ ឬមិនដល់ ពីព្រោះការបញ្ជូនទៅគឺទៅតាមរលកអាកាស។ ឯរឿងដល់មិនដល់ គឺនៅលើអ្នកដែលមានភារកិច្ចបញ្ជូន ឬក៏មិនបញ្ជូន បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ បាទ ឥឡូវយើងដល់ពេលក៏សមល្មមសម្រាកដែរហើយ ដោយសារយើងមិនបានសម្រាកនៅពាក់បណ្ដាលម៉ោងអម្បាញ់មិញនេះ។ ប៉ុន្តែមុននឹងជម្រាបអំពីបញ្ហាសម្រាក អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្ដីលោក អៀង សារី នៅកិច្ចដំណើរការសវនាការថ្ងៃស្អែក និងខានស្អែកនេះ អង្គជំនុំជម្រះមាន បានកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើសវនាការពិនិត្យឡើងវិញ សម្បទាចូលរួមសវនាការលោកស្រី អៀង ធីរិទ្ធ ហើយដោយកាលពីលើកមុនហ្នឹង គឺខាងក្រុមមេធាវីការពារក្ដីលោក អៀង សារី ហើយនិងលោក អៀង សារី ដោយសារមានទំនាក់ទំនងភរិយា ស្វាមី អ្នកទាំងពីរនោះ គាត់បានស្នើសុំចូលរួមនូវកិច្ចដំណើរការសវនាការសម្បទាចូលរួមសវនាការរបស់លោកស្រី អៀង ធីរិទ្ធ។

[១៥:៤៥:៥៦]

សំណួរសួរ តើសវនាការនៅថ្ងៃស្អែក និងខានស្អែកនេះ លោកដឹងទេ ថាតើលោក អៀង សារី មានបំណងយ៉ាងម្ដេចដែរ? ហើយលោកមេធាវីការពារក្ដីលោក អៀង សារី ក៏មានបំណងយ៉ាងដូចម្ដេចដែរ នៅក្នុងការក្នុងដំណើរការសវនាការនៅថ្ងៃស្អែក និងថ្ងៃខានស្អែកនេះ?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពអស់លោក លោកស្រីចៅក្រម។ សួស្ដីព្រះរាជអាជ្ញា សភាតា អស់លោកអ្នកទាំងអស់។ សម្រាប់សវនាការលើសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ថ្ងៃស្អែក និងថ្ងៃខានស្អែកនេះ ក្រុមមេធាវីលោក អៀង សារី នឹងបែងចែកការងារគ្នា។ ខ្ញុំមកម្នាក់ឯង ប្រហែលជាមានសហការីមួយចំនួនមកតាម ហើយលោកដោយឡែក លោក ម៉ៃខល គាត់ជាប់កិច្ចការព្រាងការងារដោយឡែក សម្រាប់សាក្សីផ្សេង គឺគាត់មិនបានអញ្ជើញមកទេ។

ដោយឡែក លោក អៀង សារី គាត់នឹងមកចូលរួមក្នុងសវនាការនេះដែរ ប៉ុន្តែនៅបន្ទប់រង់ចាំខាងក្រោម ជាធម្មតា។ សូមអរគុណលោកប្រធាន។

[១៥:៤៧:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកដែរហើយ

អង្គជំនុំជម្រះប្រកាសផ្អែកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការស្ដាប់សក្ខីកម្ម នង សុផង់ ត្រូវលើកទៅបន្តធ្វើនៅព្រឹកថ្ងៃចន្ទ ទី០៣ ខែកញ្ញា ឆ្នាំ២០១២ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

[១៥:៤៧:២៨]

សវនាការនៅព្រឹកថ្ងៃចន្ទសប្ដាហ៍ក្រោយនេះ នឹងបន្តស្ដាប់សក្ខីកម្ម នង សុផង់ ដែលនឹងបន្តការតាំងសំណួរដេញដោល ដោយភាគីសហព្រះរាជអាជ្ញា។

លោក នង សុផង់ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនចប់នៅឡើយទេ។ សវនាការ ត្រូវបន្តធ្វើនៅថ្ងៃចន្ទ ទី០៣ ខែកញ្ញា ឆ្នាំ២០១២ គឺដើមសប្ដាហ៍។

ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃចន្ទទៀត។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទសប្ដាហ៍ក្រោយ នៅពេលវេលាប្រាំបួន។

អង្គជំនុំជម្រះសូមជម្រាបផងដែរ ថានៅថ្ងៃស្អែក ទី៣០ និងថ្ងៃខានស្អែក ទី៣១ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងធ្វើសវនាការ គោលបំណងដើម្បីវាយតម្លៃឡើងវិញ លើសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដោយការពិភាក្សាសួរដេញដោល អ្នកជំនាញខាងជំងឺវិកលចរិត ឯកសារ និងសាក្សីមួយចំនួន ដែលមានភាពពាក់ព័ន្ធ។

[១៥:៤៨:៤០]

សវនាការនៅថ្ងៃស្អែក នឹងចាប់ផ្ដើមធ្វើនៅម៉ោងដប់ និងសាមសិបនាទី ដោយហេតុថា អង្គជំនុំជម្រះរង់ចាំមានវត្តមានមេធាវីអន្តរជាតិការពារក្ដីឲ្យលោកស្រី អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការនេះ។ មេធាវីអន្តរជាតិការពារក្ដីលោកស្រី អៀង ធីរិទ្ធ គឺលោកស្រី ដាយអាណា អេលីស នឹងធ្វើដំណើរមកដល់អាកាសយានអន្តរជាតិ -- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅវេលាម៉ោងដប់ព្រឹក ថ្ងៃស្អែកនេះ។

សវនាការនៅថ្ងៃស្អែក និងខានស្អែកនេះ ប្រព្រឹត្តទៅជាសាធារណៈ វត្តមានរបស់ក្រុមមេធាវីការពារក្ដី នួន ជា, ខៀវ សំផន និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ពុំមានភាពចាំបាច់ឡើយ។ ដោយឡែក ក្រុមមេធាវីការពារក្ដីលោក អៀង សារី អាចចូលរួមក្នុងសវនាការនេះបាន ក្នុងនាមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ។ សូមភាគី និងសាធារណជនជ្រាប។

[១៥:៤៩:៣១]

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប គឺ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក ចុះ និងឲ្យនាំខ្លួនពួកគាត់ទាំងបីរូប មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទសប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែក នៅព្រឹកថ្ងៃស្អែក ទី៣០ ខែសីហា ដើម្បីមូលហេតុយុត្តិធម៌ អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ និង អៀង សារី មកត្រឹមបន្ទប់ឃុំខ្លួន នៅពីក្រោមសាលសវនាការនេះ ដែលមានរៀបចំឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥០ នាទី)*